

រៀបរៀងដោយ ភិក្ខុ ធម្មបាលោ (ណុប គ្រុយ)
វត្តវិបស្សនារាម (អែរ៉ាប់) ឡុង ប៊ិច

-----------ooOoo-----------

ចាប់ ពីត្រឹមនេះទៅ

ជាធម៌ នមស្ការពិស្តារ-(វែង)

-នមស្ការពិស្តារ-(វែង)----------------៥

-នមស្ការសង្ខេប-(ខ្លី)----------------៣៨

-សុំសីល ៥-------------------- ៦៣

-សុំសីល ៨-------------------- ៦៨

-ពាហុំ------------------------ ៨១

-ព្រះពុទ្ធ ២៨ព្រះអង្គ (នមោមេ)------ ៩០

-បារមី ៣០-------------------- ៩៤

-ឯតទគ្គ ----------------------៩៧

-ធម៌សូត្រនមស្ការនៅបណ្តូលពោធិព្រឹក្ស-១០៧

-នមស្ការ សត្តមហាឋាន------------១២៩

-នមស្ការ ព្រះអរហន្ត ៩ទិស---------១៣២

-នមស្ការព្រះពុទ្ធចេតិយ-------------១៣៤

-ពុទ្ធកិច្ច ៥យ៉ាង-----------------១៣៥

-ធម៌ខន្តី-----------------------១៣៧

-សេចក្តីត្រិះរិះ របស់នាងវិសាខា------១៣៨

-មង្គលសូត្រ--------------------១៣៩

-អារាធនាព្រះធម៌ទេសនា------------១៤៣

-សុំខមាទោសពេលចប់ព្រះធម៌ទេសនា--១៤៤

-វេរព្រះត្រៃបិដក-----------------១៤៥

-វេរចង្ហាន់ថ្វាយព្រះដ៏មានព្រះភាគ-----១៤៦

++វេរបាយបិណ្ឌ------------- ១៤៧

++វេរចង្ហាន់ប្រគេនសង្ឃ---------១៤៨

++ធម៌ឧទ្ទិសបុណ្យកុសល---------១៤៩

++សុំខមាទោសព្រះរតនត្រ័យ-------១៥០

++ពាក្យសុំខមាទោសមាតាបិតា-----១៥២

++ក្រុងពារាណសី ព្រៃឥសិបតន----១៥២-ខ

++ថ្វាយបង្គំព្រះពុទ្ធ ៥ព្រះអង្គ------១៥២-គ

++ធម៌រំលឹកគុណមាតាបិតា---------១៥៣

++ពាក្យម៉ែមួយម៉ាត់------------ ១៥៣-B

++ព្រះគុណឪ--------------- ១៥៣-D

++ព្រះគុណម៉ែ----------------១៥៣-G

++ពាក្យខមាទោសដល់សព្វសត្វ----១៥៤-ក

++សុភមង្គលគាថា-------------១៥៤-ខ

++ធម្មចក្កប្បវត្តនសូត្រ-----------១៥៥

++អនត្តលក្ខណសូត្រ------------១៧១-ក

++អាទិត្តបរិយាយសូត្រ--------- ១៧១-A

++បរាភវសូត្រ----------------១៧២

++វេរភត្តក្នុងបុណ្យទូទៅ -------- ១៨២

++វេរបច្ច័យបួន ជាសង្ឃទាន------១៨៣

++អាយុរបស់សត្វក្នុងត្រៃភព------១៨៤

ភិក្ខុធម្មបាលោ. ឈាប_គ្រួយ

ឈ្មោះទេវតាទាំង៧ មានឈ្មោះតាមថ្ងៃទាំង៧

ជាបុត្រីនៃកបិលមហាព្រហ្ម

ថ្ងៃ	ឈ្មោះទេវតា	សៀតផ្កា	គ្រឿងប្រដាប់	អាហារ	អាវុធឆ្វេង	អាវុធស្តាំ	យានជំនិះ
អាទិត្យ	ទុង្សាទេវី	ផ្កាទទឹម	កែវបទុមរាគ	ផ្លែឧទុម្ពរ	ចក្រ	ស័ង្ខ	ជិះគ្រុឌ
ច័ន្ទ	គោរាគទេវី	ផ្កាអង្គាបុស្ស	កែវមុក្តា	ផ្លែព្រីង	ព្រះខ័ន	ឈើច្រត់	ជិះខ្លា
អង្គារ	រាក្សាសាទេវី	ផ្កាឈូក	កែវមោរា	លោហិត	ត្រីសូល៍	ធ្នូ	ជិះសេះ
ពុធ	មណ្ឌាទេវី	ផ្កាចម្ប៉ា	កែវពិទូរ្យ	ទឹកដោះ	ម្ជុល	ឈើច្រត់	ជិះលា
ព្រហស្បត៍	កិរិណីទេវី	ផ្កាមន្ទាបុស្ស	កែវមក៌ត	សណ្តែកល្ង	កង្វេរ	កាំភ្លើង	ជិះដំរី
សុក្រ	កិមិរាទេវី	ផ្កាចង្កុលណី	កែវបុស្សរាគម	ចេកណាំវ៉ា	ព្រះខ័ន	ពិណ	ជិះក្របី
សៅរ៍	មហោទរាទេវី	ផ្កាត្រកៀត	កែវលីលរតន៍	សាច់ទ្រាយ	ចក្រ	ត្រីសូល៍	ជិះក្ងោក

ចង់ជាពាក្យកាព្យដាយចាំ

-ថ្ងៃអាទិត្យឈ្មោះទុង្សា ថ្ងៃច័ន្ទណាឈ្មោះគោរាគ ចូរចាំចំណាំពាក្យ រាក្សសាថ្ងៃអង្គារ

ថ្ងៃពុធនាងអ្នក ទេវតាជាក់ឈ្មោះមណ្ឌា ថ្ងៃព្រហស្បត៍មាននាមថា ឈ្មោះទេវតាកិរិណី

ចំណែកថ្ងៃសុក្រ ចូរចាំទុកកិមិរា ថ្ងៃសៅរ៍មាននាមថា ឈ្មោះទេវតាមហោទរា។

នូវថ្ងៃទាំង៧ ចូរកុំខ្ជិលខំពិនិត្យ ១៣មេសាពិត? រៀងរាល់ឆ្នាំហោង ៕

ចំណាំៈ បើចូលឆ្នាំចំថ្ងៃណា សូមមើលតាមថ្ងៃនោះ នឹងឃើញឈ្មោះទេវតា-អាហារ-សំលៀកបំពាក់។ល។

(ដកស្រង់ពីសៀវភៅពីធីទសមាសភាគ១បុរាណ)

BOOK.1

នមស្ការព្រះរតនត្រៃ

សមាទានសីល ៥

សមាទានសីល ៨

រៀបរៀងដោយ ភិក្ខុធម្មបាលោ
វត្តសន្សំកុសល



មហាពោធិព្រឹក្សអាយុជាង៥០០ឆ្នាំ វត្តកល្យាណី ស្រីលង្កា

ភិក្ខុធម្មបាលោ.ឈុំម_គ្រួយ

អាត្មាភាព ភិក្ខុ ធម្មបាលោ

(ព្រះអង្គ គ្រួយ)

ក្នុងវស្សាទី៧ បាន

រៀបរៀងសៀវភៅ ធម៌នមស្ការព្រះរតនត្រៃ និងសមាទានសីល៥-សីល៨ នេះឡើង ដោយចិត្តជ្រះថ្លា នឹកឃើញដល់ឧបាសក ឧបាសិកា-ទាយក ទាយិកាមួយចំនួនថា អស់លោកទាំងនោះ អ្នកខ្លះចេះចាំល្អ អាចធ្វើការនមស្ការ ឬ សមាទានសីល ដោយមាត់ទទេ អាចប្រព្រឹត្តទៅបាន ។ អ្នកខ្លះទៀតពុំអាចសូត្រមាត់ទទេបានទេ ព្រោះពុំចាំ ។

ដោយចិត្តជា សទ្ធា ជ្រះថ្លា របស់អាត្មាភាព នឹកគិតទៅដល់សេចក្តីត្រូវការ របស់លោកអ្នកសប្បុរស ទាំងឡាយនោះ ដែលប្រាថ្នាក្នុងការ នមស្ការព្រះរតនត្រៃ ឬ សមាទានសីល៥ សីល៨ ហើយពុំអាចសូត្រមាត់ទទេបាន អាត្មាភាពក៏បានរៀបរៀងសៀវភៅនេះឡើង ឲ្យមានត្រឹមតែ ធម៌នមស្ការព្រះរតនត្រៃ និង សមាទានសីល៥ សីល៨ប៉ុណ្ណោះ ដើម្បីងាយក្នុងការបើករក សំរាប់អ្នករៀនថ្មី ឬអ្នកដែលពុំអាចសូត្រមាត់ទទេបាន ។

សព្វទានំ ធម្មទានំ ជិនាតិ ធម្មទានរមែងឈ្នះអស់ទានទាំងពួង

វត្តសន្សំកុសល ថ្ងៃចូលវស្សា ១រោច ខែអាសាឍ ២៥៥០ ០៧-១១-២០០៦

ភិក្ខុធម្មបាលោ.អង្គ_គ្រួយ

ភិក្ខុធម្មបាលោ.អង្គ_គ្រួយ

បូជនីយដ្ឋាន ឧទ្យាន លុម្ពិនី

ទីនេះហើយ ដែលព្រះតថាគតប្រសូត្រ

(ថ្ងៃសុក្រ ១៥កើត ខែពិសាខ ឆ្នាំចរ)

ប្រពៃណីរបស់ស្ត្រីក្នុងសម័យព្រះតថាគត ពេលមានគភ៌គ្រប់ខែត្រូវប្រសូត្របុត្រ គឺត្រូវទៅប្រសូត្រខាងមាតាបិតារបស់ខ្លួន ក្រោយពីទ្រង់គភ៌ព្រះបរមពោធិសត្វ ជាគំរប់១០ខែកាលណា ព្រះនាង សិរីមហាមាយាទេវី ព្រះពុទ្ធមាតា ក៏បានថ្វាយបង្គំលាព្រះបាទសេរីសុទ្ធោធន ព្រះពុទ្ធបិតា ទៅកាន់ទេវទហបុរីជានគរកំណើត ។ ទៅដល់ពាក់កណ្តាលផ្លូវ គឺព្រំប្រទល់រវាង កបិលពស្តុ និង ទេវទហបុរី ព្រះនាងក៏ឲ្យពួករាជបុរស និង ចតុរង្គសេនាដាក់ព្រះនាងចុះពីគ្រែស្នែង ដើម្បីបានឈប់សំរាកព្រះកាយ ព្រះនាងក៏យាងចូលទៅក្រោមម្លប់ឈើមួយ ដែលមានមែកសាខាធ្លាក់មកទាបស្មើដល់ដី ប្រកបទៅដោយផ្កាដេរដាស់ តាំងពីគល់ដល់ចុងមែក គួរ

ជាទីរីករាយ ព្រះនាងសិរិមហាមាយា ក៏យកព្រះហស្ត លូកចាប់មែកឈើមួយ ដែលធ្លាក់មកទាបជាងគេ គ្រានោះឯងដែលព្រះរាជបុត្រទ្រង់ប្រសូត្រចាកព្រះគភ៌ ទាំងដែលព្រះមាតាទ្រង់ឈរ ដោយឥតមានប្រឈួនសូម្បីតិចតួចក៏គ្មាន នេះជាទំនៀម នៃការប្រសូត្ររបស់ព្រះបរមពោធិសត្វ ។

ព្រហ្មពីសុទ្ធាវាស៤អង្គ ដែលជាព្រះខីណាស្រព កាន់សំណាញ់មាស ទទួលព្រះបរមពោធិសត្វ អំពីព្រះមាតា មុននឹងចុះដល់ផែនដី ដម្កល់ទុកខាងមុខព្រះមាតាថា បពិត្រព្រះនាងទេវី សូមព្រះនាងមានចិត្តរីករាយចុះ បុត្ររបស់ព្រះនាងជាអ្នកមានសក្តិធំ ទ្រង់កើតឡើងហើយ ។ ព្រះបរមពោធិសត្វ ទ្រង់ប្រតិស្ឋាន ឈរលើផែនដី ដោយព្រះបាទជាន់ស៊ប់ ផ្តោះព្រះភក្ត្រទៅកាន់ទិសឧត្តរ ទ្រង់យាងឈានទៅបាន៧ជំហាន ក៏រមិលមើលទូទៅទិសទាំងពួង ទ្រង់ពោលនូវអាសភិវាចា គឺវាចាដ៏ឧត្តមថា :

- អគ្គោហមស្មិ លោកស្ស : អញជាបុគ្គលខ្ពង់ខ្ពស់របស់លោក
- ជេដ្ឋោហមស្មិ លោកស្ស : អញជាបុគ្គលធំបំផុតរបស់លោក
- សេដ្ឋោហមស្មិ លោកស្ស : អញជាបុគ្គលប្រសើរបំផុតរបស់លោក
- អយមន្តិមា មេ ជាតិ : នេះជាកំណើតចុងក្រោយរបស់អញ
- នត្ថិទានិ បុនព្ភវោតិ : ភពថ្មីតពីនេះទៅទៀតមិនមានឡើយ

(សុត្តន្តបិដក ទីឃនិកាយ មហាវគ្គ)

------++++-------

មាតិកាធម៌

-បទសារភញ្ញ ---៥
-នមស្ការពិស្តារ (វែង) ---៥
-យោកប្បកោដី ---១៨
-ថ្វាយបង្គំព្រះបាទសូត្រជាពាក្យកាព្យ----២០
-ថ្វាយបង្គំព្រះបាទសូត្រជាពាក្យធម្មតា---២២
-វន្ទាមិ ចេតិយំ សព្វំ ---២៣
-ផ្សាយមេត្តាទិសទាំង១០ជាបាលី---២៤
-ផ្សាយមេត្តាទិសទាំង១០ ប្រែ---២៥
-បត្តិទានគាថា(យំ កិញ្ចិ កុសលកម្មំ)----២៩
-តេជះខ្ញុំសាង ---៣២
-ទានសីលខ្ញុំធ្វើហើយ ---៣៣
-ឧទ្ទិសកុសល(ឥតទំនោ)ជាពាក្យកាព្យ --៣៤
-ឧទ្ទិសកុសល(ឥតទំនោ)ជាពាក្យធម្មតា--៣៥
-អរិយមគ្គអង្គ៨ ---៣៦
-សូមឲ្យសាសនាព្រះសម្ពុទ្ធ ---៣៧
-ធម៌សុំចង្ហាន់អំពីព្រះសង្ឃ ---៣៧
-នមស្ការសង្ខេបខ្លី ---៣៨
-សុំសីល ៥ ---៦៦
-សុំសីល ៨ ---៧១
-អង្គនៃឧបោសថ ---៧៦
-ពាហុំ ---៨១
-ព្រះពុទ្ធ ២៨ព្រះអង្គ (នមោមេ) ---៩០
-បារមី៣០(ឥតិបិទាន) ---៩៤
-ឯតទគ្គ ---៩៧
-បទសូត្រដាក់ទង់ ---១០៧
-បទសូត្រលើកទង់---១០៨
-បទថ្វាយផ្កា (វែង ខ្លី) ---១១០ – ១១១
-ធម៌ថ្វាយជ័យឃោស (ជយោហិ)---១១២
-ធម្មនិយាម ៣០ ---១១៥
-គោតមប្រវត្តិ ---១១៩
-រក្សាព្រះត្រៃបិដក ---១២២
-ថ្ងៃគួរនមស្ការ ---១២៤
-ឧបមាគុណព្រះរតនត្រៃ២២ប្រការ----១២៥
-នមស្ការសត្តមហាឋាន---១៣២
-នមស្ការព្រះអរហន្ត ៩ទិស ---១៣៥
-នមស្ការព្រះពុទ្ធចេតិយ ---១៣៧
-ពុទ្ធប្រវត្តិ ពុទ្ធកិច្ច ---១៣៨ -១៣៩
-ធម៌ខន្តី ---១៤០
-សេចក្តីត្រិះរិះរបស់នាងវិសាខា ---១៤១
-អារាធនាព្រះសង្ឃទេសនា(អន្លង់ឱឃៈ៤)--១៤២
-អារាធនាព្រះសង្ឃទេសនា(អហំវីរខ្ញុំម្ចាស់)--១៤៣
-អារាធនាទេសនា(សហម្បតីព្រហ្ម) ---១៤៤
-អរព្រះគុណ និងខមាទោសចប់ទេសនា ---១៤៥
-អារាធព្រះសង្ឃចំរើនព្រះបរិត្ត ---១៤៦
-អញ្ជើញពួកទេវតា (សគ្គេ កាមេ) ---១៤៧
-វេរភត្តប្រគេនសង្ឃ (បុណ្យទូទៅ) ---១៤៨
-វេរបច្ច័យបួនសង្ឃទាន ---១៤៩
-វេរចង្ហាន់ថ្វាយព្រះមានព្រះភាគ ---១៥០
-វេរចង្ហាន់ប្រគេនសង្ឃ (ពាក្យកាព្យ) ---១៥១
-វេរបាយបិណ្ឌ ---១៥២
-វេរព្រះត្រៃបិដក ---១៥៣
-វេរកឋិនទាន ---១៥៤
-ធម៌ឧទ្ទិសជូនបុណ្យ (ពាក្យកាព្យ) ---១៥៥
-សូមខមាទោសព្រះរតនត្រៃ ---១៥៦
-សូមខមាទោសមាតាបិតា ---១៥៨
-ខ្ញុំនឹកព្រះណាស់ ---១៥៩
-ក្រុងពារាណសី ---១៦០
-រំលឹកគុណមាតាបិតា ---១៦២
-ពាក្យម៉ែមួយម៉ាត់ ---១៦៣
-ព្រះគុណឪ - ព្រះគុណម៉ែ ---១៦៥-១៦៨
-សូមខមាទោសចំពោះសព្វសត្វ---១៧០
-សុភមង្គលគាថា ---១៧១
-បរាភវសូត្រ ---១៧២
-អាយុសត្វក្នុងត្រៃភព ---១៨១
-មង្គលសូត្រ ---១៨៣
-ធម្មចក្កប្បវត្តនសូត្រ ---១៨៧
-អនត្តលក្ខណសូត្រ ---២០៤
-អាទិត្តបរិយាយ - សតិប្បដ្ឋានសូត្រ---២១៩-២៣០



រៀបរៀងដោយ   ភិក្ខុ ធម្មបាលោ (ឈុប គ្រុយ)

វត្តវិបស្សនារាម (អៃរ៉ាប់) ឡុង ប៊ិច

------------ooOoo------------

បទសារភញ្ញ

សូមថ្វាយបង្គំព្រះសម្ពុទ្ធ ប្រសើរបំផុតក្នុងលោកា
ជាគ្រូនៃមនុស្សនិងទេព្តា ទ្រង់ត្រាស់ទេសនាប្រដៅសត្វ ។

ចង្អុលឲ្យដើរផ្លូវកណ្តាល មាគ៌ាត្រកាលអាចកម្ចាត់
ទុក្ខភ័យចង្រៃឲ្យខ្ចាយខ្ចាត់ អាចកាត់សង្សារទុក្ខបាន ។

សាសនាព្រះអង្គនៅសព្វថ្ងៃ សត្វមាននិស្ស័យពីបូរាណ
ប្រឹងរៀនប្រឹងស្តាប់ចេះចាំបាន កាន់តាមលំអានបានក្តីសុខ ។

ឥតមានសុខណាស្មើក្តីស្ងប់ បញ្ចប់ត្រឹមសុខឃ្លាតចាកទុក្ខ
តាំងពីលោកនេះតទៅមុខ ក្តីសុខកើតមានព្រោះធម៌ស្ងប់។

ខ្ញុំសូមបង្គំឆ្ពោះព្រះធម៌ ព្រះសង្ឃបវរទាំងសព្វគ្រប់
រួមជាត្រ័យរត្នគួរគោរព ជាម្លប់ត្រជាក់នៃលោកា ។

ព្រះរូបព្រះធាតុនៃព្រះពុទ្ធ វិសុទ្ធតាងអង្គព្រះសាស្តា
សូមគុណត្រ័យរត្នជួយខេមរា ឲ្យបានសុខាតរៀងទៅ ។

អរហំ សម្មាសម្ពុទ្ធោ ភគវា -ព្រះដ៏មានព្រះភាគអង្គនោះ ជាព្រះអរហន្តរំលត់ភ្លើង
កិលេសភ្លើងទុក្ខទាំងពួង ត្រាស់ដឹងដោយព្រះអង្គឯង

ពុទ្ធំ ភគវន្តំ អភិវាទេមិ -ខ្ញុំព្រះករុណាសូមអភិវាទព្រះដ៏មានព្រះភាគអង្គនោះ

ស្វាក្ខាតោ ភគវតា ធម្មោ -ព្រះធម៌ជាធម៌គឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដឹង
ដោយប្រពៃហើយ

ធម្មំ នមស្សាមិ -ខ្ញុំព្រះករុណា នមស្ការនូវព្រះធម៌

សុបដិបន្នោ ភគវតោ សាវកសង្ឃោ-ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ
អង្គនោះ ប្រតិបត្តិដោយប្រពៃហើយ

សង្ឃំ នមាមិ ខ្ញុំព្រះករុណាថ្វាយបង្គំនូវព្រះសង្ឃ ។៕

--++++000++++--

ធម៌នមស្ការព្រះរតនត្រ័យ

អញ្ជើញពួកទេវតា

សមន្តា ចក្កវាឡេសុ អត្រាគច្ឆន្តុ ទេវតា
សទ្ធម្មំ មុនិរាជស្ស សុណន្តុ សគ្គមោក្ខទំ

ទេវតាទាំងឡាយ ក្នុងចក្កវាឡទាំងឡាយដោយជុំវិញ សូមអញ្ជើញ មកប្រជុំគ្នាក្នុងទីនេះ ចូរស្តាប់នូវព្រះសទ្ធម្ម ជាធម៌អាចឲ្យនូវឋានសួគ៌ និងព្រះនិព្វាន របស់ព្រះអនាវរណញ្ញាណ ជាស្តេចនៃអ្នកប្រាជ្ញ ។

រតនត្តយបូជា

(ថ្វាយគ្រឿងសក្ការៈដល់ព្រះរតនត្រៃ)

ឥមេហិ ទីបធូបា ទិសក្ការេហិ ពុទ្ធំ ធម្មំ សង្ឃំ អភិបូជយាមិ
មាតា បិតា ទីនំ គុណវន្តានញ្ច មយ្ហញ្ច ទីឃរត្តំ អត្ថាយ
ហិតាយ សុខាយ ។

ខ្ញុំព្រះករុណាសូមបូជាចំពោះនូវ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាម្ចាស់ ដោយគ្រឿងសក្ការៈទាំងឡាយ មានទានទិនធូបជាដើមនេះ ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់អ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់ខ្ញុំព្រះករុណាផង អស់កាលជាអង្វែងទៅហោង ។

ថ្វាយបង្គំព្រះពុទ្ធគុណ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

វិគ្រោះ នមស្ការ ថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃ ចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។

(សូត្របាលី៣ចប់ សំរាយ១ចប់)

យោ សន្និសិន្នោ វរពោធិមូលេ មារំ សសេនំ មហតឹ វិជេយ្យោ សម្ពោធិមាគច្ឆិ អនន្តញាណោ លោកុត្តមោ តំ បណមាមិ ពុទ្ធំ

ព្រះសម្មាសម្ពុទ្ធអង្គឯណា ទ្រង់គង់ចំរើនទូវព្រះអនាបានស្សតិកម្មដ្ឋានលើរតនបល្ល័ង្ក ក្រោមម្លប់ពោធិព្រឹក្សដ៏ប្រសើរ បានផ្ចាញ់នូវមារាធិរាជព្រមទាំងសេនាដ៏ច្រើន ហើយទ្រង់ត្រាស់ដឹងនូវ សម្មាសម្ពោធិញ្ញាណមានប្រាជ្ញារកទីបំផុតគ្មាន ព្រះអង្គប្រសើរជាងសត្វលោក ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធអង្គនោះ ដោយគោរព ។

យេ ច ពុទ្ធា អតីតា ច យេ ច ពុទ្ធា អនាគតា
បច្ចុប្បន្នា ច យេពុទ្ធា អហំ វន្ទាមិ សព្វទា

ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធនិព្វានកន្លងទៅហើយក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលនឹងបានត្រាស់ជាព្រះពុទ្ធក្នុងកាលខាងមុខក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណាដែលបានត្រាស់ជាព្រះពុទ្ធក្នុងកទ្រកល្បនេះក្តី ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធទាំងឡាយនោះ គ្រប់កាលទាំងពួង ។

(ថ្វាយបង្គំម្តង)

(រំលឹកដល់គុណព្រះនាមទាំង១០)

ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្ម សារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ

ឥតិបិសោ ភគវា អរហំ ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា អរហំ ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវ ពោលគឺកិលេស ព្រមទាំងវាសនា គឺកាយបយោគ និងវចីបយោគ សម្មាសម្ពុទ្ធោ ទ្រង់ព្រះនាមថា សម្មាសម្ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ វិជ្ជាចរណសម្បន្នោ ទ្រង់ព្រះនាមថា វិជ្ជាចរណសម្បន្នោ ព្រោះព្រះអង្គបរិបូណ៌ដោយ វិជ្ជា៣ និងវិជ្ជា៨ និងចរណៈ១៥ សុគតោ ទ្រង់ព្រះនាមថា សុគតោ ព្រោះព្រះអង្គមានដំណើរល្អយាងទៅកាន់ សុន្ទរស្ថាន

គឺអមតមហានិព្វាន **លោកវិទូ** ទ្រង់ព្រះនាមថា **លោកវិទូ** ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក **អនុត្តរោ** ទ្រង់ព្រះនាមថា **អនុត្តរោ** ព្រោះព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន **បុរិសទម្មសារថិ** ទ្រង់ព្រះនាមថា **បុរិសទម្មសារថិ** ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរសដែលមានឧបនិស្ស័យគួរនិងទូន្មានបាន **សត្ថាទេវមនុស្សានំ** ទ្រង់ព្រះនាមថា **សត្ថាទេវមនុស្សានំ** ព្រោះព្រះអង្គជាសាស្តាចារ្យនៃទេវតានិងមនុស្សទាំងឡាយ **ពុទ្ធោ** ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គត្រាស់ដឹងនូវ **ចតុរារិយសច្ច** ហើយញុំាងអ្នកដទៃឱ្យត្រាស់ដឹងផង **ភគវា** ទ្រង់ព្រះនាមថា **ភគវា** ព្រោះព្រះអង្គមានដំណើរទៅកាន់ត្រៃភពខ្ទាក់ចោលហើយគឺថាព្រះអង្គមិនត្រឡប់កើតទៀតឡើយ ។

(ហេតុខ្ញុំដោយពាក្យថា)

នត្ថិ មេ សរណំ អញ្ញំ ពុទ្ធោ មេ សរណំ វរំ
ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ

នត្ថិ មេ សរណំ អញ្ញំ វត្ថុដទៃជាទីពឹងទីរលឹកនៃខ្ញុំព្រះករុណាមិនមានឡើយ **ពុទ្ធោ មេ សរណំ វរំ** មានតែព្រះពុទ្ធជាម្ចាស់ជាទីពឹងទីរលឹកដ៏ប្រសើររបស់ខ្ញុំព្រះករុណា **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** សូមសេចក្តីសួស្តីជ័យមង្គលចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។

(សូមខមាទោសចំពោះព្រះពុទ្ធជាម្ចាស់)

ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ ពុទ្ធេ យោ

ខលិតោ ទោសោ ពុទ្ធោ ខមតុ តំ មមំ

ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវល្អង
ធូលីព្រះបាទ នៃព្រះសម្មាសម្ពុទ្ធដ៏ប្រសើរខ្ពង់ខ្ពស់ដោយអវយវៈដ៏ឧត្តម
គឺត្បូង ពុទ្ធេយោ ខលិតោ ទោសោ ទោសឯណាដែលខ្ញុំព្រះករុណា
ធ្វើឱ្យភ្លាំងភ្លាត់ហើយក្នុងព្រះពុទ្ធជាម្ចាស់ ពុទ្ធោ ខមតុតំ មមំ សូមព្រះ
ពុទ្ធជាម្ចាស់ អត់នូវទោសនោះដល់ខ្ញុំព្រះករុណា ។

(ថ្វាយបង្គំមួង)

ថ្វាយបង្គំព្រះធម្មរតនៈ

អដ្ឋង្គិកាវិយបថោ ជនានំ មោក្ខប្បវេសាយ ឧជូ ច មគ្គោធម្មោ អយំ
សន្តិកពោ បណីតោ និយ្យានិកោតំ បនមាមិ ធម្មំ

ព្រះសទ្ធម្មឯណា ជាធម៌ប្រកបដោយអង្គ៨ប្រការ ជាគន្លងដំណើរនៃ
ព្រះអរិយបុគ្គលជាម្ចាស់ ជាផ្លូវដ៏ត្រង់ ក្នុងកិរិយាញ៉ាំងជនដែលប្រាថ្នា
នូវព្រះនិព្វាន ឲ្យចូលទៅកាន់ព្រះនិព្វានបាន ព្រះធម៌នេះជាធម៌ធ្វើឱ្យ
ត្រជាក់រម្ងាប់បង់នូវភ្លើងទុក្ខភ្លើងកិលេស ជាធម៌ដ៏ឧត្តម ជាគុណញ៉ាំង
សត្វឱ្យចេញចាកសង្សារទុក្ខ ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវ
ព្រះសទ្ធម្មនោះដោយគោរព ។

(ថ្វាយបង្គំមួង)

យេ ច ធម្មា អតីតា ច យេ ច ធម្មា អនាគតា

បច្ចុប្បន្នា ចយេ ធម្មា អហំ វន្ទាមិ សព្វទា

ព្រះធម៌ទាំងឡាយឯណាដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ ដែលនិព្វានកន្លងទៅហើយក្តី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធទីងមានមកក្នុងកាលខាងមុខក្តី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រតិស្ឋានទុកក្នុងកាលសព្វថ្ងៃនេះក្តី ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះធម៌ទាំងឡាយនោះ គ្រប់កាលទាំងពួង ។

(ថ្វាយបង្គំមួង)

(បង្អោនកាយវាចាចិត្តរំលឹកដល់គុណព្រះធម៌ថា)

ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ

ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ

ស្វាក្ខា តោ ភគវតា ធម្មោ ព្រះបរិយត្តិធម៌គឺព្រះត្រៃបិដក ជាធម៌គឺព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សំដែងហើយដោយល្អ **ធម្មោ** ព្រះនព្វលោកុត្តរធម៌មាន៩ប្រការ គឺមគ្គ៤ ផល៤ និព្វាន១ **សន្ទិដ្ឋិកោ**ជាធម៌គឺព្រះអរិយបុគ្គលទាំងពួង ដឹងពិតឃើញពិតដោយ បច្ចវេក្ខណញ្ញាណគឺថា នឹងបានដឹងដោយស្តាប់ដោយជឿបុគ្គលដ៏ទៃនោះៗក៏ទេ គឺឃើញច្បាស់ដោយខ្លួនឯង **អកាលិកោ** ជាធម៌ឲ្យនូវផលមិនរង់ចាំកាលគឺថាកាលបើព្រះអរិយមគ្គកើតឡើងហើយ ព្រះអរិយផលក៏កើតក្នុងលំដាប់

គ្នាមិនបានឃើតយូរឡើយ ឯហិបស្សិកោ ជាធម៌គួរដល់ឯហិបស្សវិធី គឺថាបើព្រះអរិយបុគ្គលដែលបានសំរេចមគ្គផលហើយ ក៏គួរនឹងហៅបុគ្គលដទៃឲ្យចូលមកមើលបាន **ឱបនយិកោ** ជាធម៌គឺព្រះអរិយបុគ្គលគប្បី បង្អោនចូលមកទុកក្នុងខ្លួនដោយអំណាចនៃភាវនា **បច្ចត្តំ វេទិតព្វោ វិញ្ញូហិ** ជាធម៌គឺអ្នកប្រាជ្ញទាំងឡាយ មានឧគ្ឃដិតញ្ញូបុគ្គលជាដើម គប្បីដឹង គប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន ។

(ប្រកាសប្ដេជ្ញាខ្លួនថា)

នត្ថិ មេ សរណំ អញ្ញំ ធម្មោ មេ សរណំ វរំ
ឯតេន សវជ្ជេន ហោតុ មេ ជយមង្គលំ

នត្ថិ មេ សរណំ អញ្ញំ វត្ថុដទៃជាទីពឹងទីរឭកនៃខ្ញុំព្រះករុណាមិនមានឡើយ **ធម្មោ មេ សរណំ វរំ** មានតែព្រះធម៌ជាម្ចាស់ជាទីពឹងទីរឭកដ៏ប្រសើររបស់ខ្ញុំព្រះករុណា **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** សូមសេរីសួស្តីជយមង្គល ចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។

(សូមខមាទោសចំពោះព្រះធម៌)

ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ ធម្មេ យោ
ខលិតោ ទោសោ ធម្មោ ខមតុ តំ មមំ

ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំវំ ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះធម៌ដ៏ប្រសើរមានពីរប្រការ គឺព្រះបរិយត្តិធម៌ និងព្រះនព្វលោកុត្តរធម៌ ដោយអវយវៈដ៏ឧត្តមគឺត្បូង ធម្មេយោ ខលិតោ ទោសោ ទោសឯណាដែលខ្ញុំព្រះករុណាបានធ្វើឲ្យភ្លាំងភ្លាត់ហើយ ក្នុងព្រះធម៌ជាម្ចាស់ ធម្មោ ខម តុតំ មមំ សូមព្រះធម៌ជាម្ចាស់អត់នូវ ទោសនោះដល់ខ្ញុំព្រះករុណា ។

(ថ្វាយបង្គំម្តង)

ថ្វាយបង្គំព្រះសង្ឃរតនៈ

សង្ឃោ វិសុទ្ធោ វរទក្ខិណេយ្យោ សន្តិន្ទ្រិយោ សព្វមលប្បហីនោ
គុណេហិនេកេហិ សមិទ្ធិបត្តោ អនាសវោ តំ បនមាមិ សង្ឃំ ។

ព្រះអរិយសង្ឃឯណាដ៏បរិសុទ្ធវិសេស ជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ មានឥន្ទ្រិយរំងាប់ហើយ មានមន្ទិលគឺរាគាទិក្កិលេសទាំងពួង បង្វាត់បង់ហើយ ជាព្រះសង្ឃដល់ហើយ នូវកិរិយាសំរេចដោយគុណ ទាំងឡាយដ៏ច្រើន ជាព្រះសង្ឃមានអាសវធម៌ មិនមាន គឺថាជាព្រះខីណាស្រព ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះអរិយសង្ឃនោះដោយគោរព ។

យេ ច សង្ឃា អតីតា ច យេ សង្ឃា អនាគតា
បច្ចុប្បន្នា ច យេ សង្ឃា អហំ វន្ទាមិ សព្វទា

ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃ បានសំរេចមគ្គនិងផល កន្លងទៅហើយក្តី ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃ នឹងបានសំរេចមគ្គនិងផលក្នុងកាលខាងមុខក្តី ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃ បានសំរេចមគ្គនិងផល ក្នុងកាលជាបច្ចុប្បន្ននេះក្តី ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសង្ឃទាំងឡាយនោះ គ្រប់កាលទាំងពួង ។

(ថ្វាយបង្គំមួង)

(បង្អោនកាយវាចារំលឹកដល់គុណព្រះសង្ឃ)

សុបដិបន្នោ ភគវតោ សាវកសង្ឃោ ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋបុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។

សុបដិបន្នោ ភគវតោ សាវក សង្ឃោ ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដ៏ប្រពៃ គឺប្រតិបត្តិតាមគន្លងព្រះនព្វលោកុត្តរធម៌ **ឧជុ បដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយត្រង់ គឺប្រតិបត្តិជាមជ្ឈិមបដិបទា **ញាយ បដិបន្នោ ភគវតោ**

សាវកសង្ឃោ ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ជាស្ពានក្បៀមផុតចាកទុក្ខទាំងពួង **សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សមគួរដល់សាមីចិកម្ម គឺប្រតិបត្តិគួរដល់ សីល សមាធិ បញ្ញា **យទិទំ ចត្តារិ បុរិសយុគានិ** ព្រះសង្ឃឯណាបើរាប់ជាគូនៃបុរសទាំងឡាយមានបួនគូ គឺព្រះសង្ឃដែលបានសំរេចនូវ សោតាបត្តិមគ្គនិងសោតាបត្តិផលជាគូ១ សកទាគាមិមគ្គនិងសកទាគាមិផលជាគូ១ អនាគាមិមគ្គនិងអនាគាមិផលជាគូ១ អរហត្តមគ្គនិងអរហត្តផលជាគូ១ **អដ្ឋបុរិសបុគ្គលា** បើរាប់រៀងជាបុរសបុគ្គលមាន៨គឺព្រះសង្ឃដែលបានសំរេចនូវ សោតាបត្តិមគ្គ១សោតាបត្តិផល១ សកទាគាមិមគ្គ១សកទាគាមិផល១ អនាគាមិមគ្គ១អនាគាមិផល១ អរហត្តមគ្គ១អរហត្តផល១ **ឯសភគវតោ សាវកសង្ឃោ** ព្រះសង្ឃទាំងនោះ ជាសង្ឃសាវកនៃព្រះដ៏មានព្រះភាគ **អាហុនេយ្យោ** លោកគួរទទួលនូវចតុប្បច្ច័យ ដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីល ហើយនាំមកអំពីចម្ងាយបង្អោនចូលមកបូជា **បាហុនេយ្យោ** លោកគួរទទួលនូវអគន្តុកទាន គឺទានដែលបុគ្គលតាក់តែងដើម្បីញាតិនិងមិត្ត ដែលមកអំពីទិសផ្សេងៗ ហើយបង្អោនចូលមកបូជា **ទក្ខិណេយ្យោ** លោកគួរទទួលនូវទាន ដែលបុគ្គលជឿនូវកម្ម និងផលនៃកម្មហើយបូជា **អញ្ជលិករណីយោ** លោកគួរដល់អញ្ជលិកម្ម ដែលសត្វលោកគប្បីធ្វើ **អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស** លោកជាបុញ្ញក្ខេត្ត គឺជាទីដុះឡើងនៃពូជគឺបុណ្យនៃសត្វលោក រកខេត្តដ៏ទៃក្រៃលែងជាងគ្មាន ។

(ប្រកាសបេក្ខជាខ្ទួនថា)

នត្ថិ មេ សរណំ អញ្ញំ សង្ឃោ មេ សរណំ វរំ

ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ

នត្ថិ មេ សរណំ អញ្ញំ វត្ថុដទៃជាទីពឹងទីរឭកនៃខ្ញុំព្រះករុណាមិនមានឡើយ សង្ឃោ មេ សរណំ វរំ មានតែព្រះសង្ឃជាម្ចាស់ជាទីពឹងទីរឭកដ៏ប្រសើររបស់ខ្ញុំព្រះករុណា ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ សូមសេរីសួស្តីជ័យមង្គល ចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។

(សូមខមាទោសចំពោះព្រះសង្ឃ)

ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ សង្ឃេ យោ

ខលិតោ ទោសោ សង្ឃោ ខមតុ តំ មមំ

ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះសង្ឃដ៏ប្រសើរ មានពីរប្រការគឺ សម្មតិសង្ឃ និងអរិយសង្ឃ ដោយអវយវៈដ៏ឧត្តមគឺត្បូង សង្ឃេ យោ ខលិតោ ទោសោ ទោសឯណាដែលខ្ញុំព្រះករុណា ធ្វើឲ្យភ្លាំងភ្លាត់ហើយ ក្នុងព្រះសង្ឃជាម្ចាស់ សង្ឃោ ខមតុ តំ មមំ សូមព្រះសង្ឃជាម្ចាស់អត់នូវទោសនោះដល់ខ្ញុំព្រះករុណា ៕

(ក្រាបថ្វាយបង្គំម្តង)

យោ កប្បកោដីហិបិ អប្បមេយ្យំ កាលំ ករោន្តោ អតិទុក្ករានិ ខេទំ គតោ លោកហិតាយ នាថោ នមោ មហាការុណិកស្ស តស្ស ។

ព្រះពុទ្ធជាទីពឹង ជាពុំនឹងសព្វសត្តា
ព្រះអង្គកាលប្រាថ្នា ធ្វើកសាងអស់កាលយូរ
រាប់ដោយកោដិកប្បា ច្រើនគណនាហួសគិតគូរ
បានត្រាស់ជាសព្វញ្ញូ ត្រាស់ជាគ្រូលើកពស្ដាន
ធ្វើកម្មជាកម្រ សត្វនិករត្រាប់ពុំបាន
នឿយហាត់លំបាកប្រាណ ព្រោះប្រយោជន៍ដល់សព្វសត្វ
ខ្ញុំសូមឱនសិរសា ចិត្តប្រាថ្នាបង្គំថ្វាត់
ព្រះពុទ្ធករុណាសត្វ នោះជាទីពឹងសព្វកាល

អសម្ពុទ្ធំ ពុទ្ធនិសេវិតំ យំ ភវាភវំ គច្ឆតិ ជីវលោកោ នមោ អវិជ្ជាទិក្កិលេស ជាលំ វិទ្ធំសិនោ ធម្មវរស្ស តស្ស

សត្វតែងកើតស្លាប់បង់ ព្រោះចំណង់កម្មជាគោល
ឱយវិលវល់អន្ទោល ក្នុងភពតូចនិងភពធំ
ហេតុតែមិនដឹងធម៌ បរិសុទ្ធល្អស្អាតសុខុម
ព្រះពុទ្ធតែងផ្សែផ្សំ ចិត្តខ្ញុំសូមនមស្ការ
នូវធម៌ប្រពៃពិត វិសេសសុទ្ធនោះឯងណា
កាត់បង់នូវអវិជ្ជា គឺបណ្ដាញកិលេសហើយ

គុណេហិ យោ សីលសមាធិ បញ្ញា វិមុត្តិញ្ញាណប្បកុតីហិយុត្តោ
ខេត្តញ្ចនាន់ កុសលត្ថិកាន់ តមរិយសង្ឃំ សិរសា នមាមិ

ព្រះសង្ឃអគ្គសាវក មានសំវរៈដ៏ផូរផង់
កបដោយគុណសីលត្រង់ គឺសមាធិបញ្ញា
និងវិមុត្តិញ្ញាណ កិលេសគ្មានក្នុងអាត្មា
ជាបុញ្ញក្ខេត្តា ជនត្រូវការជាកុសល
ខ្ញុំសូមឱនសិរសី ដល់ព្រះអរិយបុគ្គល
ជាបុត្រព្រះទសពល ជាមង្គលដល់សព្វសត្វ

ឥច្ចេវមច្ចន្ត នមស្សនេយ្យំ នមស្សមានោ រតនត្តយំ យំ
បុញ្ញាភិសន្ទំ វិបុលំ អលត្ថំ តស្សានុភាវេន ហតន្តរាយោ

ខ្ញុំសូមនមស្ការ លើកហត្ថាឱនសិរសី
បង្គំគុណទាំងបី ខ្ពស់លើសលប់ត្រៃលោកា
សូមបុណ្យកងកុសល ឲ្យបានដល់យើងខ្ញុំណា
ពេញពោរស្មើធារា ដូចជលសារធំទូលាយ
សូមឲ្យកំចាត់បង់ អពមង្គលទាំងឡាយ
ឲ្យចៀសចេញចាកឆ្ងាយ ក្តីអន្តរាយកុំបីមាន
ដោយកម្លាំងអានុភាព បុញ្ញលាភជាប្រធាន
កងបុណ្យរាសីមាន សូមបានក្សាន្តកុំមានមោះ
ដោយគុណនមស្សការ ត្រៃរតនាប្រសើរខ្ពស់
សូមអានិសង្សនោះ ជាក់ដល់ស្ថាននិព្វានហោង ។

ពុទ្ធបាទនមស្សការគាថា

ប្រែជាកាព្យ

វន្ទាមិ ពុទ្ធំ ភវបារតិណ្ណំ តិលោកកេតុំ តិភវេកនាថំ យោ លោកសេដ្ឋោ សកលំ កិលេសំ ឆេត្វាន ពោធេសិ ជនំ អនន្តំ ។

ព្រះសព្វញ្ញុពុទ្ធ វិសេសផុតត្រៃលោកា
គ្មានមនុស្សឬទេវតា ព្រហ្មមារណាប្រដូចបាន ។
កំចាត់នូវកិលេស គ្មានឲ្យសេសនៅសល់ខាន
ញុំាងជនទាំងប៉ុន្មាន ជាអានន្តឲ្យត្រាស់ដឹង ។
ខ្ញុំសូមថ្វាយបង្គំ នូវព្រះបរមជាទីពឹង
ព្រះអង្គឆ្លងផុតស្ទឹង បានដល់ច្រាំងនៃភពហើយ ។
ព្រះអង្គជាទង់ជ័យ ធំត្រៃឈៃបង្ហាញត្រើយ
តែមួយព្រះអង្គហើយ ជាទីពឹងក្នុងត្រៃភព ។
មារព្រហ្មទាំងទេវតា និងមនុស្សតែងគោរព
ចូលជ្រកនៅក្រោមម្លប់ ពោធិញ្ញាណបានសុខា ។

យំ នម្មទាយ នទិយា បុលិនេ ច តីរេ យំ សច្ចពន្ធគិរិកេ សុមនាចលគ្គេ យំ តត្ថ យោនកបុរេ មុនិនោ ច បាទំ តំ បាទលញ្ឆនមហំ សិរសា នមាមិ ។

សូមថ្វាយបង្គំ ទសករប្រណម
ឆ្ពោះត្រង់ស្នាមព្រះបាទា ដែលព្រះមានជោគ ។

ទ្រង់ព្រះមេត្តា ដាន់ទុកឲ្យជាស្ថានថ្លៃ
បាទមួយនៅនា ស្ទឹងនម្មទា ។
ត្រង់ឆ្នេរខ្សាច់ប្រសើរក្រៃ បាទមួយទ្រង់ដាន់
ទុកនៅព្ធ-ដីភ្នំគីរីសច្ចព័ន្ធ បាទមួយនៅភ្នំ ។
សុមនកូដ រហូតកំពូលដីសោភ័ណ
ព្រះបាទមួយទៀត ព្រះទ្រង់ដាន់ទុក
នៅនាយោនកបុរី ខ្ញុំសូមបន្ទន់ ។
កាយវាចា និងចិត្តជ្រះថ្លាឧនសិរសី
បង្គំព្រះបាទព្រះជិនស្រី សូមសុខសួស្តីគ្រប់វេលា ។

សុវណ្ណមាលិកេ សុវណ្ណបព្វតេ សុមនកូដេ
យោនកបុរេ នម្មទាយ នទិយា បញ្ចបាទវរំ ឋានំ
អហំ វន្ទាមិ ទុរតោ

ខ្ញុំសូមនមស្ការអំពីចម្ងាយ នូវឋានទាំងឡាយដែលមានព្រះបាទ
ទាំងប្រាំកន្លែងដែលព្រះមុនីនាថទ្រង់ឈានព្រះបាទលើកំពូលភ្នំ ។
សុវណ្ណមាលិកមួយនោះជាធំ មួយនៅលើភ្នំសុវណ្ណបព៌ត
មួយនៅលើភ្នំសុមនកូដប្រាកដ មួយនៅរាជវង្សយោនកបុរី ។
មួយនៅក្បែរស្ទឹងនម្មទាជលធី ទាំងប្រាំនាទីដែលទ្រង់ប្រទាន
ទុកឲ្យសព្វសត្វប្រតិបត្តិជាស្ថាន ដោយព្រះទ្រង់ញាណប្រទានទុកឲ្យ។

ថ្វាយបង្គំព្រះបាទ

វន្ទាមិ ពុទ្ធំ ភវបារតិណ្ណំ តិលោកកេតុំ តិភវេកនាថំ យោ លោក សេដ្ឋោ សកលំ កិលេសំ ឆេត្វាន ពោធេសិ ជនំអនន្តំ

ព្រះសម្មាសម្ពុទ្ធអង្គឯណា ព្រះអង្គប្រសើរក្នុងលោក ទ្រង់កាត់បង់នូវកិលេសទាំងអស់បានហើយ ញ៉ាំងជនជាអានន្តឲ្យត្រាស់ដឹងហើយ ខ្ញុំសូមក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធនោះ ព្រះអង្គឆ្លងផុតអំពីច្រាំងនៃភពហើយ ព្រះអង្គជាទង់ជ័យនៃត្រៃលោក មានតែព្រះអង្គមួយជាទីពឹងនៃសព្វសត្វក្នុងត្រៃភព ។

យំ នម្មទាយ នទិយា បុលិនេ ច តីរេ យំ សច្ចពន្ធគិរិកេ សុមនា ចលគ្គេ យំ តត្ថ យោនកបុរេ មុនិនោ ច បាទំ តំ បាទលញ្ឆ នមហំ សិរសា នមាមិ

ស្នាមព្រះបាទឯណា ដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក លើផ្ទូរខ្សាច់ទៀបឆ្នេរនៃស្ទឹងឈ្មោះនម្មទា ស្នាមព្រះបាទឯណាដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុកលើភ្នំសច្ចពន្ធ និងលើភ្នំសុមនកូដ ស្នាមព្រះបាទឯណាដែលព្រះសម្ពុទ្ធ ទ្រង់ប្រតិស្ឋានទុកក្នុងយោនកបុរី ខ្ញុំសូមក្រាបថ្វាយបង្គំដោយត្បូងចំពោះទៅព្រះបាទ និងស្នាមព្រះបាទទាំងនោះ នៃព្រះសក្យមុនី ។

សុវណ្ណមាលិកេ សុវណ្ណបព្វតេ សុមនកូដេ យោនកបុរេ
នម្មទាយ នទិយា បញ្ចបាទវរំ ឋានំ អហំ វន្ទាមិ ទូរតោ

ខ្ញុំសូមនមស្ការអំពីចម្ងាយ នូវស្ថានដែលមានព្រះបាទ ដ៏ប្រសើរ៥ កន្លែង គឺស្ថានលើភ្នំសុវណ្ណមាលិក១ លើភ្នំសុវណ្ណបព៌ត១ លើភ្នំសុមនកូដ១ ក្នុងយោនកបុរី១ ក្បែរស្ទឹងនម្មទា១ ។

(ថ្វាយបង្គំព្រះសារីរិកធាតុ)

វន្ទាមិ ចេតិយំ សព្វំ សព្វដ្ឋានេសុ បតិដ្ឋិតំ សារីរិកធាតុ
មហាពោធឹ ពុទ្ធរូបំ សកលំ សទា

ខ្ញុំសូមថ្វាយបង្គំ ធ្លោះព្រះបរមចេតិយ
ព្រមទាំងព្រះសារី រិកធាតុនៃព្រះពុទ្ធ ។
និងមហាពោធិព្រឹក្ស ដែលគួរនឹកដោយលំអុត
លំអោនចិត្តបរិសុទ្ធ លើកកំបង់អញ្ជលី ។
និងព្រះពុទ្ធរូប ជំណាងអង្គព្រះមុនី
ដែលស្ថិតនៅគ្រប់ទី ស្ថាននានាគ្រប់ទាំងអស់ ។
ដោយតេជៈនៃគុណ ព្រះមានបុណ្យប្រសើរខ្ពស់
ដែលតែងតែរំលោះ រំដោះទុក្ខភ័យអន្តរាយ ។
សូមឲ្យខ្ញុំបានសុខ ឃ្លាតចាកទុក្ខផងទាំងឡាយ
សត្រូវទោះជិតឆ្ងាយ សូមឲ្យក្លាយមកជាមិត្ត
សូមទាន់ព្រះអរិយ មេត្រីយថ្លៃវិសិដ្ឋ
សូមបានឃើញធម៌ពិត សមដូចចិត្តប្រាថ្នាហោង ។

ផ្សាយមេត្តាចំពោះទិសទាំង ១០

សព្វេ បុរត្ថិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ
សព្វេ បុរត្ថិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ
សព្វេ ទក្ខិណាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ
សព្វេ ទក្ខិណាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ
សព្វេ បច្ឆិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ
សព្វេ បច្ឆិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ
សព្វេ ឧត្តរាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ
សព្វេ ឧត្តរាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ
សព្វេ ហេដ្ឋិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ
សព្វេ ឧបរិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ
សព្វេ សត្តា អវេរា ហោន្តុ សុខិតា ហោន្តុ និទ្ទុក្ខា ហោន្តុ
អព្យាបជ្ឈា ហោន្តុ អនីឃា ហោន្តុ ទីឃាយុកា ហោន្តុ អរោគា
ហោន្តុ សម្បត្តីហិ សមិជ្ឈន្តុ សុខី អត្តានំ បរិហរន្តុ ។
ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា សោកប្បត្តា
ច និស្សោកា ហោន្តុ សព្វេបិ បាណិនោ ។

សត្វទាំងឡាយទាំងពួង ដែលដល់ហើយនូវសេចក្តីទុក្ខ សូមឲ្យជាសត្វ
បាត់សេចក្តីទុក្ខទៅ ដែលដល់ហើយនូវភ័យ សូមឲ្យជាសត្វបាត់ភ័យទៅ
ដែលដល់ហើយនូវសេចក្តីសោក សូមឲ្យជាសត្វបាត់សេចក្តី
សោកទៅ ។

---+++000+++---

++សត្វទាំងឡាយទាំងពួង ក្នុងទិសបូព៌ - ទិសអគ្នេយ៍ - ទិសទក្សិណ
-ទិសនិរតី-ទិសបច្ចឹម-ទិសពាយ័ព្យ-ទិសឧត្តរ-ទិសឦសាន-ទិសខាងក្រោម
-ទិសខាងលើ សូមកុំឲ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។
++សូមឲ្យសត្វទាំងឡាយទាំងពួង-កុំមានពៀរនឹងគ្នា-សូមឲ្យបាននូវសេចក្តីសុខ
-សូមកុំឲ្យមានទុក្ខ -សូមកុំឲ្យបៀតបៀនដល់គ្នានឹងគ្នា -សូមកុំឲ្យមានសេចក្តី
ព្រួយលំបាក -សូមឲ្យមានអាយុវែង -សូមកុំឲ្យមានរោគ -សូមឲ្យសំរេច
ដោយសម្បត្តិគ្រប់យ៉ាង -សូមឲ្យរក្សានូវខ្លួនជាសុខស្រួលចុះ ។
++សត្វទាំងឡាយទាំងពួង-ដែលដល់ហើយនូវសេចក្តីទុក្ខ សូមឲ្យជាសត្វបាត់
សេចក្តីទុក្ខទៅ -ដែលដល់ហើយនូវភ័យ សូមឲ្យជាសត្វបាត់ភ័យទៅ
-ដែលដល់ហើយនូវសេចក្តីសោក សូមឲ្យជាសត្វបាត់សេចក្តីសោកទៅ ៕៚

------++++++-------

++ពួកសត្វទាំងអស់ក្នុង-ទិសបូព៌-ទិសអគ្នេយ៍-ទិសទក្សិណ-ទិសនិរតី-ទិសបច្ចឹម
-ទិសពាយ័ព្យ-ទិសឧត្តរ-ទិសឦសាន-ទិសខាងក្រោម-ទិសខាងលើ សូមឲ្យជា
សត្វមិនមានពៀរនឹងគ្នា សូមឲ្យមានតែសេចក្តីសុខជានិច្ចនិរន្តរ៍តទៅ ។
++ពួកសត្វទាំអស់សូមកុំមានពៀរនឹងគ្នា សូមឲ្យបានតែសេចក្តីសុខ ឲ្យប្រាសចាកទុក្ខ
កុំព្យាបាទគ្នា កុំមានសេចក្តីព្រួយចំបែង សូមឲ្យមានអាយុវែង កុំឲ្យមានរោគ សូម
ឲ្យសំរេចដោយសម្បត្តិទាំងឡាយ សូមរក្សានូវខ្លួនឲ្យជាសុខតរៀងទៅ ។
++សត្វទាំងឡាយទាំងពួងដែលដល់ហើយនូវសេចក្តីទុក្ខ សូមឲ្យជាសត្វបាត់សេចក្តីទុក្ខទៅ
ដែលដល់ហើយនូវភ័យ សូមឲ្យជាសត្វបាត់ភ័យទៅ ដែលដល់ហើយនូវសេចក្តីសោក
សូមឲ្យជាសត្វបាត់សេចក្តីសោកទៅ ៕៚

បត្តិទានគាថា (យា ទេវតា)

យា ទេវតា សន្តិ វិហារវាសិនី
ថូបេ ឃរេ ពោធិឃរេ តហឹ តហឹ
តា ធម្មទានេន ភវន្តុ បូជិតា
សោត្ថឹ ករោន្តេធ វិហារមណ្ឌលេ
ថេរា ច មជ្ឈា នវកា ច ភិក្ខវោ
សារាមិកា ទានបតី ឧបាសកា
គាមា ច ទេសា និគមា ច ឥស្សរា
សប្បាណភូតា សុខិតា ភវន្តុ តេ
ជលាពុជា យេបិ ច អណ្ឌសម្ភវា
សំសេទជាតា អថោបបាតិកា
និយ្យានិកំ ធម្មវរំ បដិច្ច តេ
សព្វេបិ ទុក្ខស្ស ករោន្តុ សំខយំ
ឋាតុ ចិរំ សតំ ធម្មោ ធម្មធរា ច
បុគ្គលា សង្ឃោ ហោតុ សមគ្គោវ
អត្ថាយ ច ហិតាយ ច អម្ហេ រក្ខតុ សទ្ធម្មោ
សព្វេបិ ធម្មចារិនោ វុឌ្ឍឹ សម្បាបុណេយ្យាម
ធម្មារិយប្បវេទិតេ ។

យើងខ្ញុំទាំងអស់គ្នា សូមបូជាដោយធម្មទាន
ដល់ទេវតាដែលមាន នៅទីស្ថានវត្តនេះក្តី ។

នាខឿនព្រះសថូប ឬនៅនាខឿនចេតិយ
សូមមានចិត្តមេត្រី ធ្វើទឹកដីទីវត្តនេះ ។
សូមឲ្យសុខសួស្តី ទុក្ខអ្វីៗកុំមានមោះ
ម្យ៉ាងទៀតសង្ឃទាំងអស់ ដែលមានផ្នួសជាថេរៈ ។
ឬក៏ជាមជ្ឈិម ឬនៅត្រឹមជាន់នវៈ
ឬក៏ឧបាសក ដែលអ្នកជាម្ចាស់នៃទាន ។
ព្រមទាំងអ្នកនិគម ឬអ្នកជំអម្បាលមាណ
គ្រប់ស្រុកប្រទេសស្ថាន សូមឲ្យបានសុខឯកអគ្គ ។
ម្យ៉ាងទៀតសត្វឯណា ដែលកើតជាជលាពុជៈ
ឬក៏អណ្ឌជៈ សំសេទជៈកំណើតក្តី ។
ឬក៏ឧបបាតិកៈ គ្រប់ៗថ្នាក់ក្នុងលោកិយ
ដោយអំណាចសេចក្តី ធម៌បាលីដ៏បវរ ។
កុំឲ្យមានទុក្ខសោក ក្តីវិយោគសង្សារចរ
ម្យ៉ាងទៀតសូមឲ្យធម៌ ព្រះបវរស្ថិតនៅវែង ។
ទីងអ្នកចេះធម្មំ សូមឲ្យតាំងនៅអង្វែង
និងសូមឲ្យតម្កើង សង្ឃម៉ឺនសែនសាមគ្គីធម៌ ។
ដើម្បីប្រយោជន៍ច្រើន និងចំរើនកុសលធម៌
សូមឲ្យធម៌បវរ ជួយគាំទ្រយើងគ្រប់គ្នា ។
ហើយសូមអស់យើងខ្ញុំ ចេះចាំគ្រប់កងធម្មា
ដែលអង្គព្រះភគវា ទ្រង់ទេសនាតាំងទុកមក

គាថាសូមសេចក្ដីសុខ

អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា
បុញ្ញំ តំ អនុមោទិត្វា ចិរំ រក្ខន្តុ សាសនំ ។
ពពួកទេវតានិងនាគ ស្ថិតនៅភាគភូមិផែនដី ឬលើអាកាសក្ដី
មានសេរីដ៏ឧត្ដម សូមអនុមោទនា នូវបុណ្យជារបស់ខ្ញុំ
ហើយសូមជួយថែទាំ នូវពុទ្ធសាសនា អស់កាលវែង ។

អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា
បុញ្ញំ តំ អនុមោទិត្វា ចិរំ រក្ខន្តុ រាជានោ ។
ពពួកទេវតានិងនាគ ស្ថិតនៅភាគភូមិផែនដី ឬលើអាកាសក្ដី
មានសេរីដ៏ឧត្ដម សូមអនុមោទនា នូវបុណ្យជារបស់ខ្ញុំ
ហើយសូមជួយថែទាំ នូវព្រះមហាក្សត្រ អស់កាលវែង ។

អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា
បុញ្ញំ តំ អនុមោទិត្វា ចិរំ រក្ខន្តុ ញាតយោ
ពពួកទេវតានិងនាគ ស្ថិតនៅភាគភូមិផែនដី ឬលើអាកាសក្ដី
មានសេរីដ៏ឧត្ដម សូមអនុមោទនា នូវបុណ្យជារបស់ខ្ញុំ
ហើយសូមជួយថែទាំ នូវក្រុមញាតិ អស់កាលវែង ។

អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា
បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ បាណិនោ
រីទេវតានិងនាគ ស្ថិតនៅភាគភូមិផែនដី ឬលើអាកាសក្តី
មានសេរីដ៏ឧត្តម សូមអនុមោទនា នូវបុណ្យជារបស់ខ្ញុំ
ហើយសូមជួយថែទាំ នូវពួកសត្វ អស់កាលវែង ។
អកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា
បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ នោ សទា
រីទេវតានិងនាគ ស្ថិតនូវភាគភូមិផែនដី ឬលើអាកាសក្តី
មានសេរីដ៏ឧត្តម សូមអនុមោទនា នូវបុណ្យជារបស់ខ្ញុំ
ហើយសូមជួយថែទាំ នូវយើងខ្ញុំ អស់កាលវែង

បត្តិទានគាថា

យំ កិញ្ចិ កុសលកម្មំ កត្តព្វំ កិរិយំ មម
កាយេន វាចាមនសា ទិទសេ សុគតំ កតំ
យេ សត្តា សញ្ញិនោ អត្ថិ យេ ច សត្តា អសញ្ញិនោ
កតំ បុញ្ញផលំ មយ្ហំ សព្វេ ភាគី ភវន្តុ តេ
យេតំ កតំ សុវិទិតំ ទិន្នំ បុញ្ញផលំ មយា
យេ ច តត្ថ ន ជានន្តិ ទេវា គន្ត្វា និវេទយុំ
សព្វេ លោកម្ហិ យេ សត្តា ជីវន្តា ហារហេតុកា
មនុញ្ញំ ភោជនំ សព្វេ លភន្តុ មម ចេតសាតិ ។

យំកិញ្ចិ កុសលកម្មំ កត្តព្វំ កិរិយំ មម អំពើជាកុសលឯណាមួយ ដែលខ្ញុំគប្បីធ្វើ **កាយេន វាចា មនសា** ដោយទ្វារទាំងបី គឺកាយ វាចា ចិត្ត **ទិវសេ សុគតំ កតំ** អំពើជាកុសលទាំងអស់នោះដែលខ្ញុំបានធ្វើហើយ ជាកុសលអាចនឹងនាំឲ្យទៅកើតក្នុងស្ថានត្រៃត្រឹងស្រួគ៌បាន **យេ សត្តាសញ្ញិនោ អត្ថិ** សត្វទាំងឡាយឯណាគឺមនុស្ស ឬ ទេវតា ឬព្រហ្ម ដែលជាសត្វមានសញ្ញាក្តី **យេ ច សត្តា អសញ្ញិនោ** សត្វទាំងឡាយឯណា ជាអសញ្ញិសត្វ គឺសត្វដែលឥតសញ្ញាក្តី **កតំ បុញ្ញផលំ មយ្ហំ សព្វេ ភាគី ភវន្តុ តេ** សត្វទាំងឡាយទាំងអស់នោះ ចូរឲ្យបាននូវចំណែកផលនៃបុណ្យ ហើយចូរសោយនូវផលនៃបុណ្យដែលខ្ញុំបានធ្វើហើយ បានឧទ្ទិសផ្សាយឲ្យទៅនេះចុះ **យេតំ កតំ សុវិទិតំ ទិន្នំ បុញ្ញផលំ មយា** បុណ្យដែលខ្ញុំបានធ្វើហើយនោះ បើសត្វទាំងឡាយឯណា បានដឹងច្បាស់ហើយ សត្វទាំងឡាយនោះ ចូរឲ្យបានសោយនូវផលនៃបុណ្យ ដែលខ្ញុំបានឧទ្ទិសឲ្យទៅនោះចុះ **យេ ច តត្ថ ន ជានន្តិ** ម៉្យាងទៀតបណ្តាអស់សត្វទាំងនោះ បើសត្វទាំងឡាយឯណាមិនបានដឹងនូវបុណ្យ ដែលខ្ញុំបានធ្វើហើយនោះ **ទេវា គន្ត្វា និវេទយុំ** សូមទេវតាទាំងឡាយអញ្ជើញទៅឲ្យដំណឹង ដល់សត្វទាំងឡាយនោះ ឲ្យបានដឹងថា ជនឯណោះគេបានធ្វើបុណ្យ ហើយគេឧទ្ទិសផ្សាយផលបុណ្យនោះ មកដល់អ្នកទាំងឡាយៗ ចូរអនុមោទនាត្រេកអរនឹងបុណ្យគេនោះចុះ **សព្វេ លោកម្ហិ យេ សត្តា** ជីវន្តាហារហេតុកាសត្វទាំងឡាយឯណាក្នុងលោក

ទាំងអស់ ដែលអាស្រ័យនូវអាហារហើយរស់នៅ មនុញ្ញំ ភោជនំ សពេ្វ លភន្តុ មម ចេតសាតិ សត្វទាំងឡាយទាំងអស់នោះ ចូរឲ្យបាននូវភោជនជាទីគាប់ចិត្ត ដែលសំរេចដោយបុញ្ញឫទ្ធិ តាមចិត្តដែលខ្ញុំឧទ្ទិសផ្សាយទៅឲ្យនេះចុះ ៕

(យំកិញ្ចិ ប្រែជាពាក្យកាព្យ)

កម្មជាកុសលឯណា　　ដែលជាការឥតសៅហ្មង
យើងខ្ញុំបានកសាង　　ដោយកាយវាចាចិត្តពិត ។
កុសលទាំងអស់នោះ　　អាចជួយដោះជួយបង្ខិត
នាំសត្វឲ្យជាប់ចិត្ត　　ស្ថិតនៅនាស្ថានឧត្តម ។
សត្វណាមានសញ្ញា　　គឺទេវតាមនុស្សឬព្រហ្ម
ដែលមានសក្តិតូចធំ　　ព្រមទាំងសត្វឥតសញ្ញា ។
សូមបានចំណែកបុណ្យ　　ដែលជាគុណល្អថ្លៃថ្លា
យើងខ្ញុំបានរចនា　　ចាត់ចែងការកុសលហ្នឹង ។
ម្យ៉ាងទៀតសត្វឯណា　　ឆ្ងាយអស្ចារ្យពុំបានដឹង
ទេវតាជាពុំនឹង　　ឲ្យដំណឹងយ៉ាងនេះថា ។
នរជននៅឯណោះ　　ស្រីឬប្រុសបានជ្រះថ្លា
កសាងបុញ្ញកិរិយា　　វត្តជាផ្លូវកើតឆាយ ។
ហើយគេឧទ្ទិសផល　　ឲ្យបានដល់អ្នកទាំងឡាយ

ចូរមានចិត្តស្រស់ស្រាយ បន្ទន់កាយទទួលយក ។
សត្វលោកទាំងអស់នោះ ដែលបានរស់តរៀងមក
ដោយបានបរិភោគ នូវអាហារទើបរស់បាន ។
សត្វទាំងអស់នោះណា បានសុខាសព្វគ្រប់ប្រាណ
អាហារយ៉ាងចំណាន សូមឲ្យបានកុំខានឡើយ ៕

គេជះខ្ញុំសាង

គេជះខ្ញុំសាង សំអិតសំអាង ឱនកាយវាចា សូមសុខសុភាព
រួបពីទុក្ខ ធ្វងដល់ត្រើយមហា ពោលគឺនិព្វាន ។
គ្រប់ជាន់គ្រប់ជាតិ កុំឲ្យខ្ញុំឃ្លាត ពីសីលនិងទាន គំនិតយល់ត្រូវ
តាមផ្លូវនិព្វាន មគ្គផលជាស្ពាន ដល់ស្ថានថ្លៃថ្លា ។
សូមជូនមគ្គផល ចំពោះទៅដល់ មាតាបិតា គុណគ្រូឧបជ្ឈា
យាចារ្យ គុណញាតិកា ប្រាំពីរសន្តាន ។
ជីដូនជីតា រស់នៅក្តីណា លោកម្ចាស់ចែកស្ថាន សូមជូន
មគ្គផល កុសលថ្កើងថ្កាន សូមសុខក្សេមក្សាន្ត ដល់ស្ថានផុតទុក្ខ ៕

បត្តិទានគាថា

--+++000+++--

ទានសីលខ្ញុំធ្វើហើយ　　ព្រះគុណ្ហើយខ្ញុំសច្ចា
ឧទ្ទិសផលនេះណា　　ជូនមាតាបិតាខ្ញុំ ។
ជីដូននិងជីតា　　គ្រូអាចារ្យទាំងតូចធំ
ញាតិមិត្តគ្រប់និគម　　មកជួបជុំទទួលផល ។
ដែលកូនចៅបានធ្វើ　　នូវអំពើជាកុសល
សូមទានឲ្យបានដល់　　ទោះមណ្ឌលឆ្ងាយយ៉ាងណា ។
កុសលទាំងអស់ហ្នឹង　　សូមទីពឹងលើទេវតា
សូមមានចិត្តមេត្តា　　នាំផល្លាទាំងអស់នេះ ។
នៅជូនឲ្យខ្ញុំផង　　ដូចបំណងកុំបីធ្វេស
កូនចៅនៅឯណោះ　　មិនប្រហែសបញ្ជូនមក ។
សូមមានចិត្តរីករាយ　　បន្ទន់កាយទទួលយក
កូនចៅបានលៃលក　　បញ្ជូនមកលោកគ្រប់គ្នា ។
ដើម្បីសោយផលទាន　　សូមឲ្យបាននៅសុខជា
កូនចៅទាំងអស់គ្នា　　បានបូជាជូនទៅហោង ។៕

ធម៌ឧទ្ទិសបុណ្យកុសល

--++++000++++--

ឥធំនោ បុញ្ញំ មាតាបិតូនំ ញាតីនំ

ហោតុ សុខិតា ហោន្តុ ញាតយោ

(ប្រែជាពាក្យកាព្យ)

-សូមលើកកុសល ឧទ្ទិសជូនដល់ លោកអ្នកមានគុណ
មាតាបិតា ដូនតាបេតជន(១) ញាតិមិត្តជាតិមុន
និងបច្ចុប្បន្ន ។ ----------------------------

-សូមលោកទាំងនោះ បានរួចទុក្ខទោស រោគភ័យអាសន្ន
ជួបស្ថានសុខសួគ៌ ទាំងប្រាំមួយជាន់ បុណ្យជួយឲ្យទាន់
ច្បាស់ព្រះធម្មា ។ ----------------------------

-សូមចិត្តគំនិត យល់ត្រូវត្រង់ពិត តាមពុទ្ធមាគ៌ា
សម្មាទិដ្ឋិ គ្រប់ជាតិនានា ពួកជនពាលា
បរវាសចៀសឆ្ងាយ ។ -------------------------

-ទីបំផុតជាតិ សូមឲ្យឃ្លៀងឃ្លាត សត្រូវទាំងឡាយ
លះឧបាទាន តណ្ហាខ្ជាត់ខ្ជាយ កិលេសអន្តរាយ
ជួបនិព្វានហោង ៕

(១)-បេតជន =ជនលះលោកនេះ ទៅលោកខាងមុខ (ស្លាប់)

ធម៌ឧទ្ទិសបុណ្យកុសល

--++++OOO++++--

ឥទំ វោ បុញ្ញំ មាតាបិតូនំ ញាតីនំ

ហោតុ សុខិតា ហោន្តុ ញាតយោ

(ប្រែជាសំរាយធម្មតា)

រីបុណ្យកុសលនៃយើងខ្ញុំទាំងឡាយនេះ សូមឧទ្ទិសជូនចំពោះ
ដល់បុព្វការីជនទាំងឡាយ មានមាតានិងបិតា
គុណគ្រូឧបជ្ឈាយាចារ្យ ជីដូននិងជីតា
ញាតិកាទាំងប្រាំពីរសន្តាន ទាំងពីរអតីតកាលផង
ដល់ស្ដេចទេវរាជផង ស្ដេចចតុលោកបាលផង
ស្ដេចយមរាជផង ទេវតាទាំងឡាយផង
នាគនិងគ្រុឌទាំងឡាយផង ពួកប្រេតទាំងឡាយផង
បុគ្គលមានពៀរសត្រូវទាំងឡាយផង មួយអន្លើដល់សព្វសត្វទាំងឡាយផង
សូមអនុមោទនានូវបុណ្យកុសល នៃយើងខ្ញុំទាំងឡាយនេះ
លុះអនុមោទនារួចហើយ សូមឲ្យបានដល់
នូវសេចក្ដីសុខ និងសេចក្ដីចំរើន
អស់កាលជាយូរ អង្វែងទៅហោង ។

អរិយមគ្គអង្គ៨

អដ្ឋង្គិកមគ្គទាំងប្រាំបី ជាផ្លូវព្រះអរិយៈទាំងឡាយ
ដំណើរដោយល្អតែងនាំកាយ ទៅកាន់ប្រទ្បាយព្រះនិព្វន ។
សម្មាទិដ្ឋិឃើញត្រូវស្រេច គឺព្រះអរិយសច្ចទាំងបួនមាន
ឃើញមានឃើញពិតព្រះនិព្វន ឃើញសុខសឹងគ្មានទោសទុក្ខា។
វិអង្គសម្មាសង្កប្បោនេះ តម្រិះដែលត្រិះត្រង់ឧស្សាហ៍
រារុញធុញថប់ក្តីប្រាថ្នា ចិន្តាចង់ចៀសចាកកាមគុណ ។
សម្មាវាចាពោលពាក្យពិត សុចរិតមិនពោលមុសាស៊ុន
មិនស៊កមិនសៀតឆ្លៀតពាក្យធ្ងន់ ពាក្យណាជាគុណថ្លែងចរចា ។
សម្មាកម្មន្តោធ្វើការត្រូវ ចៀសផ្លូវមេថុនមិនប្រាថ្នា
មិនលបមិនលួចទ្រព្យនរណា បាណាវៀរមិនសម្លាប់សត្វ ។
សម្មាអាជីវោកាន់សុចរិត ចិញ្ចឹមជីវិតគិតប្រយ័ត្ន
មិនលក់មិនជួញមនុស្សនិងសត្វ បំបាត់ជំនួញប្រាំប្រការ ។
សម្មាវាយាមោព្យាយាមនូវ ធ្វើត្រូវមិនឲ្យធ្លោយប្រាជ្ញ
ព្យាយាមរវាំងបាំងអកុសលា មិនឲ្យខ្លាំងខ្លាកើតឡើងបាន ។
ព្យាយាមលះបាបដែលមានហើយ មិនធ្វើកន្តើយឲ្យរំខាន
រំលត់ឲ្យផុតចាកសន្តាន មិនឲ្យកើតបានក្តីវេទនា ។
ព្យាយាមញុំាំងកុសលដែលមានពិត ឲ្យរិតចម្រើនច្រើនមហិមា
សម្មាសតិតាំងសទ្ធា ភាវនារំលឹកក្នុងរាងកាយ ។
បញ្ញាពិចារណានឹករឿយៗ ក្នុងចិត្តនឹកព្រួយហើយនឿយណាយ
អនិច្ចំ ទុក្ខំ ទុក្ខក្នុងកាយ គ្មានខ្លឹមគ្មានស្រាយអង្គអនត្តា
សម្មាសមាធិធ្វើចិត្តត្រូវ ហើយតាំងជាប់នូវកម្មដ្ឋានណា
ធ្វើឈានឲ្យបានដោយបញ្ញា ឲ្យបានឯកគ្គតាជាប្រធាន ។៚

ធម៌សូត្រមុននឹងបញ្ចប់នមស្ការព្រះរតនត្រៃ

សូមឲ្យសាសនាព្រះសម្ពុទ្ធ   រុងរឿងបំផុតអស់កាលយូរ
សូមព្រះសទ្ធម្មបរមត្ថ   ស្ថិតស្ថេរនៅយូរគ្រប់ប្រាំពាន់
សូមឲ្យព្រះពុទ្ធសាសនា   រុងរឿងចំរើន
សូមឲ្យព្រះពុទ្ធសាសនា   ផ្សាយទូទៅពេញសាកលលោក
សូមឲ្យលោកទាំងមូល   បានប្រកបដោយសន្តិភាព
ព្រះសក្យមុនីសម្ពុទ្ធទ្រង់ត្រាស់ថា   នត្ថិ សន្តិ បរំ សុខំ
ពុំមានសេចក្ដីសុខដ៏ទៃ   ក្រៅអំពីសេចក្ដីស្ងប់ឡើយ ។

ពុទ្ធោ ខលិតោ ទោសោ ពុទ្ធោ ខមតុ តំ មមំ

ធម្មោ ខលិតោ ទោសោ ធម្មោ ខមតុ តំ មមំ

សង្ឃោ ខលិតោ ទោសោ សង្ឃោ ខមតុ តំ មមំ

ធម៌សូត្រសុំចង្ហាន់ព្រះសង្ឃ

បពិត្រលោកម្ចាស់ដ៏ចំរើន   ខ្ញុំព្រះករុណាទាំងឡាយ
សុំទានអាហារដ៏សេសសល់   ដែលលោកម្ចាស់   លះបង់ហើយ

ពុទ្ធោ ខលិតោ ទោសោ ពុទ្ធោ ខមតុ តំ មមំ

ធម្មោ ខលិតោ ទោសោ ធម្មោ ខមតុ តំ មមំ

សង្ឃោ ខលិតោ ទោសោ សង្ឃោ ខមតុ តំ មមំ

ភិក្ខុ ធម្មបាលោ នមស្ការបូជា

ព្រះបរមសារីរិកធាតុ នៅវត្តស្រីលង្កា

នាព្រៃឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី

ក្នុងឱកាសធម្មយាត្រា ទៅប្រទេសឥណ្ឌា ២០០៥



ពុទ្ធនីយដ្ឋាន ព្រះមហាពោធិព្រឹក្ស នៅពុទ្ធគយា

ទីនេះហើយ ដែលព្រះតថាគតបានត្រាស់ដឹងនូវ

អនុត្តរសម្មាសម្ពោធិញ្ញាណ

(ថ្ងៃពុធ ១៥កើត ខែវិសាខ ឆ្នាំរកា)

បន្ទាប់ពីឆាន់ចង្ហាន់នាងសុជាតា បណ្តែតផ្សងភាជន៍មាសនាស្ទឹងនេរញ្ជរារួច ព្រះបរមពោធិសត្វ ទ្រង់ចូលទៅត្រើយខាងលិច បានទទួលស្បូវភ្លាំង៨បាច់ពីសោត្ថិយព្រាហ្មណ៍ ព្រះសមណៈបានយកស្បូវនោះទៅក្រាលពីខាងកើតគល់ឈើ ដែល

មានមែកសាខាក្រោមម្លប់ទ្រឈើធំទ្រៃឈ ក្បែរមាត់ស្ទឹងដីមានទឹកថ្លាត្រជាក់ហើយ គង់ចុះ បែរភក្ត្រទៅទិសខាងកើត ដោយតាំងអធិដ្ឋានថា បើព្រះអង្គមិនបានត្រាស់ដឹងទេ ព្រះអង្គនឹងមិនក្រោកពីទីកន្លែងនោះជាដាច់ខាត បើទោះជាសាច់និងឈាមត្រូវហួតហែង ក្រៀមស្វិត នៅសល់តែស្បែកសរសៃយ៉ាងណាក៏ដោយ ។

រាត្រីក្នុងខែ៦(ខែពិសាខ) ខ្យល់ជំនោរត្រជាក់បក់មកបបោសអង្អែលព្រះកាយព្រះអង្គ កិលេស តណ្ហា គឺចិត្តអកុសលក៏ចេញមកសំដែងរិទ្ធិ ជ្រៀតជ្រែក ការគ្រេកគ្រអាលក្នុងកាមារម្មណ៍ដែលទ្រង់ធ្លាប់បានទទួល កាលមិនទាន់ចេញមកបួស ធ្វើឲ្យព្រះអង្គនឹកទៅដល់ អតីតកាល ភាពអផ្សុក ភាពរវើរវាយ នឿយណាយ ។

តែទីបំផុត ព្រះសមណៈក៏អាចយកឈ្នះបានដោយជោគជ័យ ដោយអំណាចកម្លាំងសមាធិដ៏ខ្ពស់របស់ទ្រង់ ។

++ **ក្នុងរាត្រីបឋមយាម** (ចន្លោះម៉ោង៦ទៅ១០យប់) ព្រះអង្គបានសំរេចនូវវិជ្ជាមួយ ដែលមានឈ្មោះថា **បុព្វេនិវាសានុស្សតិញ្ញាណ** ប្រែថា ញាណរលឹកឃើញនូវអតីតកាល (រលឹកជាតិ ចាំរឿងដែលកន្លងមក ឥតមានខុសខាស់) ។

++ **ក្នុងរាត្រីយាមទី២** (ចន្លោះម៉ោង ១០ទៅ ២រំលងអាធ្រាត្រ) ព្រះអង្គបានសំរេចនូវវិជ្ជាទី២ ដែលមានឈ្មោះថា **ចុតូបបាតញ្ញាណ** (ភ្នែកទិព្វ) អាចសំឡឹងមើលទៅអនាគតកាល ឃើញអ្វីៗ ដឹងរឿង ឥតខុសខាស់ ។

++ **ក្នុងរាត្រីយាមទី៣** (ចន្លោះម៉ោង២អាធ្រាត្រទៅ៦ភ្លឺ) ព្រះអង្គបានសំរេចវិជ្ជាទី៣ មានឈ្មោះថា **អាសវក្ខយញ្ញាណ** ដែលអាចឲ្យព្រះអង្គស្គាល់បានថានេះជាទុក្ខ

- នេះជាហេតុនាំឲ្យកើតទុក្ខ នេះជាទីរំលត់ទុក្ខ នេះជាផ្លូវដើរទៅរកទីរំលត់ទុក្ខ នេះជាកិលេស នេះជាតណ្ហា នេះជាភព នេះជាជាតិ ហើយព្រះអង្គរក
- ឃើញនូវហេតុ ដែលនាំឲ្យកើត នាំឲ្យរលត់ ព្រះអង្គដឹងនូវមធ្យោបាយដើម្បីរលត់ និងដឹងនូវផ្លូវដើរទៅដើម្បីរំលត់ គឺជាវិជ្ជាមួយដ៏ខ្ពស់បំផុតរបស់ព្រះអរហន្ត ព្រះអង្គបានទទួលឋានៈ **ជាពុទ្ធ** ប្រែថា **អ្នកត្រាស់ដឹង** ក្រោមដើមឈើដែលថ្ងៃក្រោយមកមាននាមថា **ពោធិព្រឹក្ស** ប្រែថា **ព្រឹក្សានៃការត្រាស់ដឹង** ៕

បទសារភញ្ញ

សូមថ្វាយបង្គំព្រះសម្ពុទ្ធ ប្រសើរបំផុតក្នុងលោកា
ជាគ្រូនៃមនុស្សនិងទេព្តា ទ្រង់ត្រាស់ទេសនាប្រដៅសត្វ ។

ចង្អុលឲ្យដើរផ្លូវកណ្តាល មាគ៌ាត្រកាលអាចកម្ចាត់
ទុក្ខភ័យចង្រៃឲ្យខ្ចាយខ្ចាត់ អាចកាត់សង្សារទុក្ខបាន ។

សាសនាព្រះអង្គនៅសព្វថ្ងៃ សត្វមាននិស្ស័យពីបូរាណ
ប្រឹងរៀនប្រឹងស្តាប់ចេះចាំបាន កាន់តាមលំអានបានក្តីសុខ ។

ឥតមានសុខណាស្មើក្តីស្ងប់ បញ្ចប់ត្រឹមសុខឃ្លាតចាកទុក្ខ
តាំងពីលោកនេះតទៅមុខ ក្តីសុខកើតមានព្រោះធម៌ស្ងប់។

ខ្ញុំសូមបង្គំឆ្ពោះព្រះធម៌ ព្រះសង្ឃបវរទាំងសព្វគ្រប់
រួមជាត្រ័យរត្នគួរគោរព ជាម្លប់ត្រជាក់នៃលោកា ។

ព្រះរូបព្រះធាតុនៃព្រះពុទ្ធ វិសុទ្ធតាងអង្គព្រះសាស្តា
សូមគុណត្រ័យរត្នជួយខេមរា ឲ្យបានសុខាតរៀងទៅ ។

អរហំ សម្មាសម្ពុទ្ធោ ភគវា -ព្រះដ៏មានព្រះភាគអង្គនោះ ជាព្រះអរហន្តរំលត់ភ្លើង
កិលេសភ្លើងទុក្ខទាំងពួង ត្រាស់ដឹងដោយព្រះអង្គឯង

ពុទ្ធំ ភគវន្តំ អភិវាទេមិ -ខ្ញុំព្រះករុណាសូមអភិវាទព្រះដ៏មានព្រះភាគអង្គនោះ

ស្វាក្ខាតោ ភគវតា ធម្មោ -ព្រះធម៌ជាធម៌គឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដឹង
ដោយប្រពៃហើយ

ធម្មំ នមស្សាមិ -ខ្ញុំព្រះករុណា នមស្ការនូវព្រះធម៌

សុបដិបន្នោ ភគវតោ សាវកសង្ឃោ-ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ
អង្គនោះ ប្រតិបត្តិដោយប្រពៃហើយ

សង្ឃំ នមាមិ ខ្ញុំព្រះករុណាថ្វាយបង្គំនូវព្រះសង្ឃ ។៕

--++++OOO++++--

ធម៌នមស្ការព្រះរតនត្រ័យ

អញ្ជើញពួកទេវតា

សមន្តា ចក្កវាឡេសុ អត្រាគច្ឆន្តុ ទេវតា
សទ្ធម្មំ មុនីរាជស្ស សុណន្តុ សគ្គមោក្ខទំ

ទេវតាទាំងឡាយ ក្នុងចក្កវាឡទាំងឡាយដោយជុំវិញ សូមអញ្ជើញមកប្រជុំគ្នាក្នុងទីនេះ ចូរស្តាប់នូវព្រះសទ្ធម្ម ជាធម៌អាចឲ្យនូវឋានសួគ៌ និងព្រះនិព្វាន របស់ព្រះអនាវរណញ្ញាណ ជាស្ដេចនៃអ្នកប្រាជ្ញ ។

ថ្វាយបង្គំព្រះពុទ្ធរតនៈ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

កិរិយា នមស្ការ ថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃ ចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។

(សូត្របាលី៣ចប់ សំរាយ១ចប់)

ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ តំ អរហាទិគុណសំ យុត្តំ ពុទ្ធំ សិរសា នមាមិ តញ្ច ពុទ្ធំ ឥមេហិ សក្ការេហិ អភិបូជយាមិ

ឥតិបិសោ ភគវា អរហំ ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា អរហំ ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវ ពោលគឺកិលេសព្រមទាំងវាសនា គឺកាយបយោគ និងវចីបយោគ សម្មាសម្ពុទ្ធោ ទ្រង់ព្រះនាមថា សម្មាសម្ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ វិជ្ជាចរណសម្បន្នោ ទ្រង់ព្រះនាមថា វិជ្ជាចរណសម្បន្នោ ព្រោះព្រះអង្គបរិបូណ៌ដោយ វិជ្ជា៣ និងវិជ្ជា៨ និងចរណៈ១៥ សុគតោ ទ្រង់ព្រះនាមថា សុគតោ ព្រោះព្រះអង្គមានដំណើរល្អយាងទៅកាន់សុន្ទរស្ថាន គឺអមតមហានិព្វាន លោកវិទូ ទ្រង់ព្រះនាមថា លោកវិទូព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក អនុត្តរោ ទ្រង់ព្រះនាមថា អនុត្តរោ ព្រោះព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន បុរិសទម្មសារថិ ទ្រង់ព្រះនាមថា បុរិសទម្មសារថិ ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរសដែលមានឧបនិស្ស័យគួរទឹងទូន្មានបាន សត្ថាទេវមនុស្សានំ ទ្រង់ព្រះនាមថា សត្ថាទេវមនុស្សានំ ព្រោះព្រះអង្គជាសាស្តាចារ្យនៃទេវតានិងមនុស្សទាំងឡាយ ពុទ្ធោ ទ្រង់ព្រះនាមថា ពុទ្ធោព្រោះព្រះអង្គត្រាស់

ដឹងនូវ **ចតុរារិយសច្ច** ហើយញុំាងអ្នកដទៃឱយត្រាស់ដឹងផង **ភគវា**ទ្រង់ព្រះនាមថា **ភគវា** ព្រោះព្រះអង្គមានដំណើរទៅកាន់ត្រៃភពខ្ជាក់ចោល ហើយគឺថាព្រះអង្គមិនត្រឡប់កើតទៀតឡើយ ។

តំ អរហាទិគុណសំយុត្តំ ពុទ្ធំ សិរសា នមាមិ ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គប្រកបព្រមហើយ ដោយគុណមានគុណថា **អរហំ** ជាដើមនោះដោយសិរសាគឺត្បូង **តញ្ច ពុទ្ធំ ឥមេហិ សក្ការេហិ អភិបូជយាមិ** ខ្ញុំព្រះករុណាសូមបូជាចំពោះនូវព្រះសម្មាសម្ពុទ្ធជាម្ចាស់នោះ ដោយគ្រឿងសក្ការៈទាំងឡាយមានប្រមាណប៉ុណ្ណេះ ៕

(ថ្វាយបង្គំម្តង)

ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ
ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ
តំ ស្វាក្ខាតា ទិគុណសំ យុត្តំ ធម្មំ សិរសា នមាមិ តញ្ច ធម្មំ
ឥមេហិ សក្ការេហិ អភិបូជយាមិ ។

ស្វាក្ខា តោ ភគវតា ធម្មោ ព្រះបរិយត្តិធម៌គឺព្រះត្រៃបិដក ជាធម៌គឺព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សំដែងហើយដោយល្អ **ធម្មោ** ព្រះនព្វលោកុត្តរធម៌មាន៩ប្រការ គឺមគ្គ៤ ផល៤ និព្វាន១ **សន្ទិដ្ឋិកោ**ជាធម៌គឺព្រះអរិយបុគ្គលទាំងពួង ដឹងពិតឃើញពិតដោយ បច្ចវេក្ខណញ្ញាណ គឺថា នឹងបានដឹងដោយស្តាប់ដោយជឿបុគ្គលដ៏ទៃនោះៗក៏ទេ គឺឃើញ

ច្បាស់ដោយខ្លួនឯង **អកាលិកោ** ជាធម៌ឲ្យនូវផលមិនរង់ចាំកាលគឺថា កាលបើព្រះអរិយមគ្គកើតឡើងហើយ ព្រះអរិយផលក៏កើតក្នុងលំដាប់គ្នាមិនបានយឺតយូរឡើយ **ឯហិបស្សិកោ** ជាធម៌គួរដល់**ឯហិបស្សវិធី** គឺថាបើព្រះអរិយបុគ្គលដែលបានសំរេចមគ្គផលហើយ ក៏គួរនឹងហៅបុគ្គលដ៏ទៃឲ្យចូលមកមើលបាន **ឱបនយិកោ** ជាធម៌គឺព្រះអរិយបុគ្គលគប្បី បង្អោនចូលមកទុកក្នុងខ្លួនដោយអំណាចនៃភាវនា **បច្ចត្តំ វេទិតព្វោ វិញ្ញូហិ** ជាធម៌គឺអ្នកប្រាជ្ញទាំងឡាយ មានឧគ្ឃដិតញ្ញូបុគ្គលជាដើម គប្បីដឹង គប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន ។

តំ ស្វាក្ខាតាទិគុណសំយុត្តំ ធម្មំ សិរសា នមាមិ ខ្ញុំព្រះករុណាសូមថ្វាយ

បង្គំនូវព្រះធម៌ជាម្ចាស់ ដ៏ប្រកបព្រមហើយដោយគុណ មានគុណថា **ស្វាក្ខាតោ** ជាដើមនោះ ដោយសិរសាគឺត្បូង **តញ្ច ធម្មំ ឥមេហិ សក្ការេហិ អភិបូជយាមិ** ខ្ញុំព្រះករុណាសូមបូជាចំពោះនូវព្រះធម៌ជាម្ចាស់នោះ ដោយគ្រឿងសក្ការៈទាំងឡាយ មានប្រមាណប៉ុណ្ណោះ ៕

(ថ្វាយបង្គំម្តង)

សុបដិបន្នោ ភគវតោ សាវកសង្ឃោ ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋបុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ តំសុបដិបន្ន ទិគុណសំយុត្តំ សង្ឃំ សិរសា នមាមិ តញ្ច សង្ឃំ ឥមេហិ សក្ការេហិ អភិបូជយាមិ ។

សុបដិបន្នោ ភគវតោ សាវក សង្ឃោ ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដ៏ប្រពៃ គឺប្រតិបត្តិតាមគន្លងព្រះនព្វលោកុត្តរធម៌ **ឧជុ បដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយត្រង់ គឺប្រតិបត្តិជាមជ្ឈិមបដិបទា **ញាយ បដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ជាស្ពានក្សេមផុតចាកទុក្ខទាំងពួង **សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សមគួរដល់សាមីចិកម្ម គឺប្រតិបត្តិគួរដល់ សីល សមាធិ បញ្ញា **យទិទំ ចត្តារិ បុរិសយុគានិ** ព្រះសង្ឃឯណាបើរាប់ជាគូនៃបុរសទាំងឡាយមានបួនគូ គឺព្រះសង្ឃដែលបានសំរេចនូវ សោតាបត្តិមគ្គនិងសោតាបត្តិផលជាគូ១ សកទាគាមិមគ្គ

និងសកទាគាមិផលជាគូ១ អនាគាមិមគ្គនិងអនាគាមិផលជាគូ១ អរហត្តមគ្គនិងអរហត្តផលជាគូ១ **អដ្ឋបុរិសបុគ្គលា** បើរាប់រៀងជាបុរសបុគ្គលមាន៨គឺព្រះសង្ឃដែលបានសំរេចនូវ សោតាបត្តិមគ្គ១សោតាបត្តិផល១ សកទាគាមិមគ្គ១សកទាគាមិផល១ អនាគាមិមគ្គ១អនាគាមិផល១ អរហត្តមគ្គ១អរហត្តផល១ **ឯសភគវតោ សាវកសង្ឃោ** ព្រះសង្ឃទាំងនោះ ជាសង្ឃសាវកនៃព្រះដ៏មានព្រះភាគ **អាហុនេយ្យោ** លោកគួរទទួលនូវចតុប្បច្ច័យ ដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីល ហើយនាំមកអំពីចម្ងាយបង្អោនចូលមកបូជា **បាហុនេយ្យ** លោកគួរទទួលនូវអគន្តុកទាន គឺទានដែលបុគ្គលតាក់តែងដើម្បីញាតិនិងមិត្ត ដែលមកអំពីទិសផ្សេងៗ ហើយបង្អោនចូលមកបូជា **ទក្ខិណេយ្យោ** លោកគួរទទួលនូវទាន ដែលបុគ្គលជឿនូវកម្ម និងផលនៃកម្មហើយបូជា **អញ្ជលិករណិយោ** លោកគួរដល់អញ្ជលិកម្ម ដែលសត្វលោកគប្បីធ្វើ **អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស** លោកជាបុញ្ញក្ខេត្ត គឺជាទីដុះឡើងនៃពូជគឺបុណ្យនៃសត្វលោក រកខេត្តដ៏ទៃក្រៃលែងជាងគ្មាន ។

តំ សុបដិបន្នាទិគុណសំយុត្តំ សង្ឃំ សិរសា នមាមិ ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះសង្ឃជាម្ចាស់ ដ៏ប្រកបព្រមហើយដោយគុណមានគុណជា **សុបដិបន្នោ** ជាដើមនោះដោយសិរសាគឺត្បូង **តញ្ច សង្ឃំ ឥមេហិ សក្ការេហិ អភិបូជយាមិ** ខ្ញុំព្រះករុណា សូមបូជាចំពោះនូវព្រះសង្ឃជាម្ចាស់នោះ ដោយគ្រឿងសក្ការៈទាំងឡាយ មានប្រមាណប៉ុណ្ណេះ

(ថ្វាយបង្គំ)

ឥច្ចេវមច្ចន្ត   នមស្សនេយ្យំ   នមស្សមានោ
រតនត្តយំ យំ   បុញ្ញាភិសន្ទំ   វិបុលំ អលត្ថំ
តស្សានុភាវេន   ហតន្តរាយោ ។

ខ្ញុំសូមនមស្ការ   លើកហត្ថឱនសិរសី
បង្គំគុណទាំងបី   ខ្ពស់លើសលប់លោកាចារ្យ។
សូមបុណ្យកងកុសល   ឲ្យបានដល់យើងខ្ញុំណា
ពេញពោរស្មើធារា   ដូចជលសាជំទូលាយ ។
សូមឲ្យកំចាត់បង់   អពមង្គលទាំងឡាយ
ឲ្យចៀសចេញចាកឆ្ងាយ   ក្តីអន្តរាយកុំបីមាន ។
ដោយកម្លាំងអានុភាព   បុញ្ញលាភជាប្រធាន
កងបុញ្ញរាសីមាន   សូមបានក្សាន្តកុំមានមោះ ។
ដោយគុណនមស្ការ   ត្រៃរតនាប្រសើរខ្ពស់
សូមអានិសង្សនោះ   ដាក់ដល់ស្ថាននិព្វានហោង ៕

ពុទ្ធបាទនមស្សការគាថា

ប្រែជាកាព្យ

វន្ទាមិ ពុទ្ធំ ភវបារតិណ្ណំ តិលោកកេតុំ តិភវេកនាថំ យោ លោកសេដ្ឋោ សកលំ កិលេសំ ឆេត្វាន ពោធេសិ ជនំ អនន្តំ ។

ព្រះសព្វញ្ញុពុទ្ធ វិសេសផុតត្រៃលោកា
គ្មានមនុស្សឬទេវតា ព្រហ្មមារណាប្រដូចបាន ។
កំចាត់នូវកិលេស គ្មានឲ្យសេសនៅសល់ខាន
ញ៉ាំងជនទាំងប៉ុន្មាន ជាអានន្តឲ្យត្រាស់ដឹង ។
ខ្ញុំសូមថ្វាយបង្គំ នូវព្រះបរមជាទីពឹង
ព្រះអង្គឆ្លងផុតស្ទឹង បានដល់ច្រាំងនៃភពហើយ ។
ព្រះអង្គជាទង់ជ័យ ធំត្រៃឈៃបង្ហាញត្រើយ
តែមួយព្រះអង្គហើយ ជាទីពឹងក្នុងត្រៃភព ។
មារព្រហ្មទាំងទេវតា និងមនុស្សាតែងគោរព
ចូលជ្រកនៅក្រោមម្លប់ ពោធិញ្ញាណបានសុខា ។

យំ នម្មទាយ នទិយា បុលិនេ ច តីរេ យំ សច្ចពន្ធគិរិកេ សុមនាចលគ្គេ យំ តត្ថ យោនកបុរេ មុនិនោ ច បាទំ តំ បាទលញ្ឆនមហំ សិរសា នមាមិ ។

សូមថ្វាយបង្គំ ទសករប្រណម
ឆ្ពោះត្រង់ស្នាមព្រះបាទា ដែលព្រះមានជោគ ។

ទ្រង់ព្រះមេត្តា ជាន់ទុកឲ្យជាស្ថានថ្លៃ
បាទមួយនៅនា ស្ទឹងនម្មទា ។
ត្រង់ឆ្នេរខ្សាច់ប្រសើរក្រៃ បាទមួយទ្រង់ជាន់
ទុកនៅព្ធ-ដីភ្នំគិរីសច្ចព័ន្ធ បាទមួយនៅភ្នំ ។
សុមនកូដ រហូតកំពូលដីសោភ័ណ
ព្រះបាទមួយទៀត ព្រះទ្រង់ជាន់ទុក
នៅនាយោនកបុរី ខ្ញុំសូមបន្ទន់ ។
កាយវាចា និងចិត្តជ្រះថ្លាឱនសិរសី
បង្គំព្រះបាទព្រះជិនស្រី សូមសុខសួស្តីគ្រប់វេលា ។

សុវណ្ណមាលិកេ សុវណ្ណបព្វតេ សុមនកូដេ
យោនកបុរេ នម្មទាយ នទិយា បញ្ចបាទវរំ ឋានំ
អហំ វន្ទាមិ ទុរតោ

ខ្ញុំសូមនមស្សការអំពីចម្ងាយ នូវឋានទាំងឡាយដែលមានព្រះបាទ
ទាំងប្រាំកន្លែងដែលព្រះមុនីនាថទ្រង់ឈានព្រះបាទលើកំពូលភ្នំ ។
សុវណ្ណមាលិកមួយនោះជាធំ មួយនៅលើភ្នំសុវណ្ណបព៌ត
មួយនៅលើភ្នំសុមនកូដប្រាកដ មួយនៅរាជរដ្ឋយោនកបុរី ។
មួយនៅក្បែរស្ទឹងនម្មទាជលធី ទាំងប្រាំនាទីដែលទ្រង់ប្រទាន
ទុកឲ្យសព្វសត្វប្រតិបត្តិជាស្ថាន ដោយព្រះទ្រង់ញាណប្រទានទុកឲ្យ។

ថ្វាយបង្គំព្រះបាទ

វន្ទាមិ ពុទ្ធំ ភវបារតិណ្ណំ តិលោកកេតុំ តិភវេកនាថំ យោ លោក សេដ្ឋោ សកលំ កិលេសំ ឆេត្វាន ពោធេសិ ជនំអនន្តំ

ព្រះសម្មាសម្ពុទ្ធអង្គឯណា ព្រះអង្គប្រសើរក្នុងលោក ទ្រង់កាត់បង់នូវកិលេសទាំងអស់បានហើយ ញ៉ាំងជនជាអានន្តឲ្យត្រាស់ដឹងហើយ ខ្ញុំសូមក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធនោះ ព្រះអង្គឆ្លងផុតអំពីប្រាំងនៃភពហើយ ព្រះអង្គជាទង់ជ័យនៃត្រៃលោក មានតែព្រះអង្គមួយជាទីពឹងនៃសព្វសត្វក្នុងត្រៃភព ។

យំ នម្មទាយ នទិយា បុលិនេ ច តីរេ យំ សច្ចពន្ធគិរកេ សុមនា ចលគ្គេ យំ តត្ថ យោនកបុរេ មុនិនោ ច បាទំ តំ បាទលញ្ឆ នមហំ សិរសា នមាមិ

ស្នាមព្រះបាទឯណា ដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក លើផ្ទៃខ្សាច់ទៀបឆ្នេរនៃស្ទឹងឈ្មោះនម្មទា ស្នាមព្រះបាទឯណាដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុកលើភ្នំសច្ចពន្ធ និងលើភ្នំសុមនកូដ ស្នាមព្រះបាទឯណាដែលព្រះសម្ពុទ្ធ ទ្រង់ប្រតិស្ឋានទុកក្នុងយោនកបុរី ខ្ញុំសូមក្រាបថ្វាយបង្គំដោយត្បូងចំពោះទៅព្រះបាទ និងស្នាមព្រះបាទទាំងនោះ នៃព្រះសក្យមុនី ។

សុវណ្ណមាលិកេ សុវណ្ណបព្វតេ សុមនកូដេ យោនកបុរេ
នម្មទាយ នទិយា បញ្ចបាទវរំ ឋានំ អហំ វន្ទាមិ ទូរតោ

ខ្ញុំសូមនមស្ការអំពីចម្ងាយ នូវស្ថានដែលមានព្រះបាទ ដ៏ប្រសើរ៥ កន្លែង គឺស្ថានលើភ្នំសុវណ្ណមាលិក១ លើភ្នំសុវណ្ណបព៌ត១ លើភ្នំសុមនកូដ១ ក្នុងយោនកបុរី១ ក្បែរស្ទឹងនម្មទា១ ។

(ថ្វាយបង្គំព្រះសារីរិកធាតុ)

វន្ទាមិ ចេតិយំ សព្វំ សព្វដ្ឋានេសុ បតិដ្ឋិតំ សារីរិកធាតុ
មហាពោធឹ ពុទ្ធរូបំ សកលំ សទា

ខ្ញុំសូមថ្វាយបង្គំ ចំពោះព្រះបរមចេតិយ
ព្រមទាំងព្រះសារី រិកធាតុនៃព្រះពុទ្ធ ។
និងមហាពោធិព្រឹក្ស ដែលគួរនឹកដោយលំអុត
លំអោនចិត្តបរិសុទ្ធ លើកកំបង់អញ្ជលី ។
និងព្រះពុទ្ធរូប ដំណាងអង្គព្រះមុនី
ដែលស្ថិតនៅគ្រប់ទី ស្ថាននានាគ្រប់ទាំងអស់ ។
ដោយតេជៈនៃគុណ ព្រះមានបុណ្យប្រសើរខ្ពស់
ដែលតែងតែរំលោះ រំដោះទុក្ខភ័យអន្តរាយ ។
សូមឲ្យខ្ញុំបានសុខ ឃ្លាតចាកទុក្ខផងទាំងឡាយ
សត្រូវទោះជិតឆ្ងាយ សូមឲ្យក្លាយមកជាមិត្ត
សូមទាន់ព្រះអរិយ មេត្រីយថ្ងៃវិសិដ្ឋ
សូមបានឃើញធម៌ពិត សមដូចចិត្តប្រាថ្នាហោង ។

ផ្សាយមេត្តាចំពោះទិសទាំង ១០

សព្វេ បុរត្ថិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ
សព្វេ បុរត្ថិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ
សព្វេ ទក្ខិណាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ
សព្វេ ទក្ខិណាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ
សព្វេ បច្ឆិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ
សព្វេ បច្ឆិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ
សព្វេ ឧត្តរាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ
សព្វេ ឧត្តរាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ
សព្វេ ហេដ្ឋិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ
សព្វេ ឧបរិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ សត្តា អវេរា ហោន្តុ សុខិតា ហោន្តុ និទ្ទុក្ខា ហោន្តុ អព្យាបជ្ឈា ហោន្តុ អនីឃា ហោន្តុ ទីឃាយុកា ហោន្តុ អរោគា ហោន្តុ សម្បត្តីហិ សមិជ្ឈន្តុ សុខី អត្តានំ បរិហរន្តុ ។

ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ បាណិនោ ។

សត្វទាំងឡាយទាំងពួង ដែលដល់ហើយនូវសេចក្តីទុក្ខ សូមឲ្យជាសត្វបាត់សេចក្តីទុក្ខទៅ ដែលដល់ហើយនូវភ័យ សូមឲ្យជាសត្វបាត់ភ័យទៅ ដែលដល់ហើយនូវសេចក្តីសោក សូមឲ្យជាសត្វបាត់សេចក្តីសោកទៅ ។

ផ្សាយមេត្តាចំពោះទិសទាំង១០ (ប្រែ)

---+++000+++---

++សត្វទាំងឡាយទាំងពួង ក្នុងទិសបូព៌ - ទិសអគ្នេយ៍ - ទិសទក្សិណ -ទិសនិរតី-ទិសបច្ចឹម-ទិសពាយ័ព្យ-ទិសឧត្តរ-ទិសឦសាន-ទិសខាងក្រោម -ទិសខាងលើ សូមកុំឲ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។

++សូមឲ្យសត្វទាំងឡាយទាំងពួង-កុំមានពៀរនឹងគ្នា-សូមឲ្យបាននូវសេចក្តីសុខ -សូមកុំឲ្យមានទុក្ខ -សូមកុំឲ្យបៀតបៀនដល់គ្នានឹងគ្នា -សូមកុំឲ្យមានសេចក្តីព្រួយលំបាក -សូមឲ្យមានអាយុវែង -សូមកុំឲ្យមានរោគ -សូមឲ្យសំរេចដោយសម្បត្តិគ្រប់យ៉ាង -សូមឲ្យរក្សានូវខ្លួនជាសុខស្រួលចុះ ។

++សត្វទាំងឡាយទាំងពួង-ដែលដល់ហើយនូវសេចក្តីទុក្ខ សូមឲ្យជាសត្វបាត់សេចក្តីទុក្ខទៅ -ដែលដល់ហើយនូវភ័យ សូមឲ្យជាសត្វបាត់ភ័យទៅ -ដែលដល់ហើយនូវសេចក្តីសោក សូមឲ្យជាសត្វបាត់សេចក្តីសោកទៅ ។៕

------++++++------

++ពួកសត្វទាំងអស់ក្នុង-ទិសបូព៌-ទិសអគ្នេយ៍-ទិសទក្សិណ-ទិសនិរតី-ទិសបច្ចឹម -ទិសពាយ័ព្យ-ទិសឧត្តរ-ទិសឦសាន-ទិសខាងក្រោម-ទិសខាងលើ សូមឲ្យជាសត្វមិនមានពៀរនឹងគ្នា សូមឲ្យមានតែសេចក្តីសុខជានិច្ចនិរន្តរ៍តទៅ ។

++ពួកសត្វទាំអស់សូមកុំមានពៀរនឹងគ្នា សូមឲ្យបានតែសេចក្តីសុខ ឲ្យប្រាសចាកទុក្ខ កុំព្យាបាទគ្នា កុំមានសេចក្តីព្រួយចំបែង សូមឲ្យមានអាយុវែង កុំឲ្យមានរោគ សូមឲ្យសំរេចដោយសម្បត្តិទាំងឡាយ សូមរក្សានូវខ្លួនឲ្យជាសុខតរៀងទៅ ។

++សត្វទាំងឡាយទាំងពួងដែលដល់ហើយនូវសេចក្តីទុក្ខ សូមឲ្យជាសត្វបាត់សេចក្តីទុក្ខទៅ ដែលដល់ហើយនូវភ័យ សូមឲ្យជាសត្វបាត់ភ័យទៅ ដែលដល់ហើយនូវសេចក្តីសោក សូមឲ្យជាសត្វបាត់សេចក្តីសោកទៅ ។៕

បត្តិទានគាថា (យា ទេវតា)

យាទេវតា សន្តិ វិហារវាសិនី
ថូបេឃរេ ពោធិឃរេ តហឹ តហឹ
តា ធម្មទានេន ភវន្តុ បូជិតា
សោត្ថឹ ករោន្តេធ វិហារមណ្ឌលេ
ថេរា ច មជ្ឈា នវកា ច ភិក្ខវោ
សារាមិកា ទានបតី ឧបាសិកា
គាមេ ចទេសា និគមា ច ឥស្សរា
សប្បាណភូតា សុខិតា ភវន្តុ តេ
ជលាពុជា យេបិ ច អណ្ឌសម្ភវា
សំសេទជាតា អថវោបបាតិកា
និយ្យានិកំ ធម្មវរំ បដិច្ច តេ
សព្វេបិ ទុក្ខស្ស ករោន្តុ សំខយំ
ឋាតុ ចិរំ សតំ ធម្មោ ធម្មធរា ច
បុគ្គលា សង្ឃោ ហោតុ សមគ្គោវ
អត្ថាយ ច ហិតាយ ច អម្ហេ រក្ខតុ សទ្ធម្មោ
សព្វេបិ ធម្មចារិនោ វុឌ្ឍឹ សម្បាបុណេយ្យាម
ធម្មារិយប្បវេទិតេ ។

យើងខ្ញុំទាំងអស់គ្នា សូមបូជាដោយធម្មទាន
ដល់ទេវតាដែលមាន នៅទីស្ថានវត្តនេះក្តី ។

នាខឿនព្រះស្ដូប ឬនៅនាខឿនចេតិយ
សូមមានចិត្តមេត្រី ធ្វើទឹកដីទីវត្តនេះ ៗ
សូមឲ្យសុខសួស្ដី ទុក្ខអ្វីៗកុំមានមោះ
ម្យ៉ាងទៀតសង្ឃទាំងអស់ ដែលមានផ្នួសជាថេរៈ ៗ
ឬក៏ជាមជ្ឈិម ឬនៅត្រឹមជាន់នវៈ
ឬក៏ឧបាសក **ដែលជាអ្នកម្ចាស់នៃទាន** ៗ
ព្រមទាំងអ្នកនិគម ឬអ្នកជំអម្បាលមាណ
គ្រប់ស្រុកប្រទេសស្ថាន សូមឲ្យបានសុខឯកអគ្គ ៗ
ម្យ៉ាងទៀតសត្វឯណា ដែលកើតជាជលាពុជៈ
ឬក៏អណ្ឌជៈ សំសេទជៈកំណើតក្ដី ៗ
ឬក៏ឧបបាតិកៈ គ្រប់ៗថ្នាក់ក្នុងលោកិយ
ដោយអំណាចសេចក្ដី ធម៌បាលីដ៏បវរ ៗ
កុំឲ្យមានទុក្ខសោក ក្ដីវិយោគសង្សារចរ
ម្យ៉ាងទៀតសូមឲ្យធម៌ ព្រះបវរស្ថិតនៅវែង ៗ
នឹងអ្នកចេះធម្មំ សូមឲ្យតាំងនៅអង្វែង
និងសូមឲ្យគម្ដែង សង្ឃម៉ឺនសែនសាមគ្គីធម៌ៗ
ដើម្បីប្រយោជន៍ច្រើន និងចំរើនកុសលធម៌
សូមឲ្យធម៌បវរ ជួយគាំទ្រយើងគ្រប់គ្នា ៗ
ហើយសូមអស់យើងខ្ញុំ ចេះចាំគ្រប់កងធម្មា
ដែលអង្គព្រះភគវា ទ្រង់ទេសនាតាំងទុកមក

គាថាសូមសេចក្តីសុខ

អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា
បុញ្ញំនោ អនុមោទន្តុ ចិរំ រក្ខន្តុ សាសនំ ។
រីទេវតានិងនាគ ស្ថិតនៅភាគភូមិផែនដី ឬលើអាកាសក្តី
មានសេរីដ៏ឧត្តម សូមអនុមោទនា នូវបុណ្យជារបស់ខ្ញុំ
ហើយសូមជួយថែទាំ នូវពុទ្ធសាសនា អស់កាលវែង ។

អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា
បុញ្ញំនោ អនុមោទន្តុ ចិរំ រក្ខន្តុ រាជានោ ។
រីទេវតានិងនាគ ស្ថិតនៅភាគភូមិផែនដី ឬលើអាកាសក្តី
មានសេរីដ៏ឧត្តម សូមអនុមោទនា នូវបុណ្យជារបស់ខ្ញុំ
ហើយសូមជួយថែទាំ នូវព្រះមហាក្សត្រ អស់កាលវែង ។

អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា
បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ ញាតិយោ
រីទេវតានិងនាគ ស្ថិតនៅភាគភូមិផែនដី ឬលើអាកាសក្តី
មានសេរីដ៏ឧត្តម សូមអនុមោទនា នូវបុណ្យជារបស់ខ្ញុំ
ហើយសូមជួយថែទាំ នូវក្រុមញាតិ អស់កាលវែង ។

អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា
បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ បាណិនោ
រីទេវតានិងនាគ ស្ថិតនៅភាគភូមិផែនដី ឬលើអាកាសក្តី
មានសេរីដ៏ឧត្តម សូមអនុមោទនា នូវបុណ្យជារបស់ខ្ញុំ
ហើយសូមជួយថែទាំ នូវពួកសត្វ អស់កាលវែង ។
អកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា
បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ នោ សទា
រីទេវតានិងនាគ ស្ថិតនូវភាគភូមិផែនដី ឬលើអាកាសក្តី
មានសេរីដ៏ឧត្តម សូមអនុមោទនា នូវបុណ្យជារបស់ខ្ញុំ
ហើយសូមជួយថែទាំ នូវយើងខ្ញុំ អស់កាលវែង

បត្តិទានគាថា

យំ កិញ្ចិ កុសលកម្មំ   កត្តព្វំ កិរិយំ មម
កាយេន វាចាមនសា   តិទសេ សុគតំ កតំ
យេ សត្តា សញ្ញិនោ អត្ថិ   យេ ចសត្តា អសញ្ញិនោ
កតំ បុញ្ញផលំ មយ្ហំ   សព្វេ ភាគី ភវន្តុ តេ
យេតំ កតំ សុវិទិតំ   ទិន្នំ បុញ្ញផលំ មយា
យេ ច តត្ថ ន ជានន្តិ   ទេវា គន្ត្វា និវេទយុំ
សព្វេ លោកម្ហិ យេ សត្តា   ជីវន្តា ហារហេតុកា
មនុញ្ញំ ភោជនំ សព្វេ   លភន្តុ មម ចេតសាតិ ៕

យំកិញ្ចិ កុសលកម្មំ កត្តព្វំ កិរិយំ មម អំពើជាកុសលឯណាមួយ ដែលខ្ញុំគប្បីធ្វើ **កាយេន វាចា មនសា** ដោយទ្វារទាំងបី គឺកាយ វាចា ចិត្ត **តិទសេ សុគតំ កតំ** អំពើជាកុសលទាំងអស់នោះដែលខ្ញុំបានធ្វើហើយ ជាកុសលអាចនឹងនាំឲ្យទៅកើតក្នុងស្ថានត្រៃត្រឹងស្រួតិបាន **យេ សត្តាសញ្ញិនោ អត្ថិ** សត្វទាំងឡាយឯណាគឺមនុស្ស ឬ ទេវតា ឬព្រហ្ម ដែលជាសត្វមានសញ្ញាក្តី **យេ ច សត្តា អសញ្ញិនោ** សត្វទាំងឡាយឯណា ជាអសញ្ញិសត្វ គឺសត្វដែលឥតសញ្ញាក្តី **កតំ បុញ្ញផលំ មយ្ហំ សព្វេ ភាគី ភវន្តុ តេ** សត្វទាំងឡាយទាំងអស់នោះ ចូរឲ្យបាននូវចំណែកផលនៃបុណ្យ ហើយចូរសោយនូវផលនៃបុណ្យដែលខ្ញុំបានធ្វើហើយ បានឧទ្ទិសផ្សាយឲ្យទៅនេះចុះ **យេតំ កតំ សុវិទិតំ ទិន្នំ បុញ្ញផលំ មយា** បុណ្យដែលខ្ញុំបានធ្វើហើយនោះ បើសត្វទាំងឡាយឯណា បានដឹងច្បាស់ហើយ សត្វទាំងឡាយនោះ ចូរឲ្យបានសោយនូវផលនៃបុណ្យ ដែលខ្ញុំបានឧទ្ទិសឲ្យទៅនោះចុះ **យេ ច តត្ថ ន ជានន្តិ** ម្យ៉ាងទៀតបណ្តាអស់សត្វទាំងនោះ បើសត្វទាំងឡាយឯណាមិនបានដឹងនូវបុណ្យ ដែលខ្ញុំបានធ្វើហើយនោះ **ទេវា គន្ត្វា និវេទយុំ** សូមទេវតាទាំងឡាយអញ្ជើញទៅឲ្យដំណឹង ដល់សត្វទាំងឡាយនោះ ឲ្យបានដឹងថា ជនឯណោះគេបានធ្វើបុណ្យ ហើយគេឧទ្ទិសផ្សាយផលបុណ្យនោះ មកដល់អ្នកទាំងឡាយៗ ចូរអនុមោទនាត្រេកអរនឹងបុណ្យគេនោះចុះ **សព្វេ លោកម្ហិ យេ សត្តា** ជីវន្តាហារហេតុកាសត្វទាំងឡាយឯណាក្នុងលោក

ទាំងអស់ ដែលអាស្រ័យនូវអាហារហើយរស់នៅ មនុញ្ញ
ភោជនំ សព្វេ លភន្តុ មម ចេតសាតិ សត្វទាំងឡាយទាំង
អស់នោះ ចូរឲ្យបាននូវភោជនជាទីគាប់ចិត្ត ដែលសំរេចដោយ
បុញ្ញឫទ្ធិ តាមចិត្តដែលខ្ញុំឧទ្ទិសផ្សាយទៅឲ្យនេះចុះ ៕

(យំកិញ្ចិ ប្រែជាពាក្យកាព្យ)

កម្មជាកុសលឯណា ដែលជាការឥតសៅហ្មង
យើងខ្ញុំបានកសាង ដោយកាយវាចាចិត្តពិត ។
កុសលទាំងអស់នោះ អាចជួយដោះជួយបន្ទិត
នាំសត្វឲ្យជាប់ចិត្ត ស្ថិតនៅនាស្ថានឧត្តម ។
សត្វណាមានសញ្ញា គឺទេវតាមនុស្សឬព្រហ្ម
ដែលមានសក្តិតូចធំ ព្រមទាំងសត្វឥតសញ្ញា ។
សូមបានចំណែកបុណ្យ ដែលជាគុណល្អថ្លៃថ្លា
យើងខ្ញុំបានរចនា ចាត់ចែងការកុសលហ្នឹង ។
ម្យ៉ាងទៀតសត្វឯណា ធ្លាយអស្ចារ្យពុំបានដឹង
ទេវតាជាពុំនឹង ឲ្យដំណឹងយ៉ាងនេះថា ។
នរជននៅឯណោះ ស្រីឬប្រុសបានជ្រះថ្លា
កសាងបុញ្ញកិរិយា វត្តជាផ្លូវចេតនា ។
ហើយគេឧទ្ទិសផល ឲ្យបានដល់អ្នកទាំងឡាយ

ចូរមានចិត្តស្រស់ស្រាយ　　　បន្ទន់កាយទទួលយក ។
សត្វលោកទាំងអស់នោះ　　　ដែលបានរស់តរៀងមក
ដោយបានបរិភោគ　　　នូវអាហារទើបរស់បាន ។
សត្វទាំងអស់នោះណា　　　បានសុខាសព្វគ្រប់ប្រាណ
អាហារយ៉ាងចំណាន　　　សូមឲ្យបានកុំខានឡើយ ៕

តេជៈខ្ញុំសាង

តេជៈខ្ញុំសាង　សំអិតសំអាង　ឱនកាយវាចា　សូមសុខសុភាព
រួចពីទុក្ខ　ជូនដល់ត្រើយមហា　ពោលគឺនិព្វាន ។
គ្រប់ជាន់គ្រប់ជាតិ　កុំឲ្យខ្ញុំឃ្លាត　ពីសីលនិងទាន　គំនិតយល់ត្រូវ
តាមផ្លូវនិព្វាន　មគ្គផលជាស្ពាន　ដល់ស្ថានថ្ងៃថ្លា ។
សូមជូនមគ្គផល　ចំពោះទៅដល់　មាតាបិតា　គុណគ្រូឧបជ្ឈា
យាចារ្យ　គុណញាតិកា　ប្រាំពីរសន្ដាន ។
ជីដូនជីតា　រស់នៅក្ដីណា　លោកម្ចាស់ចែកស្ថាន　សូមជូន
មគ្គផល　កុសលថ្កើងថ្កាន　សូមសុខក្សេមក្សាន្ត　ដល់ស្ថានផុតទុក្ខ ៕

បត្តិទានគាថា

--+++000+++--

ទានសីលខ្ញុំធ្វើហើយ ព្រះគុណអ្ហីយខ្ញុំសច្ឆា
ឧទ្ទិសផលនេះណា ជូនមាតាបិតាខ្ញុំ ។
ឪជូននិងឪតា គ្រូអាចារ្យទាំងតូចធំ
ញាតិមិត្តគ្រប់និគម មកជួបជុំទទួលផល ។
ដែលកូនចៅបានធ្វើ នូវអំពើជាកុសល
សូមទានឲ្យបានដល់ ទោះមណ្ឌលឆ្ងាយយ៉ាងណា ។
កុសលទាំងអស់ហ្នឹង សូមទីពឹងលើទេវតា
សូមមានចិត្តមេត្តា នាំផល្លាទាំងអស់នេះ ។
ទៅជូនឲ្យខ្ញុំផង ដូចបំណងកុំបីធ្វេស
កូននៅនៅឯណេះ មិនប្រហែសបញ្ជូនមក ។
សូមមានចិត្តរីករាយ បន្ទន់កាយទទួលយក
កូនចៅបានលែលក បញ្ជូនមកលោកគ្រប់គ្នា ។
ដើម្បីសោយផលទាន សូមឲ្យបាននៅសុខា
កូនចៅទាំងអស់គ្នា បានបូជាជូនទៅហោង ។៚

ធម៌ឧទ្ទិសបុណ្យកុសល

--++++000++++--

ឥទំវោ បុញ្ញំ មាតាបិតូនំ ញាតីនំ

ហោតុ សុខិតា ហោន្តុ ញាតយោ

(ប្រែជាពាក្យកាព្យ)

-សូមលើកកុសល ឧទ្ទិសជូនដល់ លោកអ្នកមានគុណ
មាតាបិតា ដូនតាបេតជន(១) ញាតិមិត្តជាតិមុន
និងបច្ចុប្បន្ន ។ ---------------------------

-សូមលោកទាំងនោះ បានរួចទុក្ខទោស រោគភ័យអាសន្ន
ជួបស្ថានសុខសួគ៌ ទាំងប្រាំមួយជាន់ បុណ្យជួយឲ្យទាន់
ច្បាស់ព្រះធម្មា ។ ---------------------------

-សូមចិត្តគំនិត យល់ត្រូវត្រង់ពិត តាមពុទ្ធមាគ៌ា
សម្មាទិដ្ឋិ គ្រប់ជាតិនានា ពួកជនពាលា
បរវាសចៀសឆ្ងាយ ។ ------------------------

-ទីបំផុតជាតិ សូមឲ្យឃ្លៀងឃ្លាត សត្រូវទាំងឡាយ
លះឧបាទាន តណ្ហាខ្ជាត់ខ្ជាយ កិលេសអន្តរាយ
ជួបនិព្វានហោង ។ ------------------------

(១)-បេតជន =ជនលះលោកនេះ ទៅលោកខាងមុខ (ស្លាប់)

ធម៌ឧទ្ទិសបុណ្យកុសល

--++++OOO++++--

ឥធំនោ បុញ្ញំ មាតាបិតូនំ ញាតីនំ
ហោតុ សុខិតា ហោន្តុ ញាតយោ

(ប្រែជាសំរាយធម្មតា)

រីបុណ្យកុសលនៃយើងខ្ញុំទាំងឡាយនេះ	សូមឧទ្ទិសជូនចំពោះ
ដល់បុព្វការីជនទាំងឡាយ	មានមាតានិងបិតា
គុណគ្រូឧបជ្ឈាយាចារ្យ	ជីដូននិងជីតា
ញាតិកាក្នុងសំសារវដ្ត	តាំងពីអតីតកាលផង
ដល់ស្តេចទេវរាជផង	ស្តេចចតុលោកបាលផង
ស្តេចយមរាជផង	ទេវតាទាំងឡាយផង
នាគនិងគ្រុឌទាំងឡាយផង	ពួកប្រេតទាំងឡាយផង
បុគ្គលមានពៀរសត្រូវទាំងឡាយផង	មួយអន្លើដល់សព្វសត្វទាំងឡាយផង
សូមអនុមោទនានូវបុណ្យកុសល	នៃយើងខ្ញុំទាំងឡាយនេះ
លុះអនុមោទនារួចហើយ	សូមឲ្យបានដល់
នូវសេចក្តីសុខ	និងសេចក្តីចំរើន
អស់កាលជាយូរ	អង្វែងទៅហោង ។

៦៣

អរិយមគ្គអង្គ៨

អដ្ឋង្គិកមគ្គទាំងប្រាំបី   ជាផ្លូវព្រះអរិយៈទាំងឡាយ
ដំណើរដោយល្អតែងនាំកាយ   ទៅកាន់ប្រឡាយព្រះនិព្វាន ។
សម្មាទិដ្ឋិឃើញត្រូវស្រេច   គឺព្រះអរិយសច្ចទាំងបួនមាន
ឃើញមានឃើញពិតព្រះនិព្វាន   ឃើញសុខសឹងគ្មានទោសទុក្ខា។
វិអង្គសម្មាសង្កប្បនេះ   តម្រិះដែលត្រិះត្រង់ឧស្សាហ៍
រារុញធុញថប់ក្តីប្រាថ្នា   ចិន្តាចង់ចៀសចាកកាមគុណ ។
សម្មាវាចាពោលពាក្យពិត   សុចរិតមិនពោលមុសាស៊ុន
មិនស៊កមិនសៀតឆ្កៀតពាក្យធ្ងន់   ពាក្យណាជាគុណថ្លែងចរចា ។
សម្មាកម្មន្តោធ្វើការត្រូវ   ចៀសផ្លូវមេថុនមិនប្រាថ្នា
មិនលបមិនលួចទ្រព្យនរណា   បាណាវៀរមិនសម្លាប់សត្វ ។
សម្មាអាជីវោកាន់សុចរិត   ចិញ្ចឹមជីវិតគិតប្រយ័ត្ន
មិនលក់មិនជួញមនុស្សនិងសត្វ   បំបាត់ជំនួញប្រាំប្រការ ។
សម្មាវាយាមោព្យាយាមនូវ   ធ្វើត្រូវមិនឲ្យធ្លោយប្រាជ្ញា
ព្យាយាមរាំងបាំងអកុសលា   មិនឲ្យខ្លាំងខ្លាកើតឡើងបាន ។
ព្យាយាមលះបាបដែលមានហើយ   មិនធ្វើកន្តើយឲ្យរំខាន
រំលត់ឲ្យផុតចាកសន្តាន   មិនឲ្យកើតបានក្តីវេទនា ។
ព្យាយាមញ៉ាំងកុសលដែលមានពិត   ឲ្យរិតចម្រើនច្រើនមហិមា
សម្មាសតិតាំងសទ្ធា   ភាវនារំលឹកក្នុងរាងកាយ ។
បញ្ញាពិចារណានឹករឿយៗ   ក្នុងចិត្តនឹកព្រួយហើយនឿយណាយ
អនិច្ចំ ទុក្ខំ ទុក្ខក្នុងកាយ   គ្មានខ្លឹមគ្មានស្រោយអង្គអនត្តា
សម្មាសមាធិធ្វើចិត្តត្រូវ   ហើយតាំងជាប់នូវកម្មដ្ឋានណា
ធ្វើឈានឲ្យបានដោយបញ្ញា   ឲ្យបានឯកគ្គតាជាប្រធាន ។៕

ធម៌សូត្រមុននឹងបញ្ចប់នមស្ការព្រះរតនត្រៃ

សូមឲ្យសាសនាព្រះសម្ពុទ្ធ រុងរឿងបំផុតអស់កាលយូរ
សូមព្រះសទ្ធម្មបវរមគ្គ ស្ថិតស្ថេរនៅយូរគ្រប់ប្រាំពាន់
សូមឲ្យព្រះពុទ្ធសាសនា រុងរឿងចំរើន
សូមឲ្យព្រះពុទ្ធសាសនា ផ្សាយទូទៅពេញសាកលលោក
សូមឲ្យលោកទាំងមូល បានប្រកបដោយសន្តិភាព
ព្រះសក្យមុនីសម្ពុទ្ធទ្រង់ត្រាស់ថា នត្ថិ សន្តិ បរំ សុខំ
ពុំមានសេចក្តីសុខដទៃ ក្រៅអំពីសេចក្តីស្ងប់ឡើយ ៕

ពុទ្ធេ យោ ខលិតោ ទោសោ ពុទ្ធោ ខមតុ តំ មមំ
ធម្មេ យោ ខលិតោ ទោសោ ធម្មោ ខមតុ តំ មមំ
សង្ឃេ យោ ខលិតោ ទោសោ សង្ឃោ ខមតុ តំ មមំ

ធម៌សូត្រសុំចង្ហាន់ព្រះសង្ឃ

បពិត្រលោកម្ចាស់ដ៏ចំរើន ខ្ញុំព្រះករុណាទាំងឡាយ
សុំទានអាហារដ៏សេសសល់ ដែលលោកម្ចាស់ លះបង់ហើយ

ពុទ្ធេ យោ ខលិតោ ទោសោ ពុទ្ធោ ខមតុ តំ មមំ
ធម្មេ យោ ខលិតោ ទោសោ ធម្មោ ខមតុ តំ មមំ
សង្ឃេ យោ ខលិតោ ទោសោ សង្ឃោ ខមតុ តំ មមំ

ថ្ងៃទី១១ ខែវិច្ឆិកា ១៩៧៥ ម៉ោង១២ ថ្ងៃត្រង់

ខ្ញុំណុប គ្រុយ បានរត់ឆ្លងដែនខ្មែរចូលមកដល់ដីថៃ ចូលទៅរស់នៅក្នុងជំរុំវត្តកោះ អារញ្ញប្រទេស(ប៉ោយប៉ែត) ដោយការស្រឡាញ់រាប់អានពីសំណាក់ព្រះចៅអធិការវត្ត (អាចារ្យថាន់) ព្រះអង្គក៏បំបួសខ្ញុំជាសាមណេរ

ទី១.សាមណេរ ស៊ីវ ស៊ីច័ន្ទ - ទី២.ចៅអធិការ ថាន់(ថៃ) - ទី៣.សាមណេរ ណុប គ្រុយ



បូជនីយដ្ឋាន ព្រៃឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី

ទីនេះហើយ ដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែង

នូវបឋមទេសនា (អនុត្តរធម្មចក្ក)

(ថ្ងៃ១៥កើត ខែអាសាធ ឆ្នាំរកា)

អត្ថន័យ អត្ថរស នៃអរិយសច្ចៈ៤ មានទុក្ខសច្ចៈ សមុទយសច្ចៈ និរោធសច្ចៈ និងមគ្គសច្ចៈ ព្រមទាំងអរិយមគ្គដ៏ប្រសើរមានអង្គ៨ ដែលជាមជ្ឈិមបដិបទា គឺជាផ្លូវកណ្ដាល មិនតឹងពេក មិនធូរពេក ស្ដាប់ចប់កាលណាធ្វើឲ្យបញ្ចវគ្គីទាំង៥រូប បានសំរេចមគ្គផល ហើយបួសក្នុងសំណាក់ព្រះសាសនារបស់ព្រះអង្គ នៅថ្ងៃ ១៥កើត ខែអាសាធ ។ ថ្ងៃក្រោយបន្ទាប់មក ទើបមានព្រះយសកុលបុត្តព្រមទាំងសំឡាញ់៥៥នាក់ បានស្ដាប់ព្រះធម៌ព្រះអង្គ ហើយបួសបានជាព្រះអរហន្តរួមទាំងព្រះដ៏មានព្រះភាគផងចំនួន៦១អង្គ ដែលបានចាំវស្សាទី១ នៅព្រៃឥសិបតនមិគទាយវ័ន នេះឯង ៕

សមាទាន (សីល ៥)

អ្នកក្រាសីលសូត្រថា

---+++---

ឱកាស មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន
សហ បញ្ចង្គសមន្នាគតំ និច្ចសីលំ យាចាម

ទុតិយម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន
សហ បញ្ចង្គសមន្នាគតំ និច្ចសីលំ យាចាម

តតិយម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន
សហ បញ្ចង្គសមន្នាគតំ និច្ចសីលំ យាចាម

អនុគ្គហំ កត្វា សីលំ ទេថ នោ ភន្តេ ។

ព្រះសង្ឃប្រទាន នូវត្រៃសរណគមន៍

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

វីកិរិយា នមស្ការថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏
មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់
ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ
ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។
(សូត្រតាមលោក បាលី ៣ចប់ ប្រែ១ចប់)

ពុទ្ធំ សរណំ គច្ឆាមិ

ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ជាទីពឹង ទីរលឹក

ធម្មំ សរណំ គច្ឆាមិ

ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ ជាទីពឹង ទីរលឹក

សង្ឃំ សរណំ គច្ឆាមិ

ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃ ជាទីពឹង ទីរលឹក

ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ

ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ជាទីពឹង ទីរលឹក ជាគម្រប់ពីរដងផង

ទុតិយម្បិ ធម្មំ សរណំ គច្ឆាមិ

ខ្ញុំព្រះករុណាសូមដល់នូវព្រះធម៌ ជាទីពឹងទីរលឹកជាគម្រប់ពីរដងផង

ទុតិយម្បិ សង្ឃំ សរណំ គច្ឆាមិ

ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃជាទីពឹង ទីរលឹកជាគម្រប់ពីរដងផង

តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ

ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ជាទីពឹង ទីរលឹក ជាគម្រប់បីដងផង

តតិយម្បិ ធម្មំ សរណំ គច្ឆាមិ

ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ ជាទីពឹង ទីរលឹក ជាគម្រប់បីដងផង

តតិយម្បិ សង្ឃំ សរណំ គច្ឆាមិ

ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃ ជាទីពឹង ទីរលឹកជាគម្រប់បីដងផង

តិសរណគ្គហណំបរិបុណ្ណំ

កិរិយាកាន់យកនូវព្រះត្រៃសរណគមន៍ចប់តែប៉ុណ្ណេះ ។

អ្នកទទួលសីល ឆ្លើយថា : **អាមភន្តេ** ករុណាលោកម្ចាស់ ៕

សមាទានសីល ៥

--+++--

បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ

ខ្ញុំព្រះករុណា សូមសមាទាននូវ សិក្ខាបទ គឺចេតនាជាហេតុវៀរចាក
កិរិយា ធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ ។

អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ

ខ្ញុំព្រះករុណា សូមសមាទាននូវ សិក្ខាបទ គឺចេតនាជាហេតុវៀរចាក
កិរិយា កាន់យកនូវវត្ថុ ដែលគេមិនបានឲ្យដោយកាយ ឬដោយវាចា។

កាមេសុ មិច្ឆាចារា វេរមណី សិក្ខាបទំ សមាទិយាមិ

ខ្ញុំព្រះករុណា សូមសមាទាននូវ សិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ។

មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ

ខ្ញុំព្រះករុណា សូមសមាទាននូវ សិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាពោលនូវពាក្យកុហក ។

សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ

ខ្ញុំព្រះករុណា សូមសមាទាននូវ សិក្ខាបទ គឺចេតនាជាហេតុវៀរចាក ហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង ។

ឥមានិ បញ្ច សិក្ខាបទានិ សាធុកំ កត្វា អប្បមាទេន
និច្ចកាលំ សម្មារក្ខិតព្វំ

អ្នកទាំងឡាយ គប្បីធ្វើនូវសិក្ខាបទទាំងឡាយ៥ នេះឲ្យប្រពៃ ត្រូវរក្សា ឲ្យល្អ អស់កាលជានិច្ច ដោយសេចក្តីមិនប្រមាទ គឺថាកុំឲ្យធ្វេសប្រហែសឡើយ ។

អ្នករក្សាសីលត្រូវឆ្លើយថា : **អាមភន្តេ** *ករុណាលោកម្ចាស់*

ព្រះសង្ឃសំដែងអានិសង្សសីលប្រាប់ថា :

សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា
សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ ។

សត្វទាំងឡាយ ទៅកាន់ស្ថានសួគ៌ ក៏ព្រោះសីល សត្វទាំងឡាយ បានបរិបូណ៌ដោយភោគៈ ក៏ព្រោះសីល សត្វទាំងឡាយបានទៅកាន់ទីរំលត់ទុក្ខគឺព្រះនិព្វាន ក៏ព្រោះសីល ព្រោះហេតុនោះ ជនជាសប្បុរសគប្បីជំរះនូវសីលរបស់ខ្លួនឲ្យបានបរិសុទ្ធកុំឲ្យសៅហ្មង ។

អ្នករក្សាសីលត្រូវទទួលថា : សាធុ សាធុ សាធុ

(សូមខមាទោសចំពោះ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ)

++ ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ ពុទ្ធេ យោ
ខលិតោ ទោសោ ពុទ្ធោ ខមតុ តំ មមំ
++ ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ ធម្មេ យោ
ខលិតោ ទោសោ ធម្មោ ខមតុ តំ មមំ
++ ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ សង្ឃេ យោ
ខលិតោ ទោសោ សង្ឃោ ខមតុ តំ មមំ ៕

សមាទាន ឧបោសថ (សីល ៨)

អ្នកសមាទានសីលសូត្រថា

---+++---

ឱកាស មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន
សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចាម

ទុតិយម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន
សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចាម

តតិយម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន
សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចាម

អនុគ្គហំ កត្វា សីលំ ទេថ នោ ភន្តេ ។

ព្រះសង្ឃប្រទាននូវត្រៃសរណគមន៍

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស (៣ចប់)

ពុទ្ធំ សរណំ គច្ឆាមិ

ធម្មំ សរណំ គច្ឆាមិ

សង្ឃំ សរណំ គច្ឆាមិ

ខ្ញុំព្រះករុណា សូមដល់នូវ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹង ទីរលឹក

ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ

ទុតិយម្បិ ធម្មំ សរណំ គច្ឆាមិ

ទុតិយម្បិ សង្ឃំ សរណំ គច្ឆាមិ

ខ្ញុំព្រះករុណា សូមដល់នូវ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹង ទីរលឹក ជាគម្រប់ពីរដងផង

តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ

តតិយម្បិ ធម្មំ សរណំ គច្ឆាមិ

តតិយម្បិ សង្ឃំ សរណំ គច្ឆាមិ

ខ្ញុំព្រះករុណា សូមដល់នូវ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹង ទីរលឹក ជាគម្រប់បីដងផង ។

តិសរណគ្គហណំ បរិបុណ្ណំ

កិរិយា កាន់យកនូវព្រះត្រៃសរណគមន៍ បរិបូរណ៍តែប៉ុណ្ណេះ ។

អ្នកសមាទានសីលទទួលថា **អាម ភន្តេ** ករុណាលោកម្ចាស់

សមាទានឧបោសថ (សីល ៨)

បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ

ខ្ញុំព្រះករុណា សូមសមាទាននូវ សិក្ខាបទ គឺចេតនាជាហេតុវៀរចាក
កិរិយា ធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ

អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ

ខ្ញុំព្រះករុណា សូមសមាទាននូវ សិក្ខាបទ គឺចេតនាជាហេតុវៀរចាក
កិរិយា កាន់យកនូវវត្ថុដែលគេមិនបានឲ្យ ដោយកាយឬវាចា

អព្រហ្មចរិយា វេរមណី សិក្ខាបទំ សមាទិយាមិ

ខ្ញុំព្រះករុណា សូមសមាទាននូវ សិក្ខាបទ គឺចេតនាជាហេតុវៀរចាក
កិរិយាប្រព្រឹត្ត នូវធម៌មិនប្រសើរ គឺសេពមេថុនធម្ម

មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ

ខ្ញុំព្រះករុណា សូមសមាទាននូវ សិក្ខាបទ គឺចេតនាជាហេតុវៀរចាក
កិរិយាពោលនូវពាក្យកុហក

សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ

ខ្ញុំព្រះករុណា សូមសមាទាននូវ សិក្ខាបទ គឺចេតនាជាហេតុវៀរចាក
ហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ

វិកាលភោជនា វេរមណី សិក្ខាបទំ សមាទិយាមិ

ខ្ញុំព្រះករុណា សូមសមាទាននូវ សិក្ខាបទ គឺចេតនាជាហេតុវៀរចាក
កិរិយាបរិភោគនូវភោជនាហារក្នុងកាលខុស

នច្ចគីតវាទិត វិសូកទស្សន មាលាគន្ធ វិលេបន ធារណ មណ្ឌន វិភូសនដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ

ខ្ញុំព្រះករុណា សូមសមាទានទូវ សិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយារាំនិងច្រៀង និងប្រគុំ និងមើល នូវល្បែង ដែលជាសត្រូវដល់ កុសលធម៌ និងកិរិយាទ្រទ្រង់ និងប្រដាប់តាក់តែង ស្អិតស្អាងរាងកាយ ដោយផ្កាកម្រង និងគ្រឿងក្រអូប និងគ្រឿងលាបផ្សេង ៗ ។

ឧច្ចាសយនមហាសយនា វេរមណី សិក្ខាបទំ សមាទិយាមិ

ខ្ញុំព្រះករុណាសូមសមាទានទូវសិក្ខាបទ គឺចេតនាវៀរចាកទីសេនាសនៈ ដ៏ខ្ពស់ហួសប្រមាណ និង ទីសេនាសនៈដ៏ប្រសើរ ។

អ្នកសមាទាន សូត្រកំណត់ឧបោសថថា

ឥមំ អដ្ឋង្គសមន្នាគតំ ពុទ្ធប្បញ្ញត្តំ ឧបោសថំ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សម្មទេវ អភិរក្ខិតុំ សមាទិយាមិ

ខ្ញុំព្រះករុណា សូមសមាទានទូវឧបោសថសីល ដ៏ប្រកបព្រមដោយ អង្គ៨ ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់បញ្ញត្តទុកហើយនេះ ដើម្បីនឹងរក្សាឲ្យបរិបូណ៌ប្រពៃ អស់កាលកំណត់ថ្ងៃនេះ និងយប់នេះ សូមកុសលចូរជាឧបនិស្ស័យ ធ្វើឲ្យច្បាស់ទូវព្រះនិព្វាន ក្នុងអនាគត កាលទៅឯមុខនោះហោង ។

ព្រះសង្ឃរំលឹកថា

ឥមានិ អដ្ឋសិក្ខាបទានិ ឧបោសថសីលវសេន ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សាធុកំ កត្វា អប្បមាទេន សម្មារក្ខិតព្វំ

អ្នកទាំងឡាយគប្បីធ្វើនូវសិក្ខាបទទាំងឡាយ៨នេះ ឲ្យប្រពៃ ត្រូវរក្សាឲ្យល្អ ដោយអំណាចនៃឧបោសថសីល អស់កាលកំណត់ត្រឹម១ថ្ងៃ ១យប់នេះ ដោយសេចក្ដីមិនប្រមាទ គឺថាកុំគប្បីធ្វេសប្រហែសឡើយ ។

អ្នកសមាទានទទួលថា **អាមភន្តេ** ករុណាលោកម្ចាស់

អានិសង្សសីល

សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា
សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ

សត្វទាំងឡាយទៅកាន់ស្ថានសួគ៌បាន ក៏ព្រោះសីល
សត្វទាំងឡាយបានបរិបូណ៌ដោយភោគៈ ក៏ព្រោះសីល
សត្វទាំងឡាយទៅកាន់ទីរំលត់ទុក្ខ គឺព្រះនិព្វាន ក៏ព្រោះសីល
ព្រោះហេតុដូច្នោះ បុគ្គលជាសប្បុរស គប្បីជំរះនូវសីលរបស់ខ្លួន ឲ្យបានបរិសុទ្ធកុំឲ្យសៅហ្មង ។

អ្នកសមាទានទទួលថា សាធុ សាធុ សាធុ ប្រពៃហើយលោកម្ចាស់ ៕

អង្គនៃឧបោសថសីល

---+++---

បាណាតិបាត មានអង្គ៥

១-បាណោ សត្វមានជីវិត

២-បាណសញ្ញិតា សេចក្តីដឹងថាសត្វមានជីវិត

៣-វធកចិត្តំ គិតនឹងសម្លាប់

៤-ឧបក្កមោ ព្យាយាមនឹងសម្លាប់

៥-តេន មរណំ សត្វស្លាប់ដោយព្យាយាមនោះ ។

អទិន្នាទាន មានអង្គ៥

១-បរបរិគ្គហិតំ ទ្រព្យដែលម្ចាស់គេហួងហែងរក្សា

២-បរបរិគ្គហិតសញ្ញិតា សេចក្តីដឹងថា ទ្រព្យមានម្ចាស់របស់គេហួងហែងរក្សា

៣-ថេយ្យចិត្តំ គិតនឹងលួច

៤-ឧបក្កមោ ព្យាយាមនឹងលួច

៥-តេន ហរណំ លួចបានមកដោយព្យាយាមនោះ ។

កាមេសុមិច្ឆាចារ មានអង្គ៤

១-អគមនីយដ្ឋានំ ស្ត្រីដែលមិនគួរនឹងគប់រក គឺស្ត្រីដែលមានគេហួងហែងរក្សា

២-តស្មឹ សេវនចិត្តំ គិតនឹងសេពនូវមេថុនធម្មនឹងស្ត្រីនោះ

៣-ឧបក្កមោ ព្យាយាមនឹងសេពនូវមេថុនធម្ម

៤-មគ្គេន មគ្គបដិបាទនំ ញ៉ាំងមគ្គនិងមគ្គឲ្យជល់គ្នា ។

អព្រហ្មចរិយ មានអង្គ៤

១-អគមនវត្ថុ វត្ថុជាទីទម្លាយនូវសីល គឺទ្វារទាំង៣០ចំពោះទ្វារណាមួយ

២-សេវនចិត្តំ គិតនឹងសេព

៣-តជ្ជោ វាយាមោ ព្យាយាមនឹងសេពនូវមេថុនធម្មនោះ

៤-មគ្គេនមគ្គប្បដិបាទនំ ញ៉ាំងមគ្គនឹងមគ្គឲ្យដល់គ្នា

មុសាវាទ មានអង្គ៤

១-អតថំវត្ថុ វត្ថុមិនពិត

២-វិសំវាទនចិត្តំ គិតនឹងពោលឲ្យខុស

៣-តជ្ជោ វាយាមោ ព្យាយាមនឹងពោលឲ្យខុស

៤-បរស្ស តទត្ថវិជាននំ ញ៉ាំងអ្នកដទៃឲ្យដឹងច្បាស់នូវសេចក្តីនោះ ។

សុរាមេរយ មានអង្គ៤

១-មជ្ជនីយវត្ថុ វត្ថុជាទីតាំងនៃសេចក្តីស្រវឹងគឺសុរានិងមេរ័យ

២-បាតុកម្យតាចិត្តំ គិតបំរុងនឹងផឹក

៣-តជ្ជោវាយាមោ ព្យាយាមនឹងផឹកនូវទឹកស្រវឹងនោះ

៤-តស្ស បានំ បានផឹកនូវទឹកស្រវឹងនោះឲ្យកន្លងបំពង់កចូលទៅ

វិកាលភោជន មានអង្គ៣

១-វិកាលោ កាលខុសគឺព្រះអាទិត្យជ្រេទៅហើយ
ជាកបទល់នឹងអរុណរះ

២-យាវកាលិកំ *របស់ដែលគួរបរិភោគបានក្នុងកាលគឺតាំងពីអរុណរះឡើង ដរាបដល់ថ្ងៃត្រង់*

៣-អវជ្ជោហរណំ *បានលេបចូលទៅក្នុងបំពង់ក ។*

នច្ចគីត មានអង្គ៣

១-នច្ចគីតាទិ *ការល្បែងមានរាំនិងច្រៀងជាដើម*

២-កត្តុកម្យតាចិត្តំ *គិតបំរុងនឹងធ្វើ*

៣-សុតធស្សនត្ថាយគមនំ *ទៅដើម្បីនឹងស្ដាប់ឬមើល ហើយបានស្ដាប់ឬមើល*

មាលា មានអង្គ៣

១-មាលាទិ *វត្ថុសំរាប់ប្រដាប់កាយមានផ្កាកម្រងជាដើម*

២-ធារណាធន្នតា *សេចក្ដីប្រាថ្នានឹងប្រដាប់តាក់តែង*

៣-តស្ស ធារណំ *បានប្រដាប់តាក់តែង នូវវត្ថុសំរាប់ប្រដាប់កាយមានផ្កាកម្រងជាដើមនោះ ។*

ឧច្ចាសយន មានអង្គ៣

១-ឧច្ចាសយន មហាសយនំ *ទីដេកទីអង្គុយដ៏ខ្ពស់ ដ៏ប្រសើរហួសប្រមាណ*

២-បរិភោគចិត្តំ *គិតនឹងដេក ឬអង្គុយ*

៣-បរិភោគករណំ *បានដេក ឬអង្គុយ ។*

ចោរបរចេតៈ មានអង្គ៣

១-ចោរបរចេតំ មាសឬប្រាក់ដែលជាអកប្បិយកណ្ឌ

២-អត្តុទ្ទិសតា ចំពោះជារបស់ខ្លួន

៣-បដិគណ្ហាតិ បានទទួលកាន់យកដោយខ្លួនឯង ឬប្រើគេឲ្យទទួល
កាន់យកទុកដាក់ឲ្យ ហើយត្រេកអរចំពោះមាសឬ
ប្រាក់នោះ ដោយឧបាយឯណាទីមួយ ។

(ចប់អង្គនៃឧបោសថសីល)

---+++---

កុសលកម្មបថ មាន១០

----+++-----

កាយកម្ម មាន៣

១-បាណាតិបាតា វេរមណី ចេតនាជាហេតុវៀរចាក កិរិយាធ្វើសត្វ
មានជីវិតឲ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ

២-អទិន្នាទានា វេរមណី ចេតនាជាហេតុវៀរចាក កិរិយាកាន់យកនូវវត្ថុ
ដែលគេមិនបានឲ្យ ដោយកាយឬដោយវាចា

៣-កាមេសុមិច្ឆាចារា វេរមណី ចេតនាជាហេតុវៀរចាក កិរិយាប្រព្រឹត្ត
ខុសក្នុងកាមទាំងឡាយ ។

វចីកម្ម មាន៤

១-មុសាវាទា វេរមណី *ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក*

២-បិសុណាវាចា វេរមណី *ចេតនាជាហេតុវៀរចាក កិរិយាពោលនូវពាក្យញុះញង់សិកសៀតបំបែកបំបាក់អ្នកដទៃ*

៣-ផរុសាយវាចាយ វេរមណី *ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យអាក្រក់ មានពាក្យទ្រគោះបោះបោក ជេរប្រទេចអ្នកដទៃជាដើម*

៤-សម្ផប្បលាបា វេរមណី *ចេតនាជាហេតុវៀរចាក កិរិយាពោលនូវពាក្យរោយរាយឥតប្រយោជន៍ ។*

មនោកម្ម មាន៣

១-អនភិជ្ឈា *មិនមានចិត្តគិតសំឡឹងរំពៃ ចំពោះទ្រព្យរបស់អ្នកដទៃដោយគិតបំរុងនឹងឲ្យបានមកជារបស់ខ្លួនឡើយ*

២-អព្យាបាទោ *មិនមានចិត្តគំនុំគំគួន គិតប៉ងនឹងឲ្យអ្នកដទៃដល់នូវសេចក្តីវិនាសឡើយ*

៣-សម្មាទិដ្ឋិ *គំនិតយល់ឃើញត្រូវពិត ហើយប្រកាន់ឡើងថាជាត្រូវមែន*

(ចប់កុសលកម្មបថ ១០)

--+--

អកុសលកម្មបថ មាន១០



បូជនីយដ្ឋាន សាលវ័ន ឧទ្យានពួកមល្លក្សត្រ

ជាទីចូលទៅ ក្រុងកុសិនារា

ទីនេះហើយ ដែលព្រះតថាគត បរិនិព្វានដោយ

អនុបាទិសេសនិព្វានធាតុ

(ថ្ងៃអង្គារ ១៥កើត ខែវិសាខ ឆ្នាំម្សាញ់)

ទ្រង់ត្រាស់នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទចូរអ្នករៀបចំគ្រែ ឲ្យមានក្បាលដំណេកបែរទៅទិសខាងជើង ក្នុងចន្លោះនៃដើមសាលព្រឹក្សទាំងគូឲ្យតថាគតដោយឆាប់ ម្នាលអានន្ទ តថាគតមានកាយល្ហិតល្ហៃណាស់ តថាគតនឹងសឹង ។ គ្រានោះ ព្រះមានព្រះភាគ មានសតិសម្បជញ្ញៈ ទ្រង់សំរេចសីហសេយ្យា ផ្ទៀងទៅខាងស្តាំ ទ្រង់យកព្រះបាទឆ្វេង តម្រួតលើព្រះបាទស្តាំ ។ សម័យនោះឯងសាលព្រឹក្សទាំងគូក៏មានផ្ការីកស្គុះស្គាយទាំងអស់ តាំងពីគល់ដល់ចុង ដោយ

អកាលបុប្ផ ក៏ហោយក៏យាបាចសាចទូផ្កាលើសរីរៈព្រះតថាគត ផ្កាទិព្វក៏ធ្លាក់ចុះមក អំពីអាកាស ដើម្បីបូជាព្រះតថាគត ។

ព្រះអានន្ទក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន កាលពីដើមពួកភិក្ខុនៅចាំវស្សា តែងមកគាល់ព្រះតថាគត យើងខ្ញុំព្រះអង្គតែងបានជួបនឹងពួកភិក្ខុអ្នកចំរើនដោយចិត្ត ធ្លាប់បានចូលទៅអង្គុយជិតគ្នា បពិត្រព្រះអង្គដ៏ចំរើន លុះអំណឹះតអំពីព្រះតថាគតទៅ យើងខ្ញុំព្រះអង្គនឹងលែងបានជួប លែងបានទៅអង្គុយជិតពួកភិក្ខុអ្នកចំរើនដោយចិត្តហើយ ។

ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ សំវេជនីយដ្ឋាន (ទីដែលគួរកើតសង្វេគ) ដែលគួរឃើញរបស់កុលបុត្ត អ្នកមានសទ្ធានេះមាន ៤កន្លែង ។

- ម្នាលអានន្ទ សំវេជនីយដ្ឋាន(ទីដែលគួរកើតសង្វេគ) ដែលគួរឃើញរបស់កុលបុត្តអ្នកមានសទ្ធា ដោយពេញឃើញថា ព្រះតថាគតប្រសូត្រក្នុងទីនេះដូច្នេះ១
- ម្នាលអានន្ទ សំវេជនីយដ្ឋាន(ដែលគួរកើតសង្វេគ) ដែលគួរឃើញរបស់កុលបុត្តអ្នកមានសទ្ធា ដោយពេញឃើញថា ព្រះតថាគតត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណក្នុងទីនេះដូច្នេះ ១ ។
- ម្នាលអានន្ទ សំវេជនីយដ្ឋាន (ដែលគួរកើតសង្វេគ) ដែលគួរឃើញរបស់កុលបុត្តអ្នកមានសទ្ធាដោយពេញឃើញថា ព្រះតថាគតបានសំដែងនូវអនុត្តរធម្មចក្កក្នុងទីនេះដូច្នេះ១ ។
- ម្នាលអានន្ទ សំវេជនីយដ្ឋាន (ដែលគួរកើតសង្វេគ) ដែលគួរឃើញរបស់កុលបុត្តអ្នកមានសទ្ធា ដោយពេញឃើញថា ព្រះតថាគត បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុក្នុងទីនេះដូច្នេះ ១ ។

ម្នាលអានន្ទ ពួកជនណាមួយ នឹងបានដើរមកកាន់ចារិកនៃព្រះចេតិយ ៤ ខាងលើនេះ ក៏មានចិត្តជ្រះថ្លា បើប្រសិនជាធ្វើមរណកាលទៅ ពួកជនទាំងអស់នោះ លុះមានរាងកាយបែកធ្លាយទៅ ខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ នឹងចូលទៅកាន់លោក គឺមនុស្សសុគតិ និងស្ថានសួគ៌ ៕

ពុទ្ធជយមង្គលគាថា (ពាហុំ)

----+++---

ពាហុំ សហស្សមភិនិម្មិតសាវុធន្តំ
គ្រីមេខលំ ឧទិតឃោរសសេនមារំ
ទានាទិធម្មវិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ

ព្រះមុនិន្ទលោកាចារ្យ ផ្ចាញ់ក្រុងមារចិត្តមោហន្ធ
និម្មិតដៃមួយពាន់ កាន់សស្ត្រាវុធនានា ។
ជិះគ្រីមេខលជាតិ កោញ្ចនាទខ្ទរពសុធា
ព្រមដោយមារសេនា ពន្លឹកលន់កងស័ព្ទស៊ាន ។
ដោយធម្មពិធី ទានបារមីជាប្រធាន
ក្រុងមារចាញ់ទ្រង់ញាណ ប្រណម្យកាយថ្វាយវន្ទា ។
រីជយមង្គល ចូរមានដល់អ្នកពល់គ្នា
ដោយតេជៈជយា ព្រះឈ្នះមារគ្រានោះហោង ។

មារាតិរេកមភិយុជ្ឈិតសព្វរត្តឹ
ឃោរម្បនាឡវកមក្ខមថទ្ធយក្ខំ
ខន្តី សុទន្តវិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ

ព្រះមុនិន្ទពិននាយក: ផ្ចាញ់អាឡវកយក្ខឃោរឃៅ
រឹងរូសមិនតាំងនៅ ក្នុងខន្តីគុណសត្យា ។
រហូតអស់រាត្រី ព្រះជិនស្រីទ្រង់យុទ្ធនា
ក្រៃលែងក្រុងមារា ក្នុងបឋមសម្ពោធិ ។
ដោយព្រះពិធីញាណ ទ្រង់ទូន្មានដោយខន្តី
ញុំាងចិត្តអសុរី ឲ្យបង់ព្យុះចុះវន្ទោ ។
រីជយមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជ:ជយា ព្រះឈ្នះអាឡវកយក្ខហោង ។

នាឡាគិរី គជវរំ អតិមត្តភូតំ
ទាវគ្គិចក្កមសនីវ សុទារុណន្តំ
មេត្តម្ពុសេកវិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ

ព្រះមុនិន្ទពិនជិនស្រី ផ្ចាញ់ដំរីឈ្មោះនាឡា
គិរីវរគជា ដ៏ហានក្លាចុះប្រេងព្រេញ្ស ។
សាហាវធាវរេះក្រៃ ដូចភ្លើងព្រៃឆេះកំទេច
មុតដូចចក្រក្រុតពេជ្រ ខ្លាំងដូចកម្ទអសនី ។
ដោយព្រះពិធីស្រប់ ស្រោចទឹកអប់គឺបារមី
មេត្តាព្រះជិនស្រី ញ៉ាំងដំរីឲ្យជ្រះថ្លា ។
វិជយមង្គល ចូរមានដល់អ្នកពល់គ្នា
ដោយតេជៈជយា ព្រះឈ្នះនាឡាគិរី ។

ឧក្ខិត្តខគ្គមតិហត្ថសុទារុណន្តំ
ធាវន្តិ យោជនបថង្គុលិមាលវន្តំ
ឥទ្ធីភិសង្ខតមនោ ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ

ព្រះមុនិន្ទពិនលោកត្រៃ មានព្រះទ័យធ្វើបាដិហារ្យ
ផ្ចាញ់ចោរអង្គុលិមាល៍ មានកម្រងគឺម្រាមដៃ ។
នៃមនុស្សដែលគាត់កាត់ មកដោតចាត់ជាមាល័យ
អង់អាចកំណាចក្រៃ ដ៏មានដៃស្ទាត់ប្រហារ ។
កាន់ដាវឆាវក្រវី ដេញព្រះមុនីសាស្ដាចារ្យ
ចម្ងាយផ្លូវកន្តារ កណ្ដាលព្រៃបីយោជនា ។
រីជយមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជៈជយា ព្រះឈ្នះអង្គុលិមាល៍ ។

កត្វាន កដ្ឋមុទរំ ឥវ គព្ភិនិយា
ចិញ្ចាយ ទុដ្ឋវចនំ ជនកាយមជ្ឈេ
សន្តេន សោមវិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ

ព្រះមុនិន្ទមានព្រះភាគ ផ្ចាញ់ទ្រុស្តពាក្យនាងចិញ្ចា
អំពើធ្វើដូចជា ស្រីមានគភ៌ចាស់ចើសពោះ ។
យកឈើធ្វើជាកូន ព័ន្ធពោះខ្លួនពោលទ្រគោះ
ព្រះពុទ្ធឈ្នះកាលនោះ ដោយសមាចារពិធី ។
រម្ងាប់ពាក្យចណ្ឌាល នាកណ្ដាលជនប្រុសស្រី
ចិញ្ចាចាញ់បារមី គឺសច្ចំពាក្យសត្យា ។
រីជយមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជៈជយា ព្រះសាស្តាឈ្នះចិញ្ចា ។

សច្ចំ វិហាយមតិសច្ចកវាទកេតុំ
វាទាភិរោបិតមនំ អតិអន្ធភូតំ
បញ្ញាបទីបជលិតោ ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ

ព្រះមុនិន្ទពិនអ្នកប្រាជ្ញ រុងរឿងស្វាងដោយបញ្ញា
ផ្ចាញ់សច្ចកជា និគ្រន្ថក្រៅពុទ្ធវិន័យ ។
អធ្យាស្រ័យលះបង់ ពាក្យសត្យត្រង់តាមគាប់ចៃ
សរសើរខ្លួនឯងក្រៃ លើកកំពស់ដូចដងទង់ ។
បង្កើតមូរងងឹត ដោយពោលឥតពាក្យទៀងត្រង់
ព្រះទ្រង់កំចាត់បង់ ដោយប្រទីបគឺបញ្ញា ។
វិជយមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជះជយា ឈ្នះសច្ចកៈនិគ្រន្ថ ។

នន្ទោបនន្ទភុជគំ វិពុធំ មហិទ្ធឹ
បុត្តេន ថេរភុជគេន ទមាបយន្តោ
ឥទ្ធូបទេសវិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ

ព្រះមុនិន្ទពិនទ្រង់ញាណ ញុំាងមោគ្គល្លានមានអំណាច
ឲ្យប្លែងជានាគរាជ ទៅទូន្មានព្យុះភុជង្គ ។
ឈ្មោះនន្ទោបនន្ទ ចិត្តមោហន្ធរឿងឫទ្ធិរុង
ទិដ្ឋិកាចទ្រនង់ ទ្រង់ផ្ចាញ់ដោយពិធីឈាន ។
គឺឲ្យឧបទេស ឫទ្ធិវិសេសដល់មោគ្គល្លាន
ឫទ្ធិនាគអន្តរធាន ឱនចុះបាញ់ព្រះបេស្តា ។
វីជយមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជៈជយា ព្រះភគវាឈ្នះនាគហោង ។

ទុគ្គាហទិដ្ឋិកុជគេន សុទដ្ឋហត្ថំ
ព្រហ្មំ វិសុទ្ធិជុតិមិទ្ធិពកាភិធានំ
ញាណាគទេន វិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ

ព្រះមុនិន្ទពិនគោត្តម ផ្ចាញ់មហាព្រហ្មឈ្មោះពកា
សំគាល់ថាអាត្មា រុងរឿងដោយគុណបរិសុទ្ធ ។
ដែកាន់អាសិរិស គឺចិត្តទ្រឹស្តដ៏មោះមុត
កាន់ខុសផ្លូវសម្មុទ្ទ មិនលើកលាកលះបង់ប្រាណ។
ទ្រង់ឈ្នះដោយពិធី ឱសថវិសេសសម្រាន្ត
ផ្សំត្រូវគាប់សន្តាន គឺព្រះញាណប្រោសទេសនា ។
ជ័យមង្គល ចូរមានដល់អ្នកពល់គ្នា
ដោយតេជៈជយា ឈ្នះព្រហ្មឥតមានហ្មង ។

ឯតាបិ ពុទ្ធជយមង្គលអដ្ឋគាថា

យោ វាចនោ ទិនទិនេ សរតេ មតន្ទី
ហិត្វាន នេកវិវិធានិ ចុបទ្ទវានិ មោក្ខំ
សុខំ អធិគមេយ្យ នរោ សបញ្ញោ

យោ នរោ ជនឯណា កបបញ្ញាប្រាសក្តីខ្ជិល
ឧស្សាហ៍សាងទានសីល សូត្ររំលឹកព្រះធម៌ថ្ងៃ ។
គាថាប្រាំបីបទ នេះកំណត់ឈ្មោះពុទ្ធជ័យ
ទំសូត្រសព្វៗថ្ងៃ កើតមង្គលជានិរន្តរ៍ ។
សោ នរោ រីជននោះ បានរំដោះរោគអាសន្ន
ឧបទ្រពអនេកលន់ មានប្រការផ្សេងៗផង ។
នឹងដល់ធម៌ក្សេមក្សាន្ត គឺនិព្វានសុខកន្ទង
លែងទុក្ខទាំងប្អូនកង ដោយពុទ្ធជយមង្គលនេះ ៕

ព្រះពុទ្ធ ២៨ ព្រះអង្គ

នមោ មេ សព្វពុទ្ធានំ ឧប្បន្នានំ មហេសិនំ

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំចំពោះព្រះពុទ្ធ
ជាម្ចាស់គ្រប់ព្រះអង្គ ដែលបានត្រាស់រួចមកហើយ
ព្រះអង្គស្វែងរកនូវគុណដ៏ធំ ព្រះសម្ពុទ្ធទាំងនោះគឺៈ

១- តណ្ហង្ករោ មហាវីរោ

ព្រះតណ្ហង្ករ ព្រះអង្គមានព្យាយាមធំ

២- មេធង្ករោ មហាយសោ

ព្រះមេធង្ករ ព្រះអង្គមានយសធំ

៣- សរណង្ករោ លោកហិតោ

ព្រះសរណង្ករ ព្រះអង្គធ្វើឲ្យជាប្រយោជន៍ដល់សត្វលោក

៤- ទីបង្ករោ ជុតិន្ធរោ

ព្រះទីបង្ករ ព្រះអង្គទ្រទ្រង់នូវបញ្ញាដ៏រុងរឿង

៥- កោណ្ឌញ្ញោ ជនប្បមោក្ខោ

ព្រះកោណ្ឌញ្ញ ព្រះអង្គជាប្រធាននៃពពួកជន

៦- មង្គលោ បុរិសាសភោ

ព្រះមង្គល ព្រះអង្គជាបុរសដ៏ប្រសើរ

៧- សុមនោ សុមនោ ធីរោ

ព្រះសុមន ព្រះអង្គជាអ្នកប្រាជ្ញមានព្រះហឫទ័យដ៏ល្អ

៨- រេវតោ រតិវឌ្ឍនោ

ព្រះរេវត ព្រះអង្គញុំាងសេចក្ដីត្រេកអរឲ្យចំរើន

៩- សោភិតោ គុណសម្បន្នោ

ព្រះសោភិត ព្រះអង្គបរិបូណ៌ដោយព្រះគុណ

១០-អនោមទស្សី ជនុត្តមោ

ព្រះអនោមទស្សី ព្រះអង្គឧត្តមជាងពពួកជន

១១-បទុមោ លោកបជ្ជោតោ

ព្រះបទុម ព្រះអង្គញុំាងលោកឲ្យភ្លឺស្វាង

១២-នារទោ វរសារថី

ព្រះនារទ ព្រះអង្គដូចជាសារថីដ៏ប្រសើរ

១៣-បទុមុត្តរោ សត្តសារោ

ព្រះបទុមុត្តរ ព្រះអង្គជាខ្លឹមសារនៃពពួកសត្វ

១៤-សុមេធោ អប្បដិបុគ្គលោ

ព្រះសុមេធ ព្រះអង្គរកបុគ្គលប្រៀបដូចគ្មាន

១៥-សុជាតោ សព្វលោកគ្គោ

ព្រះសុជាត ព្រះអង្គប្រសើរលើសជាងសត្វលោកទាំងពួង

១៦-បិយទស្សី នរាសភោ

ព្រះបិយទស្សី ព្រះអង្គប្រសើរជាងនរជន

១៧-អត្ថទស្សី ការុណិកោ

ព្រះអត្ថទស្សី ព្រះអង្គប្រកបដោយករុណា

១៨-ធម្មទស្សី តមោនុទោ

ព្រះធម្មទស្សី ព្រះអង្គបន្ទោបង់នូវងងឹត

១៩-សិទ្ធត្ថោ អសមោ លោកេ

ព្រះសិទ្ធត្ថ ព្រះអង្គឥតមានអ្នកណាស្មើក្នុងលោក

២០-តិស្សោ ចវទតំវរោ

ព្រះតិស្សព្រះអង្គប្រសើរជាងអ្នកប្រាជ្ញខាងសំដីទាំងឡាយ

២១-ផុស្សោ ច វរទោ ពុទ្ធោ

ព្រះពុទ្ធទ្រង់ព្រះនាមផុស្ស ព្រះអង្គប្រទានទូវធម៌ដ៏ប្រសើរ

២២-វិបស្សី ច អនូបមោ

ព្រះវិបស្សី ព្រះអង្គឥតមានអ្នកណាប្រៀបផ្ទឹមបានឡើយ

២៣-សិខី សព្វហិតោ សត្ថា

ព្រះសិខី ព្រះអង្គជាគ្រូប្រៀនប្រដៅធ្វើឲ្យជាប្រយោជន៍ដល់សត្វទាំងពួង

២៤-វេស្សភូ សុខទាយកោ

ព្រះវេស្សភូ ព្រះអង្គប្រទានទូវសេចក្ដីសុខ

២៥-កកុសន្ធោ សត្ថវាហោ

ព្រះកកុសន្ធ ព្រះអង្គនាំសត្វចេញចាកផ្លូវឆ្ងាយដាច់ស្រយាល គឺកិលេស

២៦-កោនាគមនោ រណញ្ជហោ

ព្រះកោនាគមន ព្រះអង្គបំបាត់បង់នូវសត្រូវគឺកិលេស

២៧-កស្សបោ សិរិសម្បន្នោ

ព្រះកស្សប ព្រះអង្គបរិបូណ៌ដោយសិរី

២៨-គោតមោ សក្យបុង្គវោ

ព្រះគោតម ព្រះអង្គប្រសើរចម្បងជាងពួកសក្យរាជ ។

បារមីធម៌ ៣០

-ឥតិបិទាន បារមី សម្បន្នោ សោ ភគវា
-ឥតិបិទាន ឧបបារមី សម្បន្នោ សោ ភគវា
-ឥតិបិទាន បរមត្ថបារមី សម្បន្នោ សោ ភគវា

+ឥតិបិសីល បារមី សម្បន្នោ សោ ភគវា
+ឥតិបិសីល ឧបបារមី សម្បន្នោ សោ ភគវា
+ឥតិបិសីល បរមត្ថបារមី សម្បន្នោ សោ ភគវា

-ឥតិបិនេក្ខម្ម បារមី សម្បន្នោ សោ ភគវា
-ឥតិបិនេក្ខម្ម ឧបបារមី សម្បន្នោ សោ ភគវា
-ឥតិបិនេក្ខម្ម បរមត្ថបារមី សម្បន្នោ សោ ភគវា

+ឥតិបិបញ្ញា បារមី សម្បន្នោ សោ ភគវា

+ឥតិបិបញ្ញា ឧបបារមី សម្បន្នោ សោ ភគវា
+ឥតិបិបញ្ញា បរមត្ថបារមី សម្បន្នោ សោ ភគវា

-ឥតិបិវីរិយ បារមី សម្បន្នោ សោ ភគវា
-ឥតិបិវីរិយ ឧបបារមី សម្បន្នោ សោ ភគវា
-ឥតិបិវីរិយ បរមត្ថបារមី សម្បន្នោ សោ ភគវា

+ឥតិបិខន្តិ បារមី សម្បន្នោ សោ ភគវា
+ឥតិបិខន្តិ ឧបបារមី សម្បន្នោ សោ ភគវា
+ឥតិបិខន្តិ បរមត្ថបារមី សម្បន្នោ សោ ភគវា

-ឥតិបិសច្ច បារមី សម្បន្នោ សោ ភគវា
-ឥតិបិសច្ច ឧបបារមី សម្បន្នោ សោ ភគវា
-ឥតិបិសច្ច បរមត្ថបារមី សម្បន្នោ សោ ភគវា

+ឥតិបិអធិដ្ឋាន បារមី សម្បន្នោ សោ ភគវា
+ឥតិបិអធិដ្ឋាន ឧបបារមី សម្បន្នោ សោ ភគវា
+ឥតិបិអធិដ្ឋាន បរមត្ថបារមី សម្បន្នោ សោ ភគវា

-ឥតិបិមេត្តា បារមី សម្បន្នោ សោ ភគវា
-ឥតិបិមេត្តា ឧបបារមី សម្បន្នោ សោ ភគវា
-ឥតិបិមេត្តា បរមត្ថបារមី សម្បន្នោ សោ ភគវា

+ឥតិបិឧបេក្ខា បារមី សម្បន្នោ សោ ភគវា
+ឥតិបិឧបេក្ខា ឧបបារមី សម្បន្នោ សោ ភគវា
+ឥតិបិឧបេក្ខា បរមត្ថបារមី សម្បន្នោ សោ ភគវា

-+- ឥតិបិ សមតឹ បារមី សម្បន្នោ សោ ភគវា តិ -+-

ឯតទគ្គបាលី - ប្រែ

---+++---

ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ :

១+ រត្តញ្ញូនំ យទិទំ អញ្ញាកោណ្ឌញ្ញោ

-- កំពូលឯតទគ្គភិក្ខុ ដែលបានត្រាស់ដឹងធម៌ និង បានបួសមុនគេ ។

២+ មហាបញ្ញានំ យទិទំ សារីបុត្តោ

-- កំពូលឯតទគ្គភិក្ខុ ដែលមានបញ្ញា ។

៣+ ឥទ្ធិមន្តានំ យទិទំ មហាមោគ្គល្លានោ

-- កំពូលឯតទគ្គភិក្ខុ ដែលមានឫទ្ធិ ។

៤+ ធុតវាទានំ យទិទំ មហាកស្សបោ

-- កំពូលឯតទគ្គភិក្ខុ ដែលពោលពាក្យកំចាត់បង់នូវកិលេស ។

៥+ ទិព្វចក្ខុកានំ យទិទំ អនុរុទ្ធោ

-- កំពូលឯតទគ្គភិក្ខុ អ្នកមានទិព្វចក្ខុ (ភ្នែកទិព្វ) ។

៦+ ឧច្ចាកុលិកានំ យទិទំ ភទ្ទិយោ កាឡិគោធាយបុត្តោ

-- កំពូលឯតទគ្គភិក្ខុ ដែលមានត្រកូលខ្ពង់ខ្ពស់ ។

៧+ មញ្ជុស្សរានំ យទិទំ លកុណ្ឌកភទ្ទិយោ

-- កំពូលឯតទគ្គភិក្ខុ ដែលមានសំឡេងពីរោះ ។

៨++ សីហនាទិកានំ យទិទំ បិណ្ឌោលភារទ្វាជោ

--- *កំពូលភិក្ខុ ដែលជាអ្នកបន្លឺសីហនាទ ។*

៩++ ធម្មកថិកានំ យទិទំ បុណ្ណោ មន្តានីបុត្តោ

--- *កំពូលភិក្ខុ ដែលជាធម្មកថិក (សំដែងធម៌) ។*

១0+ សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ វិភជន្តានំ

+ យទិទំ មហាកច្ចានោ

--- *កំពូលភិក្ខុ អាចចែកសេចក្តីធម៌ ដែលព្រះ*

---- *តថាគត សំដែងដោយសង្ខេប ឲ្យពិស្តារបាន ។*

(វគ្គោ បឋមោ)

១១+ ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ

+++ មនោមយំ កាយំ អភិនិម្មិនន្តានំ យទិទំ ចុល្លបន្ថកោ

--- *កំពូលភិក្ខុ អ្នកនិមិត្តកាយបានតាមចិត្តប្រាថ្នា ។*

+++ ចេតោវិវដ្ដកុសលានំ យទិទំ ចុល្លបន្ថកោ

--- *កំពូលភិក្ខុ អ្នកឈ្លាសក្នុងការបើកចិត្ត (ប្រើចិត្ត) ។*

១២+ បញ្ញាវិវដ្ដកុសលានំ យទិទំ មហាបន្ថកោ

--- *កំពូលភិក្ខុ អ្នកឈ្លាសក្នុងការបើកប្រាជ្ញា (ប្រើប្រាជ្ញា) ។*

១៣+ អរណវិហារីនំ យទិទំ សុភូតិ

--- *កំពូលភិក្ខុ អ្នកនៅដោយឥតកិលេស ។*

+++ ទក្ខិណេយ្យានំ យទិទំ សុភូតិ

--- កំពូលភិក្ខុ អ្នកគួរដល់ទក្ខិណាទាន ។

១៤+ អារញ្ញកានំ យទិទំ រេវតោ ខទិរវនិយោ

--- កំពូលភិក្ខុ ខាងរស់នៅក្នុងព្រៃ (យកព្រៃជាវត្ត) ។

១៥+ ឈាយីនំ យទិទំ កង្ខារេវតោ

--- កំពូលភិក្ខុ អ្នកបានឈាន ។

១៦+ អារទ្ធវីរិយានំ យទិទំ សោណោ កោលិវិសោ

--- កំពូលភិក្ខុ អ្នកមានព្យាយាមបរិបូណ៌ ។

១៧+ កល្យាណ វាក្ករណានំ យទិទំ សោណោ កុដិកណ្ណោ

--- កំពូលភិក្ខុ អ្នកពោលពាក្យពីរោះ (សំដែងធម៌) ។

១៨+ លាភីនំ យទិទំ សីវលី

--- កំពូលភិក្ខុ អ្នកមានលាភច្រើន ។

១៨+ សទ្ធាធិមុត្តានំ យទិទំ វក្កលីតិ

---- កំពូលភិក្ខុ អ្នកមានសទ្ធាស៊ប់ ។

(វគ្គោ ទុតិយោ)

១៩+ ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ សិក្ខាកាមានំ យទិទំ រាហុលោ

--- កំពូលភិក្ខុ អ្នកស្រឡាញ់ការសិក្សា ។

២០+ សទ្ធាបព្វជិតានំ យទិទំ រដ្ឋបាលោ

--- កំពូលភិក្ខុ អ្នកបួសដោយសទ្ធា ។

២១+ **បឋមំ សលាកំ គណ្ហន្តានំ យទិទំ កុណ្ឌធានោ**

--- *កំពូលភិក្ខុ អ្នកចាប់ស្លាកបានមុនគេ ។*

២២+ **បដិភាណវន្តានំ យទិទំ វង្គីសោ**

--- *កំពូលភិក្ខុ អ្នកមានការឆ្លាតវៀងវៃ (បដិភាណ) ។*

២៣+ **សមន្តប្បាសាទិកានំ យទិទំ ឧបសេនោ វង្គន្តបុត្តោ**

--- *កំពូលភិក្ខុ អ្នកមានសេចក្តីជ្រះថ្លាគ្រប់គ្រាន់ ។*

២៤+ **សេនាសនបញ្ញាបកានំ យទិទំ ទព្វោមល្លបុត្តោ**

--- *កំពូលភិក្ខុ អ្នករៀបចំក្រាលទីសេនាសនៈ ។*

២៦+ **ទេវតានំ បិយមនាបានំ យទិទំ បិលិន្ទវច្ឆោ**

--- *កំពូលភិក្ខុ អ្នកជាទីស្រឡាញ់ គាប់ចិត្តរបស់ទេវតាទាំងឡាយ ។*

២៧+ **ខិប្បាភិញ្ញានំ យទិទំ ពាហិយោ ទារុចីរិយោ**

--- *កំពូលភិក្ខុ អ្នកត្រាស់ដឹងរហ័ស ។*

២៨+ **ចិត្តកថិកានំ យទិទំ កុមារកស្សបោ**

--- *កំពូលភិក្ខុ អ្នកមានពាក្យសំដីវិចិត្រ ។*

២៩+ **បដិសម្ភិទប្បត្តានំ យទិទំ មហាកោដ្ឋិតោតិ**

--- *កំពូលភិក្ខុ អ្នកបានបដិសម្ភិទា ។*

(វគ្គោ តតិយោ)

៣០+ ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ ពហុស្សុតានំ យទិទំ អានន្ទោ

--- *កំពូលភិក្ខុ អ្នកចេះដឹងច្រើន*

+ សតិមន្តានំ យទិទំ អានន្ទោ

--- *កំពូលភិក្ខុ អ្នកមានស្មារតី*

+ គតិមន្តានំ យទិទំ អានន្ទោ

--- *កំពូលភិក្ខុ អ្នកមានគតិ*

+ ធិតិមន្តានំ យទិទំ អានន្ទោ

--- *កំពូលភិក្ខុ អ្នកមានប្រាជ្ញា*

+ ឧបដ្ឋាកានំ យទិទំ អានន្ទោ

--- *កំពូលភិក្ខុ អ្នកជាឧបដ្ឋាក*

៣១+ មហាបរិសានំ យទិទំ ឧរុវេលកស្សបោ

--- *កំពូលភិក្ខុ អ្នកមានបរិស័ទច្រើន*

៣២+ កុលប្បសាទកានំ យទិទំ កាឡុទាយិ

--- *កំពូលភិក្ខុ អ្នកញុំាងត្រកូលឲ្យជ្រះថ្លា*

៣៣+ អប្បាពាធានំ យទិទំ ពក្កុលោ (ពាកុលោ)

--- *កំពូលភិក្ខុ អ្នកមិនមានអាពាធ*

៣៤+ បុព្វេនិវាសំ អនុស្សរន្តានំ យទិទំ សោភិតោ

--- *កំពូលភិក្ខុ អ្នករឭកឃើញបុព្វេនិវាស (រឭកជាតិ)*

៣៥+ វិនយធរានំ យទិទំ ឧបាលិ

--- *កំពូលភិក្ខុ អ្នកទ្រទ្រង់វិន័យ*

៣៦+ ភិក្ខុនោវាទកានំ យទិទំ នន្ទកោ

--- *កំពូលភិក្ខុ អ្នកឲ្យឱវាទភិក្ខុនី*

៣៧+ ឥន្ទ្រិយេសុ គុត្តទ្វារានំ យទិទំ នន្ទោ

--- *កំពូលភិក្ខុ អ្នករក្សាទ្វារក្នុងឥន្ទ្រិយទាំងឡាយ*

៣៨+ ភិក្ខុឱវាទកានំ យទិទំ មហាកប្បិនោ

--- *កំពូលភិក្ខុ អ្នកឲ្យឱវាទភិក្ខុ*

៣៩+ តេជោធាតុកុសលានំ យទិទំ សាគតោ

--- *កំពូលភិក្ខុ អ្នកឈ្លាសវៃក្នុងតេជោធាតុ*

៤០+ បដិភាណេយ្យកានំ យទិទំ រាធោ

--- *កំពូលភិក្ខុ អ្នកឈ្លាសក្នុងបដិភាណ*

៤១+ លូខចីវរធរានំ យទិទំ មោឃរាជាតិ

--- *កំពូលភិក្ខុ អ្នកទ្រទ្រង់ចីវរសៅហ្មង*

(*វគ្គោ ចតុត្ថោ*)

៤២+ ឯតទគ្គំ ភិក្ខវេ មម សាវិកានំ ភិក្ខុនីនំ រត្តញ្ញូនំ យទិទំ

+++ មហាបជាបតី គោតមី

--- *កំពូលភិក្ខុនី អ្នកត្រាស់ដឹងធម៌ និងបានបួសមុនគេ*

៤៣+ មហាបញ្ញានំ យទិទំ ខេមា

--- *កំពូលភិក្ខុនី អ្នកមានប្រាជ្ញា*

៤៤+ ឥទ្ធិមន្តីនំ យទិទំ ឧប្បលវណ្ណា

--- *កំពូលភិក្ខុនី អ្នកមានឫទ្ធិ*

៤៥+ វិនយធរានំ យទិទំ បដាចារា

--- *កំពូលភិក្ខុនី អ្នកទ្រទ្រង់វិន័យ*

៤៦+ ធម្មកថិកានំ យទិទំ ធម្មទិន្នា

--- *កំពូលភិក្ខុនី អ្នកជាធម្មកថិកា (អ្នកសំដែងធម៌)*

៤៧+ ឈាយិនីនំ យទិទំ នន្ទា

--- *កំពូលភិក្ខុនី ជាអ្នកមានឈាន*

៤៨+ អារទ្ធវីរិយានំ យទិទំ សោណា

--- *កំពូលភិក្ខុនី អ្នកមានព្យាយាម*

៤៩+ ទិព្វចក្ខុកានំ យទិទំ សកុលា

--- *កំពូលភិក្ខុនី អ្នកមានទិព្វចក្ខុ (ភ្នែក ទិព្វ)*

៥០+ ខិប្បាភិញ្ញានំ យទិទំ ភទ្ទាកុណ្ឌលកេសា

----*កំពូលភិក្ខុនីអ្នកបានត្រាស់ដឹងរហ័ស*

៥១+ បុព្វេនិវាសំ អនុស្សរន្តានំ យទិទំ ភទ្ទា កបិលានី

--- កំពូលភិក្ខុនី អ្នករឭកឃើញបុព្វេនិវាស (រឭកជាតិ)

៥២+ មហាភិញ្ញាបត្តានំ យទិទំ ភទ្ទា កច្ចានា

--- កំពូលភិក្ខុនី អ្នកបាននូវអភិញ្ញាធំ

៥៣+ លូខចីវរធរានំ យទិទំ កិសាគោតមី

--- កំពូលភិក្ខុនី អ្នកទ្រទ្រង់នូវចីវរដ៏សៅហ្មង

៥៤+ សទ្ធាធិមុត្តានំ យទិទំ សិគាលមាតា

--- កំពូលភិក្ខុនី អ្នកមានសទ្ធាស៊ប់

វគ្គោ បញ្ចមោ

៥៥+ ឯតទគ្គំ ភិក្ខវេ មម សាវកានំ ឧបាសកានំ បឋមំ សរណំ

+ គច្ឆន្តានំ យទិទំ តបុស្សភល្លិកា វាណិជា

--- កំពូលឧបាសក អ្នកបានដល់នូវសរណគមន៍ មុនគេ

៥៦+ ទាយកានំ យទិទំ សុទត្តោ គហបតិ អនាថបិណ្ឌិកោ

--- កំពូលឧបាសក ជាទាយកអ្នកឲ្យទាន

៥៧+ ធម្មកថិកានំ យទិទំ ចិត្តោ គហបតិ មច្ឆិកសណ្ឌិកោ

--- កំពូលឧបាសក អ្នកសំដែងធម៌ទេសនា (ធម្មកថិក)

៥៨+ ចតូហិ សង្គហវត្ថូហិ បរិសំ សង្គណ្ហន្តានំ យទិទំ ហត្ថកោ

\+ អានន្ទវគ្គោ

--- *កំពូលឧបាសក អ្នកសង្គ្រោះបរិស័ទ ដោយឲ្យសង្គហវត្ថុ៤ប្រការ*

៥៩+ បណីតទាយកានំ យទិទំ មហានាមោ សក្កោ

--- *កំពូលឧបាសក អ្នកឲ្យភោជនមានរសដ៏ឧត្តម*

៦០+ មនាបទាយកានំ យទិទំ ឧគ្គោ គហបតិ វេសាលិកោ

--- *កំពូលឧបាសកនៅក្រុងវេសាលី អ្នកឲ្យភោជនជាទីគាប់ចិត្ត*

៦១+ សង្ឃុបដ្ឋាកានំ យទិទំ ឧគ្គតោ គហបតិ

--- *កំពូលឧបាសក អ្នកបំរើសង្ឃ*

៦២+ អវេច្ចប្បសន្នានំ យទិទំ សូរោ អម្ពដ្ឋោ

--- *កំពូលឧបាសក អ្នកមានសេចក្តីជ្រះថ្លាមិនកំរើក*

៦៣+ បុគ្គលប្បសន្នានំ យទិទំ ជីវកោ កោមារភច្ចោ

--- *កំពូលឧបាសក អ្នកញុំាងបុគ្គលឲ្យជ្រះថ្លា*

៦៤+ វិស្សាសកានំ យទិទំ នកុលបិតា គហបតីតិ

--- *កំពូលឧបាសក អ្នកចេះនិយាយឲ្យអ្នកដទៃជ្រះថ្លា*

វគ្គោ ឆដ្ឋោ

៦៥+ ឯតទគ្គំ ភិក្ខវេ មម សាវិកានំ ឧបាសិកានំ បឋមំ សរណំ

\+ គច្ឆន្តីនំ យទិទំ សុជាតា សេនានិធីតា

--- កំពូលឧបាសិកា   អ្នកដល់នូវសរណគមន៍មុនគេ

៦៦+ ទាយិកានំ យទិទំ វិសាខា មិគារមាតា

--- កំពូលឧបាសិកា   អ្នកជាទាយិកា (អ្នកឲ្យទាន)

៦៧+ ពហុស្សុតានំ យទិទំ ខុជ្ជុត្តរា

--- កំពូលឧបាសិកា   អ្នកចេះដឹងច្រើន

៦៨+ មេត្តាវិហារីនំ យទិទំ សាមាវតី

--- កំពូលឧបាសិកា   អ្នករស់នៅដោយមានមេត្តា

៦៩+ ឈាយីនំ យទិទំ ឧត្តរា នន្ទមាតា

--- កំពូលឧបាសិកា   អ្នកមានឈាន

៧០+ បណីតទាយិកានំ យទិទំ សុប្បវាសា កោលិយធីតា

--- កំពូលឧបាសិកា   អ្នកឲ្យទានដោយផ្ចិតផ្ចង់

៧១+ គិលានុបដ្ឋាកីនំ យទិទំ សុប្បិយា ឧបាសិកា

--- កំពូលឧបាសិកា   អ្នកបំរើជម្ងឺ

៧២+ អវេច្ចប្បសន្នានំ យទិទំ កាតិយានី

--- កំពូលឧបាសិកា   អ្នកជ្រះថ្លាមិនកំរើក

៧៣+ វិស្សាសិកានំ យទិទំ នកុលមាតា គហបតានី

--- កំពូលឧបាសិកា   អ្នកចេះធ្វើឲ្យអ្នកដទៃស្និទ្ធស្នាល

៧៤+ អនុស្សវប្បសន្នានំ យទិទំ កាលី ឧបាសិកា កុររឃរិកាតិ

--- កំពូលឧបាសិកា   អ្នកជ្រះថ្លាតាមពាក្យដែលឮតៗគ្នា ៕

វគ្គោ សត្តមោ



រៀបរៀងដោយ   ភិក្ខុ ធម្មបាលោ (ណុប គ្រុយ)

វត្តវិបស្សនារាម (អៃរ៉ាប់) ឡុង ប៊ិច

បទស្មូត្រដាក់ទង់ព្រះពុទ្ធសាសនា

ក្រុមយើងអ្នកកាន់សាសនា   ត្រូវដឹងច្បាស់ថាព្រះពុទ្ធជិនស្រី
ទ្រង់មានឆណ្ណរង្សី   គឺព្រះរស្មីទាំងប្រាំមួយពណ៌ ។
ផ្សាយចេញពីព្រះកាយទ្រង់   រុងរឿងឫទ្ធិរង្គប្រសើរបវរ
ឆ្មៀលឆ្វាត់កាយឆើតឆាយល្អ   ទាំងប្រាំមួយពណ៌ស្រស់ល្អសោភា។
កំណើតនៃព្រះរស្មី   កើតដោយបារមីនៃព្រះភគវា
ធ្វើទានឥតមានរួញរា   កាលដែលនៅជាព្រះពោធិសត្វ ។
រស្មីពណ៌ខៀវនោះណា   កាលឆ្មៀលនេត្រាទ្រង់ដោយចិត្តកាត់
ធ្វើទានដល់ឥន្ទ្រព្រាហ្មណ៍បាត់   កាលនៅជាក្សត្រនាមស្រីពិរាស្ត្រ ។
រស្មីពណ៌លឿងភ្លឺថ្លា   កាលដែលទ្រង់អារសាច់ដៃធ្វើមាស
បិទពុទ្ធរូបឱភាស   ព្រះឥន្ទជាងមាសទ្រង់វ័យបណ្ឌិត ។
រស្មីក្រហមនោះណា   កាលដែលមាតាពស់ខាំស្លាប់ពិត
បទុមស៊ូប្តូរជីវិត   កាត់បេះដូងបិទធ្វើថ្នាំមាតា ។
រស្មីពណ៌ស-សុទ្ធសាធ   កាលដែលព្រះបាទវេស្សន្តរក្សត្រា
ឲ្យដំរីសសោភា   ដល់ព្រាហ្មណ៍ប្រាថ្នាយកពោធិញ្ញាណ
រស្មីពណ៌ដូចជើងហង្ស   កាលមាតាទ្រង់យក្សចាប់យកបាន
វិជ្ជាធរអារសាច់ប្រាណ   ឲ្យយក្សសាមាន្យស៊ីប្តូរជីវិត ។
រស្មីភ្លឺផ្លេកពណ្ណរាយ   កាលជាទន្សាយឈ្មោះសោមបណ្ឌិត
ឲ្យទានសាច់ឈាមជីវិត   ដល់ឥន្ទព្រាហ្មណ៍គិតជាអាហារ ។
រស្មីខៀវលឿងក្រហម   សហង្សបាទព្រមភ្លឺផ្លេកអស្ចារ្យ
ត្រូវជាប្រាំមួយប្រការ   ទាំងចាស់កុមារចូរចាំទុកអើយ ៕

(ត្រូវស្មូត្រឈរនៅក្រោមទង់ ហើយទាញខ្សែឡើង ពេលដាក់ស្មូត្រទាញខ្សែចុះក្រោម) សម្ដេច ជួន-ណាត

បទលើកទង់ព្រះពុទ្ធសាសនា

សូមមើលទង់ជ័យ ឆព្វណ្ណរង្សី ដែលមានរស្មី ភ្លឺស្រស់ល្អ
ខៀវលឿងក្រហម ព្រមទាំងពណ៌ស ហង្សបាទនិងពណ៌ដ៏ភ្លឺផ្លេក ។
ប្រទេសតូចធំ បានស្ម័គ្រស្មាគម ជំនុំគ្នាច្រើន អនេក
ព្រមយករស្មីព្រះពុទ្ធគួរត្រេក ប្រសើរពន់ពេក ក្រៃកន្លង ។
ធ្វើជាសញ្ញា ទង់ជ័យសាសនា នៃព្រះពុទ្ធធំ ចម្បង
ចូរយើងរាល់គ្នា យកចិត្តចាំចង *នឹកដល់ព្រះពុទ្ធជាអម្ចាស់* ។
ទោះជាតិផ្សេងគ្នា ក៏ត្រូវដឹងថា សុទ្ធសឹងតែជា *ពុទ្ធសាសន៍*
ត្រូវមានសាមគ្គី ទាំងក្មេងទាំងចាស់ ប្រឹងប្រែងឲ្យណាស់គ្រប់ៗគ្នា។
សូមសាសនាពុទ្ធ ចុំថ្កើងខ្ពស់ផុត រុងរឿងបរិសុទ្ធ ថ្លៃថ្លា
ហើយមានជ័យជោគផ្សាយពេញលោកា ដោយជនជ្រះថ្លារាប់ច្រើនលាន។
មានចិត្តស្នេហា គោរពបូជា ចំពោះព្រះធម៌ ដ៏កល្យាណ
ទាំងមនុស្សទេព្តាស្នេហាគ្រប់ប្រាណ ប្រាថ្នាចង់បាន សេចក្តីសុខ ។
យើងខេមរជាតិ នាំគ្នាខ្មីឃ្មាត កាន់ធម៌នឹងបាន ផុតទុក្ខ
រួបរួមសាមគ្គី ពីនេះទៅមុខ យើងនឹងបានសុខក្សេមក្សាន្តត្រាណ
ព្រមព្រៀងប្រព្រឹត្តិ តាមធម៌សុចរិត ឆ្ពោះទៅកាន់ស្ថាន និព្វាន
ជាទីផុតទុក្ខ បានសុខក្សេមក្សាន្ត ជាតិយើងនឹងបានសោយសុខា៕

(ត្រូវសូត្រឈរនៅក្រោមទង់ ហើយទាញខ្សែឡើង ពេលដាក់សូត្រទាញខ្សែចុះក្រោម)

សម្តេច ជួន-ណាត

បទសារភញ្ញ

សូមថ្វាយបង្គំព្រះសម្ពុទ្ធ ប្រសើរបំផុតក្នុងលោកា
ជាគ្រូនៃមនុស្សនិងទេវតា ទ្រង់ត្រាស់ទេសនាប្រដៅសត្វ ។

ចង្អុលឲ្យដើរផ្លូវកណ្ដាល មាគ៌ាត្រកាលអាចកម្ចាត់
ទុក្ខភ័យចង្រៃឲ្យខ្ចាយខ្ចាត់ អាចកាត់សង្សារទុក្ខបាន ។

សាសនាព្រះអង្គនៅសព្វថ្ងៃ សត្វមាននិស្ស័យពីបូរាណ
ប្រឹងរៀនប្រឹងស្ដាប់ចេះចាំបាន កាន់តាមលំអានបានក្ដីសុខ ។

ឥតមានសុខណាស្មើក្ដីស្ងប់ បញ្ចប់ត្រឹមសុខឃ្លាតចាកទុក្ខ
តាំងពីលោកនេះតទៅមុខ ក្ដីសុខកើតមានព្រោះធម៌ស្ងប់។

ខ្ញុំសូមបង្គំឆ្ពោះព្រះធម៌ ព្រះសង្ឃបវរទាំងសព្វគ្រប់
រួមជាត្រ័យរត្នគួរគោរព ជាម្លប់ត្រជាក់នៃលោកា ។

ព្រះរូបព្រះធាតុនៃព្រះពុទ្ធ វិសុទ្ធតាងអង្គព្រះសាស្ដា
សូមគុណត្រ័យរត្នជួយខេមរា ឲ្យបានសុខាតរៀងទៅ ។

បទថ្វាយផ្កាបូរាណ

យើងខ្ញុំមានចិត្តត្រេក　　អរពន់ពេកកើតជ្រះថ្លា
នាំគ្នាបូជាផ្កា　　ថ្វាយសាស្ដាដោយគោរព ។
ដើម្បីយកផលា　　និងលោះលាខ្លួនចាកភព
ចាកភ័យចាកឧបទ្រព　　ដោយសារម្លប់បុណ្យសាសនា។
ទើបបេះយកផ្កាឈើ　　មកក្រងធ្វើភ្ញួងមាលា
មានពណ៌ក្លិនផ្សេងគ្នា　　សូមបូជាថ្វាយព្រះពុទ្ធ ។
ព្រះធម៌និងព្រះសង្ឃ　　ប្រសើរអង្គសីលបរិសុទ្ធ
ត្រ័យរតន៍នេះខ្ពស់ផុត　　ដែលជាបុណ្យលោកទាំងបី ។
ខ្ញុំម្ចាស់ទាំងអស់គ្នា　　តែងកំព្រាទាំងប្រុសស្រី
ព្រាត់ប្រាសក្នុងលោកិយ　　ព្រាត់ស្វាមីព្រាត់ភរិយា ។
តែងជួបនឹងឈឺចាប់　　និងក្ដីស្លាប់ជាធម្មតា
មានក្ដីទុក្ខក្ដៅផ្សា　　រកអ្នកណាជួយពុំបាន ។
ដោយតេជះបូជា　　ភ្ញួងមាលាល្អកល្យាណ
ត្រ័យរតន៍ទាំងបីឋាន　　សូមឲ្យបានផុតទោសទុក្ខ ។
ផុតចាស់ផុតឈឺចាប់　　ផុតក្ដីស្លាប់តទៅមុខ
សូមឲ្យខ្ញុំបានសុខ　　ក្នុងសម្បត្តិព្រះនិព្វាន ។
ពាក្យពោលប៉ងប្រាថ្នា　　ធ្វើសច្ចាប្រណិធាន
សូមមគ្គផលនិព្វាន　　ឲ្យខ្ញុំបានប្រាកដហោង ៕

បទថ្វាយផ្កាបូរាណ

យើងខ្ញុំមានចិត្តត្រេក អរពន់ពេកកើតជ្រះថ្លា
នាំគ្នាបូជាផ្កា ថ្វាយត្រ័យរ័ត្នដោយគោរព ។
យើងខ្ញុំយកផ្កាឈើ មកក្រងធ្វើភួងមាលា
មានព័ណផ្សេងៗគ្នា សូមបូជាថ្វាយព្រះពុទ្ធ ។
ព្រះធម៌និងព្រះសង្ឃ ប្រសើរអង្គសិលបរិសុទ្ធ
ត្រ័យរ័ត្ននេះខ្ពស់ផុត ដែលជាម្កុដលោកទាំងបី ។
ដោយតេជៈខ្ញុំបូជា ភួងមាលាល្អកល្យាណ
សូមសុខសួគ៌និព្វាន ប្រាកដមានដល់យើងហោង ។

❋ ថ្វាយជយឃោសដល់ព្រះអង្គបានត្រាស់ដឹង ❋

★ ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ មារស្ស ច បាបិមតោ បរាជយោ ឧគ្ឃោ សិយុំ បមោទិតោ ពោធិមណ្ឌេ នាគគណា សុបណ្ណគណា ជយំតទា មហេសិនោ ។

⁂ ពេលនោះ ពួកនាគទាំងឡាយផង ពួកគ្រុឌទាំងឡាយផង មកជុំគ្នាហើយ ត្រង់ពោធិមណ្ឌល មានចិត្តជ្រះថ្លា ត្រេកអររីករាយ ថ្វាយទិព្វបុប្ផ ថ្វាយព្រះពរជ័យ ដល់ព្រះ-មហេសី គឺព្រះអង្គទ្រង់ស្វែងរកគុណដ៏ធំ យ៉ាងនេះថា ។

⁂ព្រះពុទ្ធដ៏មានសិរី ព្រះអង្គឈ្នះមារហើយ មារមានចិត្តបាប ចាញ់ព្រះអង្គហើយ ។

សូមអនុមោទនា ៗ ៗ ៗ

※ **ជយោ** ហិ ពុទ្ធស្ស សិរីមតោ អយំ មារស្ស ច បាបិមតោ ពោធិមណ្ឌេ ទេវគណា ព្រហ្មគណា ជយំតទា មហេសិនោ ។

※ពេលនោះ ពួកទេវតាទាំងឡាយផង ពួកព្រហ្មទាំង-ឡាយផង (ទាំងហ្មឺនចក្រវាឡ) មកជុំគ្នា ត្រង់ពោធិមណ្ឌល មានចិត្តត្រេកអរ រីករាយ ថ្វាយទិព្វបុប្ផ ថ្វាយព្រះពរជ័យ ដល់ព្រះមហេសី គឺព្រះអង្គទ្រង់ស្វែងរកគុណដ៏ធំយ៉ាង នេះថា ។

※ ព្រះពុទ្ធដ៏មានសិរី ព្រះអង្គឈ្នះមារហើយ មារមាន ចិត្តបាប ចាញ់ព្រះអង្គហើយ ។

សូមអនុមោទនា ៗ ៗ ៗ

⁕ **ជយោ** ហិ ពុទ្ធស្ស សិរីមតោ អយំ មារស្ស ច បាបិមតោ បរាជយោ ។

⁕ ពេលនោះ យើងខ្ញុំព្រះអង្គទាំងឡាយ មកជុំគ្នាហើយ (ក្នុងឧបដ្ឋានសាលានៃ វត្ត **ទិបស្សនារាមនេះ**) មានចិត្តជ្រះថ្លាដ៏ក្រៃលែង បាននាំមកនូវគ្រឿងសក្ការៈទាំងឡាយ មានផ្កាកម្រង គ្រឿងក្រអូប និងគ្រឿងប្រទីបជាដើម មកតម្កល់ទុកក្នុងទីនេះ ដើម្បីបូជាចំពោះព្រះរតនត្រៃ បពិត្រព្រះដ៏មានព្រះភាគដ៏ចម្រើនអើយ សូមព្រះអង្គមេត្តាអនុគ្រោះ ទទួលយកនូវគ្រឿងសក្ការៈទាំងឡាយ មានផ្កាកម្រង និងគ្រឿងក្រអូបជាដើម របស់យើងខ្ញុំព្រះអង្គទាំងឡាយ ដើម្បីសេចក្ដីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់លោកអ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់គ្រូឧបជ្ឈាយាចារ្យទាំងឡាយផង ដល់សព្វសត្វទាំងឡាយផង ដល់យើងខ្ញុំព្រះអង្គទាំងឡាយផងអស់កាលជាអង្វែងទៅហោង។ សូមថ្វាយព្រះពរជ័យដល់ព្រះអង្គ យ៉ាងនេះថា ព្រះពុទ្ធដ៏-មានសិរី ព្រះអង្គឈ្នះមារហើយ មារមានចិត្តបាប ចាញ់ព្រះអង្គហើយ **សូមអនុមោទនា** ៗ ៗ ៗ ។

ធម្មនិយាម ៣០ របស់ព្រះពុទ្ធគ្រប់ព្រះអង្គ

សូមក្រាបបង្គំប្រណម្យវន្ទា ឆ្ពោះព្រះភគវាពុទ្ធាបានត្រាស់
ធម្មនិយាមទំនៀមល្អល្អះ សាមសិបមុខច្បាស់ខ្ញុំសូមពណ៌នា។
មួយ រញ្ជួយភពជាតិគ្រប់ចុងក្រោយ បារមីនាំឲ្យដឹងពេលវេលា
ទ្រង់យាងកាន់ផ្ទៃស្មារតីល្អជា ដឹងខ្លួនគ្រប់គ្រាក្នុងគភ៌មាតា ។
ពីរ គឺព្រះភក្ត្រវរល័ក្ខណ៍ក្នុងគភ៌ ស្ទឹងស្មាធិ៍ក្នុងធម៌បវរកាយា
ព្រះភ័ក្ត្របែរផ្ទុយពីខ្នងមាតា ឆ្ពោះផ្ទៃភ្លឺថ្លាមាតារំពៃ ។
បី តិរិយាបថនៃព្រះមាតា ពេលគ្រប់មាសាសាស្ដាចាកផ្ទៃ
មាតាទ្រង់ឈរខុសស្រីដទៃ ប្រសូតបុត្រថ្លៃហឫទ័យជ្រះថ្លា ។
បួន សួនឧទ្យានទីឋានប្រសូត ក្នុងផ្ទៃរហូតឈើស្រូតចេញផ្កា
ទេវតានិងមនុស្ស ថ្វាយសាធុការ ចក្រវាឡបព្វតាខ្ញ័រខ្ញាររអ៊ូអរ ។
ប្រាំ ព្រះប្រសូតចុះស្រូតយាងឈាន ប្រាំពីរជំហានឆ្ពោះទិសឧត្តរ
ត្រួតគ្រប់ទិសឋានក្លាហានបវរ ទើបបានបន្ទបន្លឺសីហនាទ ។
ប្រាំមួយ ប្រមើលទតមើលនិមិត្ត ទេវទូតបួនពិតចិត្តគិតលះញាតិ
បុត្រកើតថ្ងៃណាថ្ងៃនោះទ្រង់ឃ្លាត ចិត្តឥតរវាតយាត្រាសាងផ្នួស ។
ប្រាំពីរ ធីរោ ផ្ដាច់ផ្លូវព្យាយាម ឥតមានទាក់ទាមក្នុងនាមអ្នកបួស
កំណាត់វេលាមិនអាចតិចហួស ប្រាំពីរថ្ងៃនោះនឹងបានត្រាស់ដឹង ។
ប្រាំបី មហេសីគង់សោយបាយាស ក្នុងថ្ងៃបានត្រាស់ទ្រង់ច្បាស់ទីពឹង
បាយាសថាសមាសថ្វាយព្រះថ្ងៃហ្នឹង ហៅបាយត្រាស់ដឹងបានបុណ្យមហិមា។

ឆ្នាំបួន ជូនភ័ព្វទ្រង់ទ្រាប់ស្បូវភ្លាំង   ក្លាយជាបល្ល័ង្កគង់តាំងភាវនា
នៅគល់ពោធិព្រឹក្សនាទិសបូព៌ា   ទេពធីតាមារមកគ្រាសាយ័ណ្ហ ។
ដប់ គាប់ហឫទ័យអានាបាណៈ   បរិកម្មប្រច័ក្សសតិដឹងទាន់
ខ្យល់ចេញខ្យល់ចូលចិត្តមូលមិនកាន់   ដំណើរជវ័នជាន់ឆ្លងកាមា ។
ដប់មួយ ជំនួយពីព្រះបារមី   ផ្ចាញ់មារអប្រិយព្រមទាំងសេនា
ពុទ្ធប្បវត្តិត្រង់នេះអស្ចារ្យ   បរិស័ទជ្រះថ្លាបាចផ្កាអភិសេក ។
ដប់ពីរ មុនីអង្គទ្រង់សម្រេចញាណ   ត្រៃវិជ្ជាមានទ្រង់ញាណអនេក
ពិសាខបុណ្ណមីកើតញាណប្លែកៗ   ពោធិញ្ញាណខ្ពស់ឯកកក្រើកធរណី ។
ដប់បី ក្យត្រថ្លៃគង់ក្នុងមហាឋាន   វិមុត្តិក្សេមក្សាន្តអស់ឋានប្រាំពីរ
សប្តាហ៍ឋានមួយលើកសួយឋានទី   ចេតិយព្រះមុនីប្រាំពីរកន្លែង ។
ដប់បួន ជូនព្រហ្មជុំអារាធនា   សូមព្រះភគវាយាងត្រាស់សម្តែង
ព្រះធម៌ប្រពៃវិស័យសូរ្យសែង   ទ្រង់ព្រមសម្តែងដោយព្រហ្មវិហារ ។
ដប់ប្រាំ ចាំច្បាស់ទ្រង់ត្រាស់ធម្មចក្ក   ឥសិបតនៈព្រៃមិគទាយា
បានត្រៃរតនៈអាសាឡ្ហបូជា   ថ្ងៃព្រះភគវា ស្ថាបនា ព្រះសង្ឃ ។
ដប់ប្រាំមួយ ទ្រង់គង់ត្រាស់ឱវាទ   បដិមោក្ខ ស្អាងស្អាត ឱវាទផូរផង់
បេះដូង ព្រះធម៌ ពន្លឺ ចតុរង្គ   ថ្ងៃនោះ ត្រូវត្រង់ មាឃបុណ្ណមី ។
ដប់ប្រាំពីរ ទ្រង់គង់វត្តជេតពន   ប្រោសដល់មហាជននិរន្តរ៍ប្រក្រតី
ទ្រង់យកអរុណ ជេតពន សួស្តី   ជេតពនជិនស្រីអាស្រ័យជានិច្ច ។
ដប់ប្រាំបី ទ្រង់សម្តែងបាដិហារ្យ   យមកៈអស្ចារ្យនិគ្រន្ថរត់គេច
នៅក្រុងសាវត្ថីប្រុសស្រីមិនតិច   នេះគឺពុទ្ធកិច្ចសង្គ្រោះលោកា
ដប់ប្រាំបួន ទ្រង់គង់ឋានត្រៃត្រិង្ស   គ្រេះរិះរំពឹងថ្លឹងគុណមាតា
សម្តែងអភិធម្មស័ក្តិសមអស្ចារ្យ   ថ្វាយព្រះមាតាសុខាអមតៈ ។

ថ្ងៃ គឺព្រះអង្គទ្រង់ចាកទេវលោក   ស្តេចយាងចុះមកដែនសង្កស្ស:
មហាជនច្រើនពិតយកចិត្តទុកដាក់   បូជាគារវៈអចលចេតិយ ។
ថ្ងៃមួយ គឺទ្រង់គង់ក្នុងសមាបត្តិ   ព្រះញាណស្ងប់ស្ងាត់លះកាត់លោកិយ
អរហត្តផលតម្កល់ប្រក្រតី   ឆាប់ក្តីយូរក្តីវិស័យពុទ្ធញ្ញាណ ។
ថ្ងៃពីរ ប្រមើលមើលគ្រប់វេនេយ្យ   ឧបនិស្ស័យសព្វសត្វដែលមាន
ដោយព្រះករុណាសមាបត្តិញ្ញាណ   ត្រួតសត្វកោដិលានមានពីរវារៈ ។
ថ្ងៃបី ទ្រង់លៃវិន័យអាជ្ញា   បញ្ញត្តសិក្ខាតាមការជ្រាបជាក់
មានរឿងកើតមុនខូចគុណសាវ័ក   មានហេតុជាក់លាក់ទើបដាក់វិន័យ ។
ថ្ងៃបួន អង្រួនហឫទ័យករុណា   ជាតកទេសនាសាស្តាលកលៃ
ដើមរឿងជាហេតុបង្កើតអត្ថន័យ   ជាតកប្រពៃលៃតាមហេតុការណ៍ ។
ថ្ងៃប្រាំ ទ្រង់ប្រោសដល់ពួកព្រះញាតិ   អង្គព្រះលោកនាថសម្តែងបាដិហារ្យ
កម្ចាត់មានះព្រះញាតិវង្សា   ទើបត្រាស់ទេសនាគម្ពីរពុទ្ធវង្ស ។
ថ្ងៃប្រាំមួយ ទ្រង់គង់ធូន់ក្នុងធម៌   បរិស័ទណាល្អមានធម៌ទ្រទ្រង់
ស្តេចយាងទទួលស្រុះស្រួលដោយអង្គ   គារវៈផូរផង់ឆ្ពោះត្រង់ព្រះធម៌ ។
ថ្ងៃប្រាំពីរ ទ្រង់គង់ចាំវស្សា   បើមាននរណានិមន្តដោយល្អ
ពេលចេញវស្សាមុនយាងចេញចរ   ទ្រង់ចម្រើនពរត្រាស់លាអ្នកនោះ ។
ថ្ងៃប្រាំបី ទ្រង់គង់យ៉ាងហ្មត់ចត់   មុនភត្តក្រោយភត្តគ្មានភ្លាត់ភ្លេចសោះ
បំពេញពុទ្ធកិច្ចគ្រប់យាមទាំងអស់   ពុទ្ធកិច្ចសង្គ្រោះមនុស្សនិងទេវតា ។
ថ្ងៃប្រាំបួន ទ្រង់គង់សោយមំសៈ   ក្នុងថ្ងៃទ្រង់ដាក់អនុដ្ឋានកាយា
បិណ្ឌបាតចុងក្រោយជាទានថ្លៃថ្លា   សោយរសមំសាហឫទ័យបរិសុទ្ធ ។
សាមសិប អវសានទ្រង់បានចូលឈាន   មុននឹងនិព្វានឈានច្រើនបំផុត
ម្ភៃបួនសែនកោដិសមាបត្តិបរិសុទ្ធ   រួចហើយទ្រង់ផុតរលត់សង្ខារ ។

អរហំ រីខ្ញុំបង្គំវន្ទា

ឆ្ពោះព្រះភគវាព្រះធម៌ថ្លៃថ្លា
ព្រមទាំងព្រះសង្ឃផ្លូវផង់សីលា
ចិន្តាលំអុតព្រះពុទ្ធនិយាម ។
សូមឲ្យសព្វសត្វបដិបត្តិតាមធម៌
សាសនាបវរល្អដូចព្រះនាម
អរហំសម្មាគ្មានការទាក់ទាម
កិលេសរវាមរវាតសូន្យបង់ ។
សូមឲ្យសាសនាសម្មាសម្ពុទ្ធ
បរិសុទ្ធមោះមុតរួមចិត្តទ្រទ្រង់
ឋិតថេរចិរកាលអភិបាលដោយសង្ឃ
ព្រមព្រៀងស្មោះត្រង់ផ្ចិតផ្ចង់សិក្ខា ។
សូមមនុស្សទេវតាមានការគោរព
ទាំងថ្ងៃទាំងយប់ក្នុងព្រះសាសនា
សូមបានសម្រេចដូចក្តីប្រាថ្នា
អស់នូវតណ្ហាទុក្ខាចប់ហោង ។

គោតមប្រវត្តិ

ខ្ញុំសូមថ្វាយវន្ទា ព្រះសាស្តាដ៏មានបុណ្យ
និងសូមគោរពគុណ គ្រាព្រះអង្គចុះចាកឋាន ។
មកចាប់ផ្ទៃមាតា ស្រីស្រីម្ហាស្រស់កល្យាណ
កាលណោះមហាជនបាន សុខក្សេមក្សាន្តព្រោះបារមី ។
ក្នុងថ្ងៃព្រហស្បតិ៍អា- សាធមាសពេញបូរមី
រកាផ្ទាំឆ្នាំថ្មី សុខសិរីជល់ជនា ។
កាលបានដប់ខែហើយ ព្រះគុណអើយកើតអស្ចារ្យ
នៅនាដងព្រឹក្សា ឈ្មោះហៅថាព្រៃសាលវ័ន ។
កក្រើកផែនពសុធា មានទេវតារាប់រយពាន់
ស្ថិតនៅក្នុងដំបន់ នៃឧទ្យានលុម្ពិនី ។
ឆ្នាំចពិសាខនា ថ្ងៃសុខថាពេញបូរមី
ថ្ងៃនោះព្រះជិនស្រី ទ្រង់ប្រសូត្រឥតមានព្រួយ ។
កាលសិទ្ធត្ថក្សត្រា មានវស្សាដប់ប្រាំមួយ
បិតាបានលើកសួយ អភិសេកនឹងស្រីម្ហា ។
នារីស្រស់កល្យាណ អ្នកផងបានស្គាល់គ្រប់គ្នា
ថាឈ្មោះនាងពិម្ពា ស្រស់សោភាលើសលែងក្រៃ ។
កាលនោះក្នុងឆ្នាំឆ្លូវ ត្រូវថ្ងៃសៅរ៍មានសេរី
អាសាធពេញបូរមី ក្សត្រាថ្លៃបានសុខា ។

ស្តេចមានព្រះរាជបុត្រ　　បរិសុទ្ធភក្ត្រស្រស់ថ្លា
គួរឲ្យព្រះរាជា　　ស្តេចជំពាក់ចិត្តពេកក្រៃ ។
តែទ្រង់បានកាត់ផ្តាច់　　ទ្រង់សំរេចព្រះហឫទ័យ
ថាត្រូវកាត់អាល័យ　　ពីបុត្រថ្លៃមួយគ្រាណា ។
បើបិតាបានត្រាស់　　ខិលរហ័សរកបុត្រា
មកប្រោសស្ងួនពុំខា　　ចាកសង្ឃារណាបុត្រថ្លៃ ។
កាលនោះថ្ងៃព្រហស្បតិ៍　　ក្នុងឆ្នាំថោះមានសិរី
អាសាធពេញបូរមី　　ក្សត្រាថ្លៃចេញបព្វជា ។
កាលបានបព្វជាហើយ　　មិនព្រំខើយខំឧស្សាហ៍
ធ្វើទុក្រ្កកិរិយា　　គ្មាននរណាធ្វើដូចអ្វី ។
បានត្រាស់ឆ្នាំរកា　　ពិសាខាពុទ្ធបុណ្ណមី
ថាថ្ងៃព្រះជិនស្រី　　មានសិរីឈ្នះក្រុងមារ ។
ត្រាស់ដឹងបានពីរខែ　　ទ្រង់គាន់គ្គេរប្រោសទេសនា
ប្រោសបញ្ចវគ្គិយា　　នាកណ្តាលដងព្រឹក្សព្រៃ ។
គឺក្នុងឆ្នាំរកា　　អាសាធមាសាបុណ្ណមី
ថ្ងៃសៅរ៍ព្រះជិនស្រី　　ផ្តើមពោលស្តីធម៌ទេសនា ។
ក៏ជាថ្ងៃកំណើត　　សង្ឃបានកើតក្នុងលោកា
សាទ័កព្រះសាស្តា　　មានរហូតដល់សព្វថ្ងៃ ។
នាថ្ងៃមួយនោះណា　　គួរសោកាណាស់ម្ចាស់ថ្លៃ
គឺថ្ងៃព្រះជិនស្រី　　កាត់ព្រះទ័យដាក់សង្ខារ ។

គឺក្នុងថ្ងៃអាទិត្យ ឆ្នាំម្សាញ់ពិតមាឃមេសា
នៅចំពោះមុខមារ នាបាទាលចេតិយ ។
បីខែកន្លងទៅ មិនឈប់នៅយឺនយូរអី
ដល់ថ្ងៃព្រះជិនស្រី ទ្រង់និព្វានចាកលោកា ។
គឺក្នុងឆ្នាំនោះឯង មានការផ្សេងតែមាសា
គឺខែពិសាខនា ថ្ងៃអង្គារពេញបូរមី ។
ដោយអំណាចអានុភាព ដែលខ្ញុំក្រាបថ្វាយចន្ទីយ៍
នឹកគុណព្រះមុនី សូត្រប្រវត្តិព្រះសាស្តា ។
សូមឲ្យសំរេចបុណ្យ ដែលជាគុណល្អថ្លៃថ្លា
អន្ទោលក្នុងសង្សារ សូមប្រាថ្នាជួបបណ្ឌិត ។
សូមជួបព្រះសិរអារ្យ ជាសាស្តាដ៏ពិសិដ្ឋ
សូមចាក់ធ្លុះធម៌ពិត សមដូចចិត្តប្រាថ្នាហោង ៕

អនុមោទនា

--

រក្សាព្រះត្រ័យបិដក

--+++000+++--

++សិក្សាបិដកមរតកព្រះ　　មានជ័យជំនះឈ្នះមោហា
　គឺជាកុសលផ្តល់បញ្ញា　　ឆ្លងវដ្តសំសារឆ្ពោះនិព្វាន ។
++ដូច្នេះយើងត្រូវថែរក្សា　　បិដកថ្លៃថ្លាជាធម្មទាន
　ព្រះធម្មចេតិយប្រាថ្នាញាន　　សាសា្តនៅមានយើងត្រូវប្រឹង ។
++រក្សាបិដកមានគុណក្រៃ　　លក់លៃបែងចែកញែកឲ្យដឹង
　ប្រាំពីរប្រការគិតថ្លឹង　　ល្អម្ល៉ឹងប្រឹងថែខ្មែរមានធម៌ ។
++មួយគឺរក្សាព្រះសាសនា　　មរតកអស្ចារ្យជាពុទ្ធពរ
　ពាក្យពិតពាក្យពុទ្ធសុទ្ធបវរ　　ចេតិយព្រះធម៌ វិ.សុ.អ ។
++ពីរគឺរក្សាព្រះសាស្តា　　វិន័យធម៌អាចិណ្ណទុកដាក់
　ស្ថិតនៅជាគ្រូដ៏សមសក្តិ　　ប្រចក្រធម្មាជាសាស្តា ។
++បីគឺរក្សាការខារសង្ឃ　　ទ្រទ្រង់តម្រង់ព្រះសាសនា
　សង្គាយនាធម៌វិន័យណា　　គ្រាស់អស់ទស្សរាសែសិបប្រាំ ។
++បួនគឺរក្សាគុណសម្បត្តិ　　នៃពុទ្ធបរិស័ទចាត់ជាឆ្នាំ
　ព្រះធម៌វិន័យព្រះអង្គផ្តាំ　　ស្ថិតច្រើនពាន់ឆ្នាំព្រោះបរិស័ទ ។
++ប្រាំគឺរក្សាត្រ័យសទ្ធម្ម　　បរិយត្តិនាំចំបដិបត្តិ
　បដិវេធៈជាក់កំចាត់　　កិលេសបង់បាត់ស្ងាត់សន្តាន ។

++ ប្រាំមួយរក្សាត្រ័យរតនៈ　　បិតនៅប្រចក្រសរណឋាន
ព្រះពុទ្ធព្រះធម៌នាំសុខសាន្ត　　ព្រះសង្ឃកល្យាណមានវិន័យ ។
++ប្រាំពីររក្សាត្រ័យសិក្ខា　　សាសនាចារថាប់ដួងហឫទ័យ
សីលសមាធិធម៌ប្រពៃ　　ផុតភ័យអាស្រ័យដោយបញ្ញា ។
++ព្រះត្រ័យបិដកមានប្រវត្តិ　　រឿងរ៉ាវបានកត់ចារអក្ខរា
អរិយធម៌ទប្បធម៌មនុស្សទេវតា　　បុព្វេយ៉ាងណាចារឲ្យដឹង ។
++បិដកថាច្បាប់ប្រាប់ភពត្រ័យ　　អ្នកមាននិស្ស័យលែលកប្រឹង
សិក្សាបដិបត្តិកំចាត់ខឹង　　ឲញ្ញឹងសំឡឹងដឹងត្រ័យលក្ខណ៍ ។
++បិដកច្បាប់ដើមព្រះសាសនា　　បាលីអក្ខរាសាស្ត្រាថាក់
បដិបត្តិបូជាធានាមគ្គ　　កំណត់ត្រ័យលក្ខណ៍លាត្រ័យលោក។
++កសាងចេតិយបិដកខ្មែរ　　យើងនាំគ្នាហែរព្រះមានជោគ
សាធុ សាធុ ផុតចាករោគ　　សាធុ ផុតលោក អនុមោទនា ៕

(អនុមោទនា)

\-\-\-\-\-\-\-\-

\-\-\-\-\-\-

\-\-\-

ថ្ងៃគួរនមស្សការ

--+++OOO+++--

ពិសាខបុណ្ណមីគឺថ្ងៃពិសេស　　យើងបានចាំចេះថ្ងៃព្រះភគវា
ប្រាំពីរប្រការថ្វេះថ្លាខន្ធា　　វិសាខបូជាឫកពារសែនល្អ ។
ទីមួយគឺថ្ងៃសុមេធបណ្ឌិត　　ពោធិសត្វពិតមានឫទ្ធិបវរ
ចាប់ផ្ដើមទទួលព្រះពុទ្ធព្យាករណ៍　　លោកធាតុញាប់ញ័រសាទរពេកក្រៃ ។
ទីពីរគឺថ្ងៃក្សត្រថ្លៃប្រសូត　　អស្ចារ្យរហូតសម្ពោធព្រឹក្សព្រៃ
កំណើតចុងក្រោយជាប់ដោយអត្ថន័យ　　ផុតចាកភពក្រៃលែងភ័យលែងព្រួយ ។
ទីបីគឺថ្ងៃព្រះស្រីមហាពោធិ៍　　ដុះចេញលេចធ្លោពោធិ៍ពិតមានគ្រួយ
ថ្ងៃព្រះប្រសូតស្រូតដុះជាមួយ　　ជំនួយឲ្យចិត្តបរិស័ទថ្វេះថ្លា ។
ទីបួនគឺថ្ងៃចមក្រៃត្រាស់ដឹង　　ថ្ងៃមានទីពឹងពំនឹងលោកា
ជាថ្ងៃព្រះពុទ្ធបរិសុទ្ធអស្ចារ្យ　　ពួកជនថ្វេះថ្លាចិន្តាល្អស្អាត ។
ទីប្រាំគឺថ្ងៃអង្គថ្លៃនិព្វាន　　ថ្ងៃព្រះទ្រង់ញាណមានពុទ្ធខាន
បច្ឆឹមវាចាថាកុំប្រមាទ　　ឱវាទពិសិដ្ឋបិតនៅជាគ្រូ ។
ប្រាំមួយគឺថ្ងៃប្រល័យព្រះធាតុ　　ចេតិយលោកនាថនៅទៀតមិនយូរ
ព្រះធាតុទាំងអស់ហោះមកគល់ពោធិ៍　　គេថារលាយរំលត់ពុទ្ធសាសន៍ ។
ប្រាំពីរគឺថ្ងៃជោគជ័យពុទ្ធ　　គ្រប់ព្រះភគវាឈ្នះមារបានត្រាស់
នាំមកនូវសុខវិសេសខ្លាំងណាស់　　គ្រប់អង្គទ្រង់ត្រាស់ព្រះធម៌ទេសនា ។
វិសាខបុណ្ណមីថ្ងៃប្រពៃពិត　　យើងខ្ញុំមានចិត្តនឹងធឹងថ្វេះថ្លា
ខន្ធាសំពះអង្គព្រះសាស្ដា　　សូត្រធម៌ថ្វាយផ្កាបូជាប្រទីប ៕

ឧបមាគុណព្រះរតនត្រ័យ ២២ប្រការ

----+++++OOO++++----

រីគុណព្រះត្រ័យរតន៍ បរិសុទ្ធប្រសើរក្រៃ
លោកបានឧបមេយ្យ មានម្ភៃពីរប្រការ ។
+++ទីមួយគឺព្រះពុទ្ធ ប្រសើរផុតត្រៃលោកា
ប្រៀបដូចព្រះចន្ទ្រា រះនាថ្ងៃពេញបូរមី ។
រីឯព្រះធម្មា ប្រៀបដូចជាកម្ពុរស្មី
នៃដួងព្រះចន្ទថ្លៃ ចាំងរស្មីភ្លឺលោកា ។
ព្រះសង្ឃដូចលោកហ្នឹង បានទីពឹងព្រោះចន្ទ្រា
ចែងចាំងរស្មីថ្លា ឲ្យលោកាល្អពេកក្រៃ ។
+++ទីពីរព្រះភគវា ប្រៀបដូចជាអាទិត្យថ្ងៃ
រះឡើងនៅពេលថ្ងៃ មានរស្មីខ្លាំងមហិមា ។
ព្រះធម៌នៃព្រះអង្គ ផូរផង់ដូចអាភា
ចេញពីអាទិត្យថ្លា ដេញអន្ធការឲ្យខ្ចាត់ទៅ ។
ព្រះសង្ឃអង្គសាវ័ក មានសំវរៈល្អពេកក្ងួង
ដូចទ្វីបលោកដែលត្រូវ អាទិត្យក្តៅឲ្យភ្លឺថ្លា ។
+++ទីបីព្រះមុនី ឥតមានពីរក្នុងលោកា
ព្រះអង្គប្រៀបដូចជា អ្នកអុជភ្លើងឈូលផុតព្រៃ។

រីអង្គព្រះធម្មា ប្រៀបដូចជាភ្លើងភ្លៅក្រៃ
ដុតព្រៃសៅ្មចវៃ្ង ជាសត្រូវនឹងស្រូវស្រែ ។
ព្រះសង្ឃនោះឯងនៃ ឧបមេយ្យដូចដីស្រែ
ដែលម្ចាស់ខិតខំថែ ក្លាយជាស្រែដ៏ឧត្តម ។
+++ទីបួនព្រះភគវា ប្រៀបដូចជាភ្លៀងយ៉ាងធំ
ប្រយោជន៍ដ៏ឧត្តម តែងកើតមានដល់លោកា ។
ព្រះធម៌ព្រះទ្រង់ញាណ ដែលទ្រង់បានប្រោសទេសនា
ដូចដំណក់ទឹកថ្លា ស្រោចជណ្ដប់លើផែនដី ។
សារ័កអ្នកហ្មត់ចត់ ដូចជនបទពណ៌ខៀវខ្ចី
ដែលភ្លៀងទើបធ្លាក់ថ្មី គួរប្រុសស្រីទាក់នេត្រា ។
+++ទីប្រាំព្រះសម្ពុទ្ធ ប្រសើរផុតជននានា
ព្រះអង្គប្រៀបដូចជា សារថីដ៏ចំណាប់ ។
រីឯព្រះធម៌ថ្លៃ ឧបមេយ្យដូចជាច្បាប់
ឧបាយជាគ្រឿងចាប់ បង្វឹកសេះអាជានេយ្យ ។
ព្រះសង្ឃដ៏សោភា ប្រៀបដូចជាអាជានេយ្យ
ហ្វឹកហាត់ល្អប្រពៃ អាចលៃប្រើតាន់ចិន្ដា ។
+++ប្រាំមួយនោះឯងនៃ ល្អពេកក្រៃព្រះសាស្ដា
ព្រះអង្គប្រៀបដូចជា សីល្បពេទ្យសំរាប់ដកសរ ។
ព្រះធម៌នៃព្រះអង្គ មានបែបទ្រង់សែនបវរ
ដូចឧបាយដកសរ គឺទិដ្ឋិសត្វគ្រប់គ្នា ។

សង្ឃសាវ័កកល្យាណ　　លោកប្រៀបបាននឹងអ្នកណា
ដែលសរមុគកាយា　　គ្រូវគ្រូពេទ្យដកចេញបាន ។
+++ប្រាំពីរព្រះសម្ពុទ្ធ　　បរិសុទ្ធប្រៀបស្មើបាន
ចក្ខុពេទ្យចំណាន　　ចេះឧបាយបកនេត្រា ។
ព្រះធម៌វិសេសថ្លៃ　　ឧបមេយ្យឧបាយា
បកភ្នែកឲនានា　　ឲ្យភ្លឺថ្លាផុតឲម្ភី ។
រីឯព្រះសង្ឃា　　ប្រៀបដូចជាអ្នកភ្នែកឈឺ
គ្រូវពេទ្យបកឲ្យភ្លឺ　　ចាកងងឹតគឺមោហា ។
+++ប្រាំបីព្រះភគវន្ត　　អរហន្តជាសាស្តា
ព្រះអង្គប្រៀបដូចជា　　ពេទ្យមានប្រាជ្ញាឆ្លាតវៃ ។
ព្រះធម៌ដ៏កល្យាណ　　ប្រៀបស្មើបានឱសថថ្លៃ
ដែលពេទ្យមានស្នាដៃ　　ឆ្លៃផ្សំគ្រូវយ៉ាងចំណាន ។
ព្រះសង្ឃរតន៍ថ្លៃ　　ឧបមេយ្យអ្នកដែលបាន
សះស្បើយរោគសាមាន្យ　　គឺកិលេសគ្រប់ប្រការ ។
+++ប្រាំបួនព្រះទ្រង់ញាណ　　ប្រៀបអ្នកបានស្គាល់មាគ៌ា
បង្ហាញសព្វគ្រប់គ្នា　　ឲ្យទៅរកទីផុតភ័យ ។
រីឯព្រះធម្មា　　ដែលសាស្តាទ្រង់លកលៃ
គ្រាស់ទុកដល់សព្វថ្ងៃ　　ឧបមេយ្យផ្លូវសុខា ។
ចំពោះព្រះសង្ឃរតន៍　　បរិសុទ្ធឥតមាយា
ប្រៀបដូចប្រុសស្រីណា　　ដើរដល់ទីដែលក្សេមក្សាន្ត។

+++ទីជប់ព្រះសាស្តា មានបញ្ញារុងរឿងថ្កាន
ប្រៀបដូចព្រៃហេមពាន្ត ពេញទៅដោយដើមរុក្ខា ។
ព្រះធម៌ដូចដើមថ្នាំ ជុះប្រចាំគ្រប់វេលា
គុណភាពល្អអស្ចារ្យ នៅក្នុងទីព្រៃហេមពាន្ត ។
ព្រះសង្ឃល្អសោភា ប្រៀបដូចជាអ្នកដែលបាន
ឱសថព្រៃហេមពាន្ត ផឹករួចហើយស្បើយរោគា ។
+++ជប់មួយព្រះមានជោគ ដូចនាយទូកក្នុងវដ្តសារ
តែងមានចិត្តករុណា ដល់សព្វសត្វក្នុងភពត្រៃ ។
ព្រះធម៌ពាក្យទូន្មាន ប្រៀបស្មើបានទូកចរណៃ
ចម្លងផុតលោកត្រៃ ឲ្យដល់ត្រើយបានសុខា ។
ព្រះសង្ឃដ៏និមល ដូចអ្នកដល់ត្រើយហើយណា
ត្រើយនោះមានឈ្មោះថា ព្រះនិព្វានសែនសុខត្រៃ ។
+++ជប់ពីរព្រះភគវា ជាសាស្តាបញ្ញាវៃ
ព្រះអង្គឧបមេយ្យ អ្នកឲ្យទ្រព្យគាប់ចិន្តា ។
ព្រះធម៌ទាំងប៉ុន្មាន ប្រៀបស្មើបានទ្រព្យនោះណា
ដែលជនផងនានា តែងប្រាថ្នារៀងរាល់ថ្ងៃ ។
សង្ឃសាវ័កកល្យាណ ដូចអ្នកបានចាយទ្រព្យថ្លៃ
គុណភាពល្អពេកក្រៃ ចាយរួចបានសុខគួរគាប់ ។
+++ជប់បីព្រះនិរភ័យ ឧបមេយ្យអ្នកមានភ័ព្វ
បង្ហាញវេជ្ជទ្រព្យ ឲ្យដល់អ្នកដែលត្រូវការ ។

ព្រះធម៌ពាក្យប្រដៅ ដូចរណ្ដៅទ្រព្យនោះណា
ពេញដោយទ្រព្យនានា មានតម្លៃហួសការស្មាន ។
ព្រះសង្ឃអ្នកស្ដាប់ទ្រង់ ផូរផង់រុងរឿងថ្កាន
ប្រៀបដូចជាអ្នកបាន រណ្ដៅទ្រព្យរីករាយក្រៃ ។
+++ជប់បួនព្រះចមគព ល្អសព្វគ្រប់គ្មានទោសពៃរ៍
ព្រះអង្គប្រសើរក្រៃ ដូចជាធីរៈបុរស ។
ព្រះធម៌ពាក្យបង្រៀន ប្រៀបស្មើបានភ្លឺផុតគ្រោះ
ក្សេមក្សាន្តឥតមានមោះ មានតែសុខគ្រប់ប្រការ ។
ព្រះសង្ឃដ៏សមទ្រង់ វិសុទ្ធវង្សចិរញ្ចងថ្លា
ដូចអ្នកបានសុខា ដោយសារធីរៈបុរស ។
+++ជប់ប្រាំព្រះសម្ពុទ្ធ បរិសុទ្ធសមធាំងអស់
ប្រៀបដូចជាសប្បុរស អ្នកលួងលោមឲ្យបានស្បើយ ។
រីព្រះសទ្ធម្មា ប្រៀបដូចការលួងនោះហើយ
លួងលោមឲ្យបានល្ហើយ ស្បើយភ្លឺសោករោគចង្រៃ ។
ព្រះសង្ឃសាវ័កពុទ្ធ ដូចអ្នកផុតរួចចាកភ័យ
ឧបទ្រពកំណាចក្រៃ ព្រោះស្នាដៃនៃព្រះអង្គ ។
+++ជប់ប្រាំមួយនោះណា ព្រះសាស្ដាវិសុទ្ធវង្ស
ព្រះវ័យស្អាតស្អោះត្រង់ ប្រៀបប្រដូចនឹងមិត្តល្អ ។
រីឯពាក្យទេសនា រចនាជាបទធម៌
ដូចពាក្យមិត្តបវរ ប្រាប់ប្រយោជន៍ដល់មិត្តភក្ត្រ ។

ព្រះសង្ឃឧត្តមពិត អ្នកនែបនិត្យព្រះធម្មា
ប្រៀបដូចនឹងអ្នកណា បានប្រយោជន៍គាប់ហឫទ័យ។

+++ជប់ប្រាំពីរព្រះនិរទុក្ខ ល្អគ្រប់មុខហួសវិស័យ
ព្រះអង្គឧបមេយ្យ បឹងកើតទ្រព្យច្រើនប្រការ ។
ព្រះធម៌ល្អគួរគាប់ ដូចជាទ្រព្យមានខ្លឹមសារ
កើតក្នុងបឹងនោះណា ជនត្រូវការកើបយកបាន ។
ព្រះសង្ឃស្វាមីភក្តិ ប្រៀបដូចអ្នកសំណាងមាន
ជួបទ្រព្យបឹងកល្យាណ រមែងបានក្តីរីករាយ ។

+++ជប់ប្រាំបីព្រះសុគត ល្អវិសុទ្ធិមិនធន់ថ្វាយ
ប្រៀបធៀបអធិប្បាយ អ្នកផ្ចូតទឹករាជកុមារ ។
បណ្តាំនៃព្រះអង្គ សមរំបេបទ្រង់គ្រប់ប្រការ
ប្រៀបដូចនឹងទឹកថ្លា សំរាប់ងូតជម្រះកាយ ។
ព្រះសង្ឃប្រៀបដូចជា រាជកុមារបានសប្បាយ
ងូតទឹកត្រជាក់សាយ ជ្រះអស់ក្អែលពីកាយា ។

+++ជប់ប្រាំបួនព្រះជិនស្រី មានសិរីឈ្នះក្រុងមារ
ព្រះអង្គប្រៀបដូចជា អ្នកធ្វើគ្រឿងប្រដាប់កាយ ។
ព្រះធម៌ពាក្យបណ្តាំ ពីរពាន់ប្រាំរយឆ្នាំឆ្ងាយ
ដូចគ្រឿងប្រដាប់កាយ ពេញនិយមគ្រប់វេលា ។
សាវ័កព្រះទ្រង់ញាណ ដែលលោកបានស្តាប់ទេសនា
ដូចអ្នកល្អសោភា ព្រោះអលង្ការធម្មគន្ធ ។

+++ទីម្ភៃនោះឯងណា ឧបមាព្រះភគវន្ត
ដូចគ្នានឹងដើមច័ន្ទន៍ ប្រកបក្លិនមានតម្លៃ ។
រីឯព្រះសទ្ធម្ម ដ៏ឧត្តមសម្ប្រពៃ
ដូចក្លិនច័ន្ទន៍ចរណៃ ដែលប្រុសស្រីគួចប្រាថ្នា ។
សាវ័កអ្នកស្មោះត្រង់ អ្នកទ្រទ្រង់សីលសិក្ខា
ដូចជានរណា ស្រង់ក្លិនច័ន្ទន៍ឆ្ងុយពេកពិត ។
+++ម្ភៃមួយព្រះបិតា ជាសាស្តាទ្រង់មានឫទ្ធិ
ដូចផ្តល់ទឹកអម្រឹត ដល់កូនស្ងួនទាំងប្រុសស្រី ។
រីព្រះសទ្ធម្មណា ដែលសាស្តាះពោលស្រដី
ទេសនាយ៉ាងឃ្មាតខ្មី ប្រៀបដូចទឹកអម្រឹតហ្នឹង ។
ព្រះសង្ឃប្រៀបដូចជា អ្នកកំព្រាឥតទីពឹង
បានទឹកអម្រឹតហ្នឹង មានពំនឹងរួចមរណា ។
+++ម្ភៃពីរព្រះគោតម ដូចបទុមក្នុងជលសារ
សូរ្យសែងរះកាលណា រីកសាខាស្រស់ឆើតឆាយ ។
ព្រះធម៌ប្រៀបដូចជា ទឹកជមផ្កាឈូកទាំងឡាយ
គួរស្រូបឥតខិនណាយ មាននៅក្នុងបទុមផ្កា ។
ព្រះសង្ឃអង្គសាវ័ក អ្នកជឿជាក់ត្រៃសិក្ខា
ប្រដូចនឹងភូមរា បានក្រេបផ្កាក្នុងវារី ។
ឧបមាគុណត្រៃរតន៍ មានប្រាកដម្ភៃពីរ
ដែលខ្ញុំខំសម្តី សូត្រវន្ទីយ៍នមស្ការ ។
សូមឲ្យសំរេចបុណ្យ ដែលជាគុណល្អថ្លៃថ្លា
អន្ទោលក្នុងសង្សារ សូមប្រាថ្នាជួបបណ្ឌិត ។
សូមជួបព្រះសិរអារ្យ ជាសាស្តាដ៏ពិសិដ្ឋ
សូមចាក់ផ្លុះធម៌ពិត សមដូចចិត្តប្រាថ្នាះហោង ។៕ (អនុមោទនា)

នមស្ការបូជាសត្តមហាឋាន

--+++++000++++++--

**បឋមំ ពោធិបល្លង្កំ - ទុតិយំ អនិមិសកំ - តតិយំ ចង្កមំសេដ្ឋំ - ចតុត្ថំ រតនឃរំ
បញ្ចមំ អជបាលញ្ច - មុច្ចលិន្ទេនឆដ្ឋមំ -សត្តមំ រាជាយតនំ-សត្តាហំ មុនិសេវិតំ
ឯតេ សត្តមហាឋានេ- ជម្ពូទីបេ បតិដ្ឋិតា-បូជិតា នរទេវេហិ-អហំ វន្ទាមិ ទូរតោ**

ខ្ញុំសូមបង្គំប្រណម្យវន្ទា ស្ថានព្រះភគវានានាឆ្ងាយជិត
ស្ថានធំប្រាំពីរព្រះមុនីនៃបនិត្យ ស្ថានមួយទ្រង់ស្ថិតពិតមួយសប្តាហ៍ ។
សត្តមហាស្ថានមហាចេតិយ ពួកជនប្រុសស្រីគប្បីជ្រះថ្លា
ជាស្ថានបូជានៃមនុស្សទេវតា ស្ថិតនៅអស្ចារ្យក្នុងជម្ពូទ្វីប ។
បឋមំ ពោធិបល្លង្កំ *ទ្រង់តាំងបធានគ្មានស្តាយជនជីព*
ត្រាស់ជាព្រះពុទ្ធដុតភ្លើងប្រទីប មនុស្សជម្ពូទ្វីបមានលាភថ្លៃថ្លា ។
ទុតិយំ អនិមិសកំ *ទ្រង់តាំងកាយឈរទិសបូព៌ឧត្តរា*
នៃព្រះពោធិព្រឹក្សមិនព្រិចនេត្រា ទ្រង់ទតវិចារណ៍មហាស្ថានពុទ្ធោ ។
តតិយំ ចង្កមំ សេដ្ឋំ *ទ្រង់តាំងហឫទ័យក្នុងព្រៃព្រះពោធិ៍*
ទ្រង់យាងទៅមកពីទីទ្រង់ឈរ និងគល់ព្រះពោធិ៍ប្រពៃអស្ចារ្យ ។

ចតុត្ថំ រតនឃរំ ទ្រង់តាំងពលំកម្លាំងប្រាជ្ញា
ព្រះជ្រែករអភិធម្មក្នុងផ្ទះរតនា ពាយព្យទិសានៃទីត្រាស់ដឹង ។
បញ្ចមំ អជបាលញ្ចេ ទ្រង់តាំងទ្រង់ដាក់ហឫទ័យនឹងធឹង
នៅទីទទួលបាយាសត្រាស់ដឹង ខាងកើតដងស្ទឹងនេរញ្ជរា ។
មុច្ចលិន្ទេន ឆដ្ឋមំ ទ្រង់តាំងបល្ល័ង្កគង់ក្នុងធម្មា
ខាងត្បូងព្រះពោធិ៍មាននាគរាជា បាំងព្រះភគវាការពារភិរុណ ។
សត្តមំ រាជាយតនំ ទ្រង់តាំងធម្មំខ្លាំងក្លាដោយគុណ
ខាងត្បូងមុច្ចលិន្ទព្រះឥន្ទចុះមុន បូជាព្រះគុណគង់ក្រោមដើមកែស ។
សត្តមហាស្ថានមហាចេតិយ សូត្ររៀងរាល់ថ្ងៃចំរើនចំណោះ
ចំរើនចិត្តស្ងប់រស់មិនប្រហែស កាត់បង់កិលេសមានៈឫស្យា ។
ព្រះពុទ្ធត្រាស់ដឹងទីពឹងក្នុងលោក ផុតពីទុក្ខសោករាគរោគតណ្ហា
គង់ក្នុងស្ថានស្ងាត់ប្រាំពីរសប្ដាហ៍ ចេតិយសម្មាសម្ពុទ្ធគ្រប់អង្គ ៕

សាធុ សាធុ សាធុ

--++++OOO++++--

សត្តមហាឋ

-+++000+++



សត្តមហាឋានមហាចេតិយ ប្រតិស្ឋាននៅ

ពុទ្ធគយាសីសៈសព្វថ្ងៃនេះ

នមស្ការបូជា
ព្រះអរហន្ត ៩ ទិស

--+++++OOO+++++--

ព្រះពុទ្ធស្ថិតស្ថានមជ្ឈិម   សារីបុត្រទៀបទីមគង់ទិសទក្ខិណា
ព្រះអានន្ទគង់ទិសបច្ឆិមា   ព្រះមោគ្គលានណាគង់ទិសឧត្តរ ។
ព្រះកោណ្ឌញ្ញគង់ទិសបូព៌បវរ   គវម្ពត្តិករគង់ទិសពាយព្យ
ព្រះឧបលិគង់ទិសនិរតីបន្ទាប់   អង្គព្រះកស្សបគង់អគ្នេយ៍ស្ថាន ។
ព្រះរាហុលគង់ទិសឦសាន   ទាំងប្រាំបួនស្ថានជាទីបូជា
យើងខ្ញុំប្រណម្យបង្គំវន្ទា   គ្រប់ទិសនានាសូមសុខសួស្តី ។
សូមឲ្យកំចាត់បំបាត់ទុក្ខភ័យ   ឧបទ្រពចង្រៃកុំបីបៀតបៀនដល់កាយ
ឱព្រះតេជៈខ្ញុំម្ចាស់សូមថ្វាយ   អំពីចម្ងាយគ្រប់ទិន្នទិវា ។
សូមឲ្យខ្ញុំរួចអបាយវេរា   ទាន់ព្រះភគវាព្រះសេអារមេត្រី
ព្រះអង្គស្រោចស្រង់សត្វក្នុងលោកិយ   ផ្ទុកសំពៅថ្មីដល់និព្វានហោង ៕

សាធុ សាធុ សាធុ

--++++OOO++++--

នមស្ការបូជាព្រះអរហន្ត៩ទិស

---+++++000+++++++---



ធម្មាសនះមហាចេតិយព្រះអរហន្តទាំង ៩ទិស
ប្រតិស្ឋាននៅវត្តវេឡុវន សព្វថ្ងៃនេះ

ក្រាបថ្វាយបង្គំព្រះពុទ្ធចេតិយ

--++++000++++--

+++ខ្ញុំព្រះករុណាសូមដល់នូវ ព្រះពុទ្ធ ព្រះធម៌ និងព្រះអរិយសង្ឃ ជាទីពឹង ទីរលឹក ខ្ញុំព្រះករុណាសូមក្រាបនមស្ការបូជា ព្រះគុណនៃអង្គព្រះសម្មាសម្ពុទ្ធ ដែលទ្រង់ពេញពោរដោយព្រះមេត្តា ករុណារកប្រមាណមិនបាន ។

+++ព្រះអង្គទ្រង់លះបង់គ្រប់យ៉ាង ក្នុងការសន្សំព្រះបារមី ដើម្បីត្រាស់ដឹង ហើយប្រកាសធម៌ នាំវេនេយ្យសត្វចេញចាកពីវដ្ដៈ ។

+++ខ្ញុំព្រះករុណាបូជាព្រះពុទ្ធចេតិយ ដោយសេចក្ដីជ្រះថ្លាដ៏ក្រៃលែង សូមតាំងសច្ចាធិដ្ឋាន ដោយផលានិសង្សនៃបុណ្យ ដែលខ្ញុំព្រះករុណាបានធ្វើក្នុងថ្ងៃនេះ សូមជាបច្ច័យឲ្យបានសំរេចដូចសេចក្ដីប្រាថ្នា ។

+++ អង្គព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ដឹងធម៌យ៉ាងណា សូមឲ្យខ្ញុំព្រះករុណាមានចំណែកនៃធម៌របស់ព្រះអង្គ ក្នុងកាលដ៏សមគួរផងចុះ ។

+++ទោះបីកើតក្នុងភពជាតិណាៗ សូមកើតនៅក្រោមម្លប់ នៃបវរព្រះពុទ្ធសាសនា កណ្ដាលកល្យាណមិត្ត បានសេពគប់នឹងសប្បុរស ដែលជាអ្នកដឹងនូវធម៌ដ៏ប្រសើរ សូមជាបុគ្គលសម្មាទិដ្ឋិ មានឱកាសសិក្សាធម៌ ស្ដាប់ធម៌ ប្រព្រឹត្តធម៌ ដែលជាបច្ច័យឲ្យចំរើនទៅដោយសតិ និងបញ្ញាបញ្ជូនតទៅគ្រប់ជាតិ រហូតដល់ព្រះនិព្វានហោង ៕

❀ ពុទ្ធប្រវត្តិសង្ខេប ❀

✱✱✱ ✱✱✱ ✱✱✱ ✱✱✱ ✱✱✱ ✱✱✱

យើងខ្ញុំបរិស័ទពុទ្ធសាសនា អោនកាយវាចាចិត្តគោរព
ចំពោះព្រះពុទ្ធដែលជាម្លប់ គ្រប់គ្នាត្រូវចាំឲ្យទៀងទាត់ ។
ចងចាំថ្ងៃខែឲ្យបានច្បាស់ នៃព្រះពុទ្ធម្ចាស់គឺប្រវត្តិ
សង្ខេបខ្លីៗឲ្យរត់មាត់ កំណត់ចាំបានពេលទាំងអស់ ។
យាងចូលកាន់គភ៌ឆ្នាំរកា អាសាឍមាសាថ្ងៃព្រហស្បតិ៍
ប្រសូត្រឆ្នាំចថ្ងៃសុក្រស្មោះ ពិសាខឈើលាស់ដើមរដូវ ។
សោយរាជ្យកត្តិកថ្ងៃអាទិត្យ ប្រជុំព្រាហ្មណ៍ព្រឹទ្ធនាឆ្នាំឆ្លូវ
បួសថោះអាសាឍព្រហស្បតិ៍ត្រូវ ត្រាស់នូវរកាពិសាខពុធ ។
បរិនិព្វានថ្ងៃអង្គារ បរិស័ទគ្រប់គ្នាកើតតក់ស្លុត
នៅខែពិសាខព្រះសម្ពុទ្ធ រលត់បញ្ចក្ខន្ធនាឆ្នាំម្សាញ់ ។
យើងបាត់ព្រះពុទ្ធទាន់សាសនា ធម៌ជាអាចារ្យកុំគ្នន់គ្នាញ់
អ្នកប្រព្រឹត្តធម៌ឈ្មោះស្រឡាញ់ ចំពោះអង្គអញ្ជតថាគត ។
បំណាច់អ្នកកាន់ពុទ្ធសាសនា ត្រូវចាំសាវតារនៃព្រះពុទ្ធ
គឺថ្ងៃខែឆ្នាំឲ្យហ្មត់ចត់ ទើបបានកំណត់ជាពុទ្ធជន ។

❀ ពុទ្ធកិច្ច ៥ យ៉ាង ❀

ពុទ្ធកិច្ច ៥ យ៉ាងគឺអ្វីខ្លះ ចូរចាំឲ្យច្បាស់គ្រប់រូបាំ
បំណាច់អ្នកកាន់ពុទ្ធសាសនា ត្រូវចាំកិច្ចការនៃព្រះអង្គ ។
ពេលព្រឹកទ្រង់យាងបិណ្ឌបាត តាមផ្ទះមានញាតិចាំរហង់
ជួនមួយអង្គឯងជួនមានសង្ឃ តម្រង់តាមសត្វមាននិស្ស័យ ។
រសៀលទ្រង់ត្រាស់សំដែងធម៌ ដល់សត្វនិករដោយអាល័យ
បើសត្វមិនយល់ទ្រង់ឧបមេយ្យ បកស្រាយសេចក្តីឲ្យយល់បាន ។
ព្រលប់ប្រទានព្រះឱវាទ ដល់សង្ឃឲ្យស្អាតក្នុងសន្តាន
កុំឲ្យប្រព្រឹត្តខុសលំអាន តាមផ្លូវដែលបានទ្រង់បញ្ញត្តិ ។
អាធ្រាត្រទ្រង់ដោះស្រាយបញ្ហា ដែលពួកទេព្តាមកច្រើនក្តាត់
សំដែងប្រស្នូត្រប្តូបរមត្ថ តាមពពួកសត្វដែលសង្ស័យ ។
ជិតភ្លឺប្រមើលនិស្ស័យសត្វ តើអាចប្រតិបត្តិមានកម្រៃ
ដែលគួរត្រាស់ដឹងព្រះធម៌ថ្លៃ តាមឧបនិស្ស័យសត្វលោកា ។
៤៥ ឆ្នាំឥតមានខ្វះ ព្រះអង្គនឿយណាស់លើសមនុស្សា
ឥតមានសម្រាកព្រះកាយា ឥតមាននរណាប្រដូចបាន ។
យើងបាត់ព្រះពុទ្ធទាន់សាសនា ធម៌ជាអាចារ្យទូន្មានប្រាណ
ប្រព្រឹត្តត្រង់ផ្លូវត្រូវលំអាន ដរាបដល់បាននិព្វានហោង ។

ធម៌ខន្តី

ទោសៈនោះខ្លាំង កម្លាំងក្រៃលែង តែទុកឲ្យវែង គ្មានអ្វីខ្លាំងដូច
ត្រូវកាត់ពិតិច ត្រូវក្តិចពីតូច ត្រូវអត់ឲ្យរួច ពិទោសដែលខឹង។
អ្នកប្រាជ្ញបុរាណ តែងឲ្យដំណឹង ថាបើមិនខឹង ទើបហៅខន្តី ។
ឲ្យគេខឹងចុះ យើងកុំខឹងអី មិនខឹងមិនស្តី ខន្តីបានយើង ។
ខន្តីជាទ្រព្យ គួរគាប់ថ្កុំថ្កើង ខន្តីកើតឡើង ក្នុងលោកទាំងមូល។
ខន្តីជាឫស ដុះជាបណ្តូល ខន្តីជាមូល មេធម៌ទាំងអស់ ។
ខន្តីជាយាន ជាស្ពានសប្បុរស អ្នកប្រាជ្ញទាំងអស់ អាស្រ័យខន្តី ។
ទៅសួគ៌និព្វាន គ្មានទៅដោយអ្វី ទៅដោយខន្តី ជាស្ពានជាន់ដើរ ។
ខន្តីជាសុខ ស្រណុកប្រសើរ មិនបាច់ចាំដើរ ទ្រព្យហូរចូលឯង ។
ខន្តីជាគ្រឿង ប្រដាប់តាក់តែង អ្នកផងស្ងប់ស្ងែង កោតក្រែងគ្រប់គ្នា ។
ជាទីស្រឡាញ់ មនុស្សនិងទេព្តា ឆ្ពោះទៅទីណា មានលាភគ្រប់យ៉ាង។
ហេតុនេះលោកអ្នក ដែលមានសំណាង ធ្វើបុណ្យកសាង កុំចោលខន្តី ។
ទានសីលភាវនា សមាធិក្តី តែខ្វះខន្តី គ្មានអ្វីទីតាំង ។
ខ្ញុំសូមសង្ខេប បញ្ចប់ធម្មំ អវសានឯវំ ប៉ុណ្ណោះឯងហោង។។

ខន្តី សេចក្តីអត់ធន់ សោរច្ចៈ សេចក្តីស្ងប់ស្ងៀម

--+++++++OOO+++++++--

សេចក្ដីត្រិះរិះ៥ប្រការរបស់នាងវិសាខា

---+++++++000+++++++---

១-សេចក្ដីត្រិះរិះរបស់ខ្ញុំថា　　តើនៅពេលណាខ្ញុំបានថ្វាយទាន
　នូវប្រាសាទថ្មីតាមទ្រព្យដែលមាន　ជាវិហារទានថ្វាយចំពោះសង្ឃ ។
២-សេចក្ដីត្រិះរិះរបស់ខ្ញុំថា　　តើនៅពេលណាខ្ញុំបានឱនអង្គ
　ថ្វាយគ្រែពូកខ្នើយដោយចិត្តផ្ចិតផ្ចង់　ចំពោះដល់សង្ឃដែលគង់ក្នុងវត្ត ។
៣-សេចក្ដីត្រិះរិះរបស់ខ្ញុំថា　　តើនៅពេលណាខ្ញុំបានថ្វាយភត្ត
　ផ្សំដោយមំសះធ្វើដោយហ្មត់ចត់　សាលាកភត្តជាអាហារទាន ។
៤-សេចក្ដីត្រិះរិះរបស់ខ្ញុំថា　　តើនៅពេលណាជួបព្រះទ្រង់ញាណ
　ព្រមទាំងព្រះសង្ឃសព្វខ្ញុំមាន　ថ្វាយចីវរទានសំពត់សាច់ល្អ ។
៥-សេចក្ដីត្រិះរិះរបស់ខ្ញុំថា　　តើនៅពេលណាជួបសង្ឃបវរ
　ថ្វាយភេសជ្ជៈទឹកឃ្មុំប្រេងស្ករ　ទឹកដោះគោល្អនិងទឹកអំពៅ ។
+++មកដល់ឥឡូវខ្ញុំបានសំរេច　　គ្រប់មុខស្រេចបាច់ឥតមានសល់នៅ
　ខ្ញុំបានថ្វាយទានកប់ទុកយ៉ាងជ្រៅ　ក្នុងដំណើរទៅកាន់ព្រះនិព្វាន ៕

សូមអនុមោទនា

-+++000+++-

អារាធនាធម្មកថិកសម្ដែងព្រះធម៌ទេសនា

អន្លង់ឱឃៈបួន

--+++000+++--

++បពិតព្រះគុណ ព្រះករុណា គង់លើអាសនា សក្តិសមរម្យ
ដឹកនាំទេសនា ប្រោសយើងខ្ញុំ ដើម្បីអប់រំ កាយវាចា ។
++យើងខ្ញុំគ្រប់គ្នា អ្នកលិចលង់ ជុំក្នុងអន្លង់ បួនប្រការ
អន្លង់ទី១ គឺកាមា ដែលពេញត្រៀបត្រា ក្នុងកាមគុណ ។
++អន្លង់ទី២ ភវោឃៈ វាយសត្វម្នាក់ ក្នុងភពធ្ងន់
មានស្លាប់ឬកើត ជានិរន្ត ឥតមានស្រាកស្រាន់ ក្នុងភពបី ។
++អន្លង់ទី៣ ទិដ្ឋោឃៈ ទាញសត្វម្នាក់ ក្នុងអវចី
ព្រោះទិដ្ឋិយល់ មិនប្រពៃ បុណ្យក្តីបាបក្តី ឥតអំពើ ។
++អន្លង់ទី៤ គឺអវិជ្ជា បាំងសត្វនានា ឲ្យល្ងីល្ងើ
នាំសត្វវង្វេង មិនឲ្យធ្វើ អំពើបុណ្យទាន សីលភាវនា ។
++ហេតុនេះព្រះគុណ ព្រះករុណា គង់លើអាសនា សំដែងធម្មា
ដឹកនាំយើងខ្ញុំ ទាំងអស់គ្នា ឡើងជិះនាវា ព្រះត្រ័យលក្ខណ៍
++កំចាត់កិលេស និងតណ្ហា ព្រមទាំងអវិជ្ជា ដោយអរិយមគ្គ
កាច់បំបាក់បង់ សង្សារចក្រ ចូលកាន់អមតៈ និព្វានហោង ៕

អារាធនាព្រះសង្ឃសំដែងធម៌

---+++000+++---

អហើរីខ្ញុំម្ចាស់ សូមប្រកាសក្រោមប្រណិប័តន៍
ដល់អស់ពួកបរិស័ទ ដែលលះកាត់ក្តីកង្វល់ ។
ហើយមកប្រជុំគ្នា ព្រោះប្រាថ្នាយកកុសល
ហេតុនេះសូមតម្កល់ តាំងចិត្តស្តាប់ធម៌ទេសនា ។
ដើម្បីជាការបុណ្យ និងជាគុណច្រើនណាស់ណា
អំណាចស្តាប់ទេសនា ដោយជ្រះថ្លាក្នុងសន្តាន ។
សូមតាំងចិត្តឲ្យស្អាត ខ្ញុំអារាធនាថ្កាន
និមន្តលោកនិធាន ទេសន៍ជូនទានយើងរាល់គ្នា ។
ពេលនេះសូមបរិស័ទ ដែលប្រណិប័តន៍គាល់ត្រៀបត្រា
កុំពោលកុំចរចា និយាយគ្នាបែរមុខក្រោយ ។
សូមផ្ចង់នូវសញ្ញា ផ្ទៀងសោតាស្តាប់កុំធ្វេស
ទើបនឹងបានផលសោយ អានិសង្សប្រាំប្រការ ៕

<u>សូមអនុមោទនា ៗ</u>

អារាធនាធម្មកថិកសំដែងធម៌ទេសនា

--+++000+++--

ព្រហ្មា ច លោកា ធិបតី សហម្បតី កតញ្ជលី អន្ធិវរំ អាយាចថ
សន្តីធ សត្តាប្បរ ជក្ខជាតិកា ទេសេតុ ធម្មំ អនុកម្បិមំ បជំ ។
សទ្ធម្មភេរី វិនយញ្ច កាយំ សុត្តញ្ច ពន្ធំ អភិធម្មចម្មំ
អាកោដយន្តោ ចតុសច្ចធណ្ឌំ បវេ្បាធនេយ្យេ បរិសាយ មជ្ឈេ ៕

សហម្បតីព្រហ្ម និនបង្គំអារាធនា សម្តេចព្រះភគវា ដោយគាថាយ៉ាងនេះឯង ។
ព្រះពុទ្ធទ្រង់អនុកូល ព្រមទទួលនឹងសំដែង ដោយតុណ្ហីភាពថ្លែង តាមភាវៈគុណករុណា
ទើបក្រោកចាកទីនោះ យាត្រាឆ្ពោះព្រៃមិគទា យាងចេញចរលីលា ពីទីនោះដោយព្រះបាទ
ញ៉ាំងសត្វចូលពុទ្ធចក្រ មានបញ្ចវគ្គីយ៍ជាអាទិ៍ ឲ្យផឹកអម្រឹតជាតិ រសនិព្វានតាមធម្មតា
ចាប់ដើមពីនោះឯង ទ្រង់សំដែងធម៌ទេសនា ធ្វើពុទ្ធក្រឹត្យា អស់វស្សាសែសិបប្រាំ
ពុំថយពុំបន្ទួ ប្រយោជន៍យូរអង្វែងឆ្នាំ សំរេចបុញ្ញកម្ម ដល់សព្វសត្វទាំងភពត្រៃ
ហេតុនោះឥឡូវនេះ យើងខ្ញុំនេះសាទរក្រៃ បពិត្រព្រះគុណថ្លៃ សូមនិមន្តប្រោសទេសានា
អនុគ្រោះពួកបរិស័ទ ដែលជាប់ខាត់ដោយមោហា ឲ្យកើតមានបញ្ញា ប្រាកដនាទីនេះហោង

អរព្រះគុណនិងសូមខមាទោស

(សូត្រពេលចប់ទេសនា)

++បពិត្រព្រះគុណ ព្រះករុណា គង់លើអាសនា ដ៏ថ្កើងថ្កាន
សក្តិសមរម្យធំ មេត្តាបាន នាំរឿងនិទាន ឥតមានខ្វះ ។
++អស់ឱព្រះគុណ ថ្លៃបរិសុទ្ធ ជាសាវកពុទ្ធ ព្រះជាម្ចាស់
បានត្រាស់ឲ្យទាន ធម៌ច្បងច្បាស់ តាមពុទ្ធដីកាព្រះ ត្រាស់ទេសនា ។
++ញ៉ាំងចិត្តសន្តាន ជននានា ដែលមានអវិជ្ជា និងតណ្ហា
កិលេសរួបរឹត ឥតឧបមា បានភ្លឺថ្លះថ្លា ទាំងប្រុសស្រី ។
++គឺគុណអានុភាព ព្រះករុណា ដែលប្រោសទេសនា ត្រាប្រណី
តាមពុទ្ធភាសិត ប្រែបាលី បានជាសេចក្តី ដោយបរមត្ថ ។
++ញែកដោយសណ្ឋាន តាមថ្នាក់ធម៌ ធម៌ណាដែលល្អ ជាសង្កាត់
ចែកចេញដោយខ្លី គ្មានវិបត្តិ ពិរោះពេកក្លាត់ ឥតសង្ស័យ ។
++មិនគឺសាវក អង្គឯណា គឺព្រះករុណា ទេសន៍ថ្មីៗ
ឯទំបញ្ចប់ សរទ្វបខ្លី យើងខ្ញុំប្រុសស្រី ស្តាយណាស់ណា។
++មិនទាន់អស់ចិត្ត នឹងសាច់ធម៌ សឹងឃាត់អង្វរ មិនហ៊ានថា
ឃើញនឿយព្រះទ័យ ព្រះករុណា សូមសាធុការ ចប់សេចក្តី ។
++ហត្ថខ្ញុំទាំងគូ គងប្រណម្យ លើកឡើងបង្គំ គុណកែវបី
ព្រះពុទ្ធព្រះធម៌ ព្រះសង្ឃថ្លៃ សូមមានសេរី ដូចប្រាថ្នា ។
++ខ្ញុំសូមខមា ទោសទាំងឡាយ ក្រែងឆ្គងដោយកាយ ឬវាចា
ចិត្តមានគ្រោតគ្រាត សណ្ឋានណា ដូចជាគាថា សូត្រក្រោយហោង ៕

(សូមអនុមោទនា)

អារាធនាព្រះសង្ឃចំរើនព្រះបរិត្ត

---+++000+++---

វិបត្តិប្បដិពាហាយ សព្វសម្បត្តិសិទ្ធិយា
សព្វទុក្ខវិនាសាយ បរិត្តំព្រូថមង្គលំ ។
វិបត្តិប្បដិពាហាយ សព្វសម្បត្តិសិទ្ធិយា
សព្វភយវិនាសាយ បរិត្តំព្រូថមង្គលំ ។
វិបត្តិប្បដិពាហាយ សព្វសម្បត្តិសិទ្ធិយា
សព្វរោគវិនាសាយ បរិត្តំព្រូថមង្គលំ ។

សូមព្រះករុណាចំរើននូវព្រះបរិត្ត ជាជ័យមង្គលសិរីសួស្តី ដើម្បីការពារបញ្ចៀសនូវវិបត្តិនិងសេចក្តីអន្តរាយទាំងពួង ដើម្បីនឹងឲ្យបានសំរេចនូវសម្បត្តិគ្រប់យ៉ាង ដើម្បីនឹងញ៉ាំងទុក្ខ ញ៉ាំងភ័យ ញ៉ាំងរោគ ទាំងអស់ឲ្យវិនាសបាត់ទៅ ។

អារាធនាទេវតា

--+++000+++--

សគ្គេ កាមេ ច រូបេ គិរិសិខរតដេ ចន្តលិក្ខេ វិមានេ
ទីបេ រដ្ឋេ ច គាមេ តរុវនគហនេ គេហវត្ថុម្ហិ ខេត្តេ
ភុម្មា ចាយន្តុ ទេវា ជលថលវិសមេ យក្ខគន្ធព្វនាគា
តិដ្ឋន្តា សន្តិកេយំ មុនិវរវចនំ សាធវោ មេ សុណន្តុ ។

+++ ទេវតាទាំងឡាយដែលស្ថិតនៅក្នុងស្ថានសួគ៌ ដែលជាកាមភពនិងរូបភពក្តី ភូមិទេវតាទាំងឡាយដែលស្ថិតនៅក្នុងទិព្វវិមាន គឺលើកំពូលភ្នំ ឬភ្នំដែលដាច់ក្តី ព្វដ៏អាកាសក្តី នៅនាកោះនិងដែននិងស្រុកក្តី នៅនាដើមព្រឹក្សានិងព្រៃញាតស្បាតឬទីស្រែចំការក្តី យក្ខនិងគន្ធព្វនិងនាគទាំងឡាយ ដែលស្ថិតនៅនាទីទឹកទីគោកឬទីមិនរាបស្មើ ដែលនៅក្នុងទីជិតនេះក្តី សូមអញ្ជើញមកប្រជុំគ្នាក្នុងទីនេះ ពាក្យឯណាដែលជាពាក្យព្រះសក្យមុនីដ៏ប្រសើរ ដែលព្រះសង្ឃនឹងសូត្រឥឡូវនេះ លោកអ្នកសប្បុរសទាំងឡាយ ចូរស្តាប់នូវពាក្យនោះអំពីសំណាក់នៃព្រះសង្ឃដោយគោរព។

+++ ធម្មស្សវនកាលោ អយម្ភទន្តា បពិត្រលោកអ្នកដ៏ចំរើនទាំងឡាយ ពេលនេះជាពេលគួរនឹងស្តាប់នូវព្រះធម៌ (៣ដង) ។៕

ថេរភត្ត (ក្នុងពិធីបុណ្យទូទៅ)

អយំ នោ ភន្តេ . បិណ្ឌបាតោ . ធម្មិកោ . ធម្មលទ្ធោ . ធម្មេនេវ .ឧប្បាទិតោ . មាតាបិតុ . អាទិកេ . គុណវន្តេ . ឧទ្ទិស្ស . ឥមំ. (សង្ឃភត្តំ) . សបរិក្ខារំ . ពុទ្ធប្បមុខស្ស . សង្ឃស្ស ទេម . តេ គុណវន្តាទយោ . ឥមំ . (សង្ឃភត្តំ) . សបរិក្ខារំ . អត្តនោ . សន្តកំ វិយ . មញ្ញមានា . អនុមោទន្តុ . អនុមោទិត្វាន . យថិច្ឆិត សម្បត្តីហិ . សមិជ្ឈន្តុ . សព្វទុក្ខា . បមុញ្ចន្តុ . ឥមិនា . និស្សន្ទេន ។

ទុតិយម្បិ -- តតិយម្បិ ។

បពិត្រព្រះគម្ពែងសង្ឃដ៏ចំរើនន្ទើយ វីចង្ហាន់បិណ្ឌបាតនៃយើងខ្ញុំទាំងឡាយនេះ ប្រកបដោយធម៌ បានមកដោយធម៌ កើតឡើងដោយធម៌ យើងខ្ញុំទាំងឡាយ សូមឧទ្ទិសចំពោះ ដល់លោកអ្នកដ៏មានគុណទាំងឡាយ មានមាតានិងបិតាជាដើម ហើយយើងខ្ញុំទាំងឡាយ វេរនូវសង្ឃភត្តនេះ ព្រមទាំងគ្រឿងបរិក្ខារ ប្រគេនដល់សង្ឃ មានព្រះពុទ្ធជាប្រធាន ។ សូមលោកអ្នកដ៏មានគុណទាំងឡាយ មានមាតានិងបិតាជាដើមនោះ សំគាល់នូវសង្ឃភត្តនេះ ថាដូចជារបស់នៃខ្លួន ហើយសូមអនុមោទនាយកចុះ លុះអនុមោទនារួចហើយ សូមឲ្យរួចរដោះចាកទុក្ខទោស និងពៀរវេរាទាំងពួង ហើយឲ្យបានសំរេច នូវសម្បត្តិទាំងឡាយបីប្រការ គឺសម្បត្តិមនុស្ស១ សម្បត្តិទេវតា១ សម្បត្តិព្រះនិព្វាន១ ដោយសមគួរតាមសេចក្តីប្រាថ្នា របស់លោកអ្នកដ៏មានគុណទាំងឡាយនោះចុះ ដោយអំណាចផលានិសង្ស ដែលហូរជូនទៅមិនដាច់នេះហោង ។

អស់វារៈពីរដងផង -- អស់វារៈបីដងផង ។ៗ

វេរចតុបច្ច័យជាសង្ឃទាន

មយំ ភន្តេ . ឥមេ ចត្តារោ . បច្ចយេ . ឥធានេត្វា . សង្ឃស្ស ទេម.
សាធុ ភន្តេ . សង្ឃោ . ឥមេ ចត្តារោ . បច្ចយេ . បដិគ្គណ្ហាតុ .អម្ហាកំ
ទីឃរត្តំ . អត្ថាយ . ហិតាយ . សុខា ++ធុតិយម្បិ ++តតិយម្បិ ។

បពិត្រព្រះគម្ពែងសង្ឃដ៏ចំរើនន្តើយ យើងខ្ញុំទាំងឡាយ បាននាំនូវបច្ច័យទាំងឡាយបួននេះ មកដំកល់ទុកក្នុងទីនេះ ហើយវេរប្រគេនដល់ព្រះសង្ឃ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃទទួលយក នូវបច្ច័យទាំងឡាយបួននេះ ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់យើងខ្ញុំទាំងឡាយផង ដល់មាតាបិតាទាំងឡាយផង គ្រូឧបជ្ឈាយ៍ទាំងឡាយផង ញាតិការទាំងឡាយផង អស់កាលជាអង្វែងទៅហោង ៕

ទេរចង្ហាន់ថ្វាយព្រះដ៏មានព្រះភាគ

---+++++++++---

បពិត្រព្រះដ៏មានព្រះភាគដ៏ចំរើនហើយ យើងខ្ញុំព្រះអង្គទាំងអស់គ្នា មានសទ្ធាជ្រះថ្លា បាននាំមកនូវផ្កាកម្រង គ្រឿងក្រអូប គ្រឿងប្រទីប ព្រមទាំងចង្ហាន់បិណ្ឌបាត្រ មកដំកល់ទុកក្នុងទីនេះ ដើម្បីថ្វាយដល់ព្រះដ៏មានព្រះភាគ ។

បពិត្រព្រះដ៏មានព្រះភាគដ៏ចំរើនហើយ សូមព្រះអង្គអនុគ្រោះ ទទួលយក ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់លោកអ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់យើងខ្ញុំព្រះអង្គទាំងឡាយផង ដល់ទេវតាទាំងឡាយផង ដល់នាគនិងគ្រុឌទាំងឡាយផង ដល់សព្វសត្វក្នុងអបាយភូមិទាំងឡាយផង ដល់ស្តេចយមរាជផង សូមអស់លោកទាំងអស់នោះ ត្រេកអរ អនុមោទនា កាលបានអនុមោទនារួចហើយ សូមឲ្យបានដល់នូវសេចក្តីសុខចុះ

- សូមញាតិទាំងឡាយអនុមោទនា
- សូមអនុមោទនាបុណ្យអំពីយើងខ្ញុំ

សូមអនុមោទនា

++++++++

ធម៌វេរចង្ហាន់ប្រគេនសង្ឃ

----+++++000++++++++----

-បពិត្រព្រះសង្ឃទ្រង់សីលា　　ខ្ញុំព្រះករុណាទាំងប្រុសស្រី
ដែលត្រូវជាបុត្របុព្វការី　　នៃអ្នកមានគុណគ្រប់អាត្មា ។
-គាត់តែងវេយ្យធម៌ប្រសើរស្អាត　　ដោយនូវបសាទក្នុងចិន្តា
ផុលផុសផុះចេញចាកចេតនា　　គោរពឧបការជាប្រធាន ។
-បង្ហោនថ្វាយសង្ឃដ៏ទ្រង់យស　　សូមទានអនុគ្រោះដោយប្រោសប្រោណ
ទទួលវេយ្យធម៌ទាំងប៉ុន្មាន　　ដែលចាត់ជាទានទក្ខិណា ។
-ប្រសើរលើសលុបខ្ពស់បំផុត　　អង្គព្រះសម្ពុទ្ធទ្រង់ត្រាស់ថា
ថ្វាយទានគោរពមានផល្លា　　ខ្ញុំសូមបូជាគ្រានេះហោង ៕

- អស់វារៈពីរដងផង
- អស់វារៈបីដងផង

វេរបាយបិណ្ឌ

--+++000+++--

បពិត្រព្រះករុណាដ៏ចំរើនន្ទើយ យើងខ្ញុំព្រះករុណាទាំងឡាយ បានតាក់តែងហើយ នូវវត្ថុទាំងឡាយ មានខាទនីយ ភោជនីយាហារ គឺបង្អែមនិងចំអាប មានបាយបិណ្ឌជាដើមនេះ ហើយបង្អោនចូលមក វេរប្រគេនដល់ព្រះករុណា ។

បពិត្រព្រះករុណាដ៏ចំរើន សូមព្រះករុណាអនុគ្រោះទទួលយក នូវវត្ថុទាំងឡាយ មានបង្អែមនិងចំអាប និងបាយបិណ្ឌជាដើមនេះ ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់យើងខ្ញុំព្រះករុណាទាំងឡាយផង ដល់មាតាបិតាទាំងឡាយផង ព្រមទាំងពពួកញាតិទាំងឡាយផង អស់កាលជាអង្វែងទៅហោង ៕

សូមអនុមោទនា ៗៗ

ទេវព្រះត្រ័យបិដក

-++++000++++-

(នមោ ៣ ចប់)

ឥមានិ ធម្មចេតិយានិ សង្ឃស្ស ទេម

បពិត្រព្រះសង្ឃដ៏ចំរើនហើយ ខ្ញុំព្រះករុណាទាំងឡាយ បាននាំមកហើយ នូវគម្ពីរព្រះត្រ័យបិដក១ចប់ បើគិតជាភាគមានចំនួន១១០ភាគ មកប្រគេនព្រះសង្ឃ ដែលគង់ចាំសិក្សាក្នុងវត្តខាងជុំនេះ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃមេត្តាទទួលយក នូវព្រះធម្មចេតិយ គឺគម្ពីរព្រះត្រ័យបិដកទាំងអស់នេះ ដើម្បីសិក្សា ឲ្យបានជាប្រយោជន៍ ដល់ព្រះករុណាគ្រប់ព្រះអង្គផង និងឲ្យបានសំរេចបុណ្យ ដល់ខ្ញុំព្រះករុណាទាំងអស់គ្នាផង អស់កាលជានិច្ចតរៀងទៅ ៕

សូមអនុមោទនា

-++000++-

វេរកឋិនចីវរ

--+++000+++--

១- **នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស** (៣ចប់)

២-បពិត្រព្រះសង្ឃដ៏ចំរើនឡើយ - ខ្ញុំព្រះករុណាទាំងអស់គ្នា - មានសេចក្តីជ្រះថ្លា -បានដង្ហែរមកហើយ -នូវកឋិនចីវរ -ព្រមទាំងបរិក្ខារ-ដើម្បីវេរថ្វាយដល់សង្ឃ -ជាប្រយោជន៍ដល់ការក្រាលកឋិន - នៅវត្ត(ពោធិ៍នេះ) - ខ្ញុំព្រះករុណាសូមវេរ -នូវកឋិនទាននេះដូចតទៅ :-

៣-ឧកាស : ឥមំ ភន្តេ -កឋិន ចីវរំ -សានិសំ សំ -សង្ឃស្ស ទេម ។

-ទុតិយម្បិ : ឥមំ ភន្តេ -កឋិន ចីវរំ -សានិសំ សំ -សង្ឃស្ស ទេម ។

-តតិយម្បិ : ឥមំ ភន្តេ -កឋិន ចីវរំ -សានិសំ សំ -សង្ឃស្ស ទេម ។

៤-បពិត្រព្រះសង្ឃដ៏ចំរើនឡើយ -កឋិនចីវរ -ព្រមទាំងអានិសង្សលាភនេះ - ខ្ញុំព្រះករុណាទាំងអស់គ្នា -បានវេរប្រគេនសង្ឃហើយ -សូមព្រះសង្ឃមេត្តា អនុគ្រោះ -ទទួលយក -ក្រាលនូវកឋិនចុះ -ដើម្បីជាប្រយោជន៍ -ដល់ការ ទ្រទ្រង់ព្រះសាសនាផង -ជាប្រយោជន៍ -ដល់លោកអ្នកដ៏មានគុណ -របស់ខ្ញុំ ព្រះករុណាផង -ដល់សព្វសត្វទាំងអស់ផង -ព្រមទាំងខ្ញុំព្រះករុណាផង -ជា ឧបនិស្ស័យ -ក្នុងសាសនាព្រះជិណស្រី -រួចផុតចាកទុក្ខទាំងពួងហោង ៕

សូមអនុមោទនា ៗ

(ព្រះសង្ឃប្រធាន អនុមោទនាគាថា)

ធម៌ឧទ្ទិសជូនបុណ្យ

---+++++000+++++---

- រីបុណ្យដែលកើតពីថ្វាយសទ្ធា ឧត្តមផូរផង់ខ្ពស់ថ្លៃថ្លា
  ឧទ្ទិសបូជាជូនមាតា ព្រមទាំងបិតាគ្រប់ៗជាតិ ។
- មួយអន្លើដោយសត្វគ្រប់ៗឋាន ព្រមទាំងគ្រប់ប្រាណសន្តានញាតិ
  ដែលជាប់និស្ស័យជាទាយាទ ដែលឃ្លាតព្រោះចាញ់មច្ចុមារ ។
- សូមអញ្ជើញលោកមកទទួលផល បានដល់នូវអង្គអនុមោទនា
  សេរីសុខៈគ្រប់ប្រការ ស្រេចតាមប្រាថ្នានៃលោកចុះ ។
  ចំណែកឯយើងខ្ញុំទាំងឡាយ សូមបានរីករាយកុំបីខ្ទោះ
- ជួបជួនសួនចិត្តធម៌សប្បុរស អស់ទៅនៃជាតិជរាហោង ៕

(សូមអនុមោទនា)

សូមខមាទោសព្រះរតនត្រ័យ

--+++++OOO+++++--

កាយេន វាចា យវ ចេតសាវា ពុទ្ធេ កុកម្មំ បកតំ មយាយំ

ពុទ្ធោ បដិគ្គណ្ហតុ អច្ចយន្តំ កាលន្តរេសំ វរិតុំ វពុទ្ធេ ។

កម្មឯណាដែលខ្ញុំធ្វើ អាក្រក់លើព្រះពុទ្ធពិត
ដោយកាយវាចាចិត្ត ទុច្ចរិតឥតបារម្ភ ។
ពុទ្ធោ សូមព្រះពុទ្ធ ទ្រង់អំណត់អត់ទោសខ្ញុំ
ខុសឆ្គងព្រះពុទ្ធកុំ យកទោសខ្ញុំតទៅទៀត ។
ដើម្បីនឹងសង្រួម រវាំងព្រមមិនឲ្យឃ្លាត
សូមជួបព្រះពុទ្ធទៀត ឲ្យបានសុខសព្វៗកាល ។

កាយេន វាចា យវ ចេតសាវា ធម្មេ កុកម្មំ បកតំ មយាយំ

ធម្មោ បដិគ្គណ្ហតុ អច្ចយន្តំ កាលន្តរេសំ វរិតុំ វធម្មេ ។

កម្មឯណាដែលខ្ញុំធ្វើ អាក្រក់លើព្រះធម៌ពិត
ដោយកាយវាចាចិត្ត ទុច្ចរិតឥតបារម្ភ ។
ធម្មោ សូមព្រះធម៌ ទ្រង់អំណត់អត់ទោសខ្ញុំ
ខុសឆ្គងព្រះធម៌កុំ យកទោសខ្ញុំតទៅទៀត ។
ដើម្បីនឹងសង្រួម រវាំងព្រមមិនឲ្យឃ្លាត
សូមជួបព្រះធម៌ទៀត ឲ្យបានសុខសព្វៗកាល ។

កាយេន វាចា យទ ចេតសា វា សង្ឃេ កុកម្មំ បកតំ មយា យំ
សង្ឃោ បដិគ្គណ្ហតុ អច្ចយន្តំ កាលន្តរេសំ វរិតុំ វសង្ឃេ ។

កម្មឯណាដែលខ្ញុំធ្វើ អាក្រក់លើព្រះសង្ឃពិត
ដោយកាយវាចាចិត្ត ទុច្ចរិតឥតបារម្ភ ។
សង្ឃោ សូមព្រះសង្ឃ ទ្រង់អំណត់អត់ទោសខ្ញុំ
ខុសឆ្គងព្រះសង្ឃកុំ យកទោសខ្ញុំតទៅទៀត ។
ដើម្បីនឹងសង្រួម រវាំងព្រមមិនឲ្យឃ្លាត
សូមជួបព្រះសង្ឃទៀត ឲ្យបានសុខសព្វៗកាល ៕

ពាក្យសូមខមាទោស

យើងខ្ញុំកូនប្រុសនិងកូនស្រី　　សូមឱនសិរសីថ្វាយបង្គំ
បាទាមាតាបិតាខ្ញុំ　　លោកមានគុណធំឧត្តមក្រៃ ។
តាំងពីកូនកើតក្នុងពោះម្ដាយ　　លោកតែងខ្វល់ខ្វាយរៀងរាល់ថ្ងៃ
ខ្លាចកូនមិនសុខឃ្លាតចាកផ្ទៃ　　ចិត្តនឹកមមៃដល់កូនណាស់ ។
លុះពេលកូនកើតលោកព្រួយចិត្ត　　ខ្លាចបង់ជីវិតឆាប់រហ័ស
បើកូនបានសុខរីករាយណាស់　　ចិត្តលោកប្ដូរផ្លាស់អរពន់ពេក ។
កាលកូននៅតូចម៉ែថ្នាក់ថ្នម　　លួងលោមបីបមដាក់ឲ្យដេក
ខំច្រៀងបំពេរអត់ដំណេក　　ឲ្យកូនស្ងួនដេកធើបអស់ចិត្ត ។
លុះកូនធំឡើងឲ្យសិក្សា　　សព្វវិជ្ជាការល្អប្រណីត
ប្រយោជន៍ឲ្យស្រួលដល់ជីវិត　　រិះគិតផ្លូវលោកនិងសាសនា ។
ពេលនេះកូនសូមខមាទោស　　ដែលកូនចៅខុសរាល់យប់ថ្ងៃ
ដោយកាយវាចាចិត្តអប្រិយ　　មិនគួរគប្បីទៅលើលោក ។
ទោះបីទោសតូចឬធំក្ដី　　សូមលោកប្រណីលោះទុក្ខសោក
កុំឲ្យមានបាបកម្មតាមមក　　ដល់កូនរាល់រូបតទៅហោង ។
ពេលនេះកូនខំធ្វើបុណ្យទាន　　ជូនលោកមានគុណគ្រាន់ចម្លង
ឲ្យលោកផុតទុក្ខគ្រឿងសៅហ្មង　　បានសុខកន្លងក្នុងនិព្វាន ។
សូមលោកមានគុណទទួលយក　　នូវបុណ្យកុសលទុក្ខជាស្ពាន
ឲ្យបានសោយសុខក្នុងនិព្វាន　　កុំបីខកខានតទៅហោង ។៕

---++++000++++---

ខ្ញុំនឹកព្រះណាស់

--+++000+++--

ខ្ញុំឈរកណ្ដាលទីក្រុងចាស់ ខ្ញុំនឹកព្រះណាស់ពេលព្រលប់
បញ្ចគីរីនៅឃើញគ្រប់ ចិត្តខ្ញុំប្រាថ្នាព្រះសាស្ដា ។
ផល្គុណខ្ទីតចាស់ច័ន្ទភ្លឺហើយ ខ្ញុំពុំឃើញឡើយព្រះមិតា
បាត់ស្ងាត់សូន្យអរហន្ដា សល់តែសីលានិងព្រៃភ្នំ ។
ហាក់ដូចថ្មីៗឥឡូវសោះ ស្រាប់តែបាត់អស់ចាកចោលខ្ញុំ
ខ្ញុំបានត្រឹមតែថ្វាយបង្គំ ដួងចិត្តស្រែកយំនឹកសាស្ដា ។
នឹកអើយសែននឹកអង្គព្រះពុទ្ធ ខ្ញុំសូមលំអុតឱនសិរសា
សំដែងរៀបរាប់ចាត់អក្ខរា មគ្គផសាស្ដាធ្លាប់អាស្រ័យ ។
ថ្វីត្បិតរូបកាយស្ដេចយាងបាត់ ធម្មកាយមិនខ្ចាត់ស្ថិតសព្វថ្ងៃ
អារាធនាអង្គព្រះពុទ្ធថ្លៃ គង់ក្នុងហឫទ័យនៃយើងខ្ញុំ ។៕

កណ្ដាលទីក្រុងចាស់ មើលឃើញច្បាស់ភ្នំជុំវិញ
នឹកព្រះខំបំពេញ ដាក់ធម៌ដើរចេញចាកលោកា ។
ដើរតាមស្នាមព្រះបាទ ព្រះលោកនាថជាសាស្ដា
ព្រមទាំងអរហន្ដា ចាកលោកាចូលនិព្វាន ។
លោកនេះមិនគួរនៅ សុទ្ធសុត្រូវតែងរុករាន
ព្រះនាំទៅនិព្វាន សត្វគោជលានចេញចាកស្ពាន ។
ឥឡូវទៅអស់ហើយ គឺនៅឡើយតែលំអាន
មិនយូរនឹងបាត់ដាន ផ្លូវនិព្វានគ្មានអ្នកដើរ ។
កាលនោះដែនមគ្គធៈ សុទ្ធអារិយៈអ្នកប្រសើរ
ឥឡូវចេញដំណើរ ដើរទៅបាត់ស្ងាត់អស់ហើយ ។៕

ក្រុងពារាណសី ព្រៃឥសិបតន

---+++000+++---

ក្រុងពារាណសីទីកដីពោធិសត្វ   ក្នុងសង្សារវដ្តបំពេញបារមី
ព្រះបាទព្រហ្មទត្តគ្រងដែនកាសី   ព្រះពោធិសត្វថ្លៃបួសជាតាបស ។
ឥសិបតនព្រៃមិគទាយា   ឋានព្រះភគវាគ្រប់អង្គទាំងអស់
សំដែងធម្មចក្កប្រោសពួកតាបស   អរិយមគ្គខ្ពង់ខ្ពស់បឋមទេសនា ។
អាសាឡ្ហបុណ្ណមីថ្ងៃកំណើតធម៌   ទេសនាបវរមជ្ឈិមាយាត្រា
ថ្ងៃខួបកំណើតព្រះធម៌ទេសនា   បរិស័ទទ្រះថ្លថ្វាយផ្កាចេតិយ ។
អាសាឍបុណ្ណមីថ្ងៃកំណើតសង្ឃ   សរណៈពេញអង្គសង្ឃគំរប់បី
ឋានត្រ័យរតនៈក្នុងដែនកាសី   អាសាឍបុណ្ណមីអាសាឡ្ហបូជា ។
ចេតិយព្រះយសខ្ពស់ព្រោះសសរ   យសបានស្ដាប់ធម៌តលំដាប់គ្នា
ឯហិភិក្ខុដោយព្រះភគវា   ព្រះយសបានជាសង្ឃព្រះអរហន្ត ។
ហាសិបបួនអង្គសំឡាញ់ព្រះយស   មកបួសទាំងអស់ព្រៃមិគទាយវន
ឋានត្រៃរតនៈឋានព្រះភគវន   ត្រាស់ប្រាប់អរហន្តចេញផ្សាយសាសនា ។
ខ្ញុំថ្វាយបង្គំឋានត្រ័យរតនៈ   ដោយចិត្តស្មោះស្ម័គ្រនឹកព្រះសាស្ដា
នឹកព្រះអរហន្តនឹកធម៌ទេសនា   ខ្ញុំសូមប្រាថ្នាផុតភាពលោកិយ ៕

ថ្វាយបង្គំព្រះពុទ្ធប្រាំព្រះអង្គ

1 ឱកាសៈខ្ញុំសូមវន្ទា នូវព្រះឈ្នះមារ ទាំងប្រាំព្រះអង្គ សូមយាងបារមី
ម្ចាស់ថ្លៃមកគង់ នៅនាកំឡុង ទីឋានកិត្តិយស ។
2 ព្រះកក្កុសន្ធោ ដើមច្រេសជាពោ ធិព្រឹក្សខ្ពង់ខ្ពស់ ឆព្វណ្ណរង្សី
រស្មីសាយសុស ព្រះជន្មអង្គនោះ បួនម៉ឺនវស្សា ។
3 ព្រះកោនាគមនោ ត្រាស់ដើមឧទុម្ពរ ពោធិសាខា ឆព្វណ្ណរង្សី
រស្មីភ្លឺថ្លា ព្រះជន្មវស្សា បីម៉ឺនឆ្នាំគត់ ។
4 ព្រះកស្សបោ ដើមជ្រៃជាពោ ធិព្រឹក្សបរិសុទ្ធ ឆព្វណ្ណរង្សី
រស្មីមោះមុត ព្រះជន្មកំណត់ ពីរម៉ឺនវស្សា ។
5 ព្រះសមណៈគោតម ត្រាស់យ៉ាងសក្តិសម បរមសាស្តា ផុសវ័ត្ថបល្ល័ង
រតនៈភ្លឺថ្លា ស្តេចគង់ផ្ចាញ់មារ ព្រះអង្គឥតភ្ញឹក ។
6 ថ្កើងព្រះបារមី ឆព្វណ្ណរង្សី ក្រោមដើមពោធិព្រឹក្ស នាងហ៊ីងធរណី
ទេវីច្បូតទឹក ពលមារសន្ធឹក ចាញ់ព្រះសាស្តា ។
7 ព្រះជន្មប៉ែតសិប សាសនាកំណត់ ប្រាំពាន់វស្សា ទ្រង់ចូលនិព្វាន
ទុកតែសាសនា ប្រោសអស់ទេវតា មនុស្សសត្វទាំងឡាយ ។
8 ព្រះសិអារ្យមេត្រី ពោធិសត្វថ្លៃ ប្រសើរឆើតឆាយ ទ្រង់ត្រាស់ឯក្រោយ
ដោយពុទ្ធទំនាយ ព្រះជន្មវែងឆ្ងាយ ប្រាំបីម៉ឺនវស្សា ។
9 ដើមខ្នឹងជាពោ ធិព្រឹក្សសេដ្ឋោ ប្រសើរថ្លៃថ្លា ប្រោសមនុស្សទាំងឡាយ
អ្នកមានវាស្នា អស់ទាំងទេព្តា រាប់អសង្ខេយ្យ ។
10 ព្រមទាំងព្រះធម៌ ជ្រាលជ្រៅបវរ ប្រសើរពេកក្រៃ ប្រាំបីម៉ឺនបួនពាន់
ធម្មក្ខន្ធនោះនៃ របស់ជិនស្រី ទីទៃរាល់អង្គ ។
11 ព្រមទាំងព្រះសង្ឃ ប្រសើរសីលទ្រង់ ជាបុត្រព្រះពុទ្ធ លះកាត់តណ្ហា
ប្រសើរបំផុត ខ្ញុំសូមលំអុត កាយវាចាចិត្ត ។
12 ដោយតេជៈខ្ញុំ លើកហត្ថបង្គំ ត្រៃរតនា សូមកំចាត់បង់
សត្រូវនានា ទុក្ខសោករោគា វិនាសទៅហោង ៕ ចប់

រំលឹកគុណមាតាបិតា

បពិត្រមាតានិងបិតា　　លោកមានមេត្តាកូនទាំងឡាយ
តាំងពីកូនកើតមានរូបកាយ　　លោកតែងខ្វល់ខ្វាយថែរក្សា ។
ថ្នាក់ថ្នមបីបមម្ហូបចំណី　　មិនដែលខ្វះអ្វីសោះឡើយណា
គុណលោកទាំងពីរច្រើនណាស្ងា　　ពុំអាចពណ៌នាឲ្យអស់បាន ។
យើងខ្ញុំសូមផ្គងអញ្ជលី　　លើកហត្ថទាំងពីរបន្ទន់ប្រាណ
បង្គំបាទាព្រះក្បែរក្បាន្ត　　ទោសខុសប៉ុន្មានសូមប្រណី ។
ម្នាស់អើយកាលកូនទ្រូហោយំ　　លោកស្ទុះបីបមត្រកងបី
ច្រៀងបំពេរកូនដោយប្រិមប្រិយ៍　　ដោយចិត្តមេត្រីផ្តេកកូនណា ។
ទឹកមាត់ទឹកមូត្រលាមកផង　　ទាំងគ្រឿងសៅហ្មងផងនានា
លោកចាប់លោកកាន់លោកស្រទា　　លាងដោយហត្ថាមិនធុញទ្រាន់ ។
មាតាបិតាគឺជាព្រះ　　មានគុណច្រើនណាស់ពេកអនន្ត
កូនសូមគោរពព្រះគុណធ្ងន់　　វិសេសលើសលន់រាប់ពុំបាន ។
ពេលនេះកូនសូមឧទ្ទិសផល　　តាំងចិត្តដឹកល់ដោយក្លាហាន
ទានសីលភាវនាដែលកូនបាន　　សាងទាំងប៉ុន្មានជូនទៅលោក ។
ដោយអានិសង្សនៃបុណ្យនេះ　　សូមលោកបានរួចផុតទុក្ខសោក
រោគាព្យាធិកុំបីមក　　បៀតបៀនរូបលោកបានឡើយហោង
ដោយអានុភាពគោរពគុណ　　សូមព្រះមានបុណ្យជួយចម្លង
ឆ្លងផុតភពបីដូចបំណង　　ផុតគ្រឿងសៅហ្មងដូចប្រាថ្នា ។
កូនសូមបានជួបព្រះមានបុណ្យ　　ដែលលោកនិមន្តលើកសាសនា
កូនសូមបានជួបព្រះសីអារ្យ　　ស្តាប់ធម៌ទេសនានិព្វានហោង ។៕

ពាក្យម៉ែមួយម៉ាត់

---+++000+++---

+ពាក្យម៉ែមួយម៉ាត់ ប្រសើរពេកក្លាត់ ពេញដោយក្តីល្អ ប្រចាំដោយគុណ
វិសុទ្ធិបវរ មនុស្សពេញនគរ ល្អមិនស្មើម៉ែ ។
+ពាក្យម៉ែមួយម៉ាត់ ពេលកូនឈឺថ្កាត់ តែងស្រែកហៅម៉ែ ឮពាក្យម៉ែភ្លាម
កូនបានល្ហើយល្ហែ ឱម៉ែអើយម៉ែ ម៉ែល្អឥតបី ។
+ពាក្យម៉ែមួយម៉ាត់ លួងកូនឲ្យបាត់ ក្តីសោកវីងវ៉ៃ បាត់ភ័យលែងព្រួយ
សប្បាយហឫទ័យ ពាក្យម៉ែមានន័យ កាត់ថ្លៃពុំបាន ។
+ពាក្យម៉ែមួយម៉ាត់ អាចបង់កំចាត់ ទុក្ខសោកសាមាន្យ ញ៉ាំងកូនត្រេកអរ
រស់ដោយសាន្តត្រាណ ពាក្យម៉ែប្រៀបបាន និព្វមន្តថ្លាថ្លៃ ។
+ពាក្យម៉ែមួយម៉ាត់ កូនតែងច្រូខាត់ ហៅឥតឱនណាយ កូនរស់បានរៀន
ដោយសារគុណម្តាយ លះបង់ចិត្តកាយ ដើម្បីបុត្រា ។
+ពាក្យម៉ែមួយម៉ាត់ ឲ្យកូនធំធាត់ មានបុត្រភរិយា ល្បីល្បាញកេរ្តិ៍ឈ្មោះ
យសស័ក្តិទ្រព្យា ព្រោះម៉ែគាំពារ ជួយកូនរាល់ថ្ងៃ ។
+ពាក្យម៉ែមួយម៉ាត់ នៅពេលកូនព្រាត់ ប្រាសឆ្ងាយទីវែង កូនតែងរំលឹក
យំនឹករាល់ថ្ងៃ រស់ក្បែរម្តាយថ្លៃ ផុតទុក្ខគ្រាំគ្រា ។
+ពាក្យម៉ែមួយម៉ាត់ អាចចូលផ្តាច់កាត់ រាល់បុត្របញ្ហា ទោះមានឧបស័គ្គ
ធំធេងយ៉ាងណា ម៉ែប្តូរសង្ខារ ដើម្បីរូបកូន ។

+ពាក្យម៉ែមួយម៉ាត់ ពីរោះពេកក្លាត់ មិនចេះស្រពោន ម៉ែតែងខ្វល់ខ្វាយ
យិតយោងសណ្ដាន មិនឲ្យរូបកូន ធ្លាក់ក្នុងអវីចី ។
+ពាក្យម៉ែមួយម៉ាត់ ជាកំលាំងចិត្ត សែនមានតម្លៃ ជួយកូនសំរេច
សព្វកិច្ចការអ្វី ពាក្យម៉ែឲ្យជ័យ ស័ក្តិសិទ្ធិឧត្តម ។
+ពាក្យម៉ែមួយម៉ាត់ ល្បួងកូនឲ្យបាត់ ពីការទួញយំ ម៉ែអប់រំកូន
ពីតូចដល់ធំ ឱគុណម្ដាយខ្ញុំ ធ្ងន់លើសប្រថពី ។
+ពាក្យម៉ែមួយម៉ាត់ នៅពេលយប់ស្ងាត់ កូនខំសំភី រៀបរាប់គុណម៉ែ
ចារក្នុងគម្ពីរ លុះក្ស័យជីវី គ្រារាប់ពុំអស់ ។
+ពាក្យម៉ែមួយម៉ាត់ ជាទីប្រណិប័តន៍ នៃកូនស្រីប្រុស ម៉ែព្រះក្នុងផ្ទះ
ព្រះល្អឥតខ្ចោះ សូមកូនទាំងអស់ ចងចាំគ្រប់ប្រាណ។
+ពាក្យម៉ែមួយម៉ាត់ កូនណាប្រណិប័តន៍ នឹងបានសុខសាន្ត ទេវតាតាមថែ
សព្វគ្រប់ទីស្ថាន ស្លាប់ទៅនឹងបាន សោយសុខសួគ៌ា ។
+ពាក្យម៉ែមួយម៉ាត់ កូនត្រូវរូតរះ សំពះបូជា ទាន់ម្ដាយរស់នៅ
កូនត្រូវឧស្សាហ៍ ជូនភោជនាហារ បានបុណ្យច្រើនហោង ។៚

(ភិក្ខុ កង សុខណ្ណមុនី កុសល)

ព្រះគុណឪ

-+++000+++-

ពេលម៉ែពរផ្ទៃឪរងរ៉ាប់ ការងារយ៉ាកយ៉ាប់ឪបំពេញ
នោះការងារស្រីឬម្ដេចមិញ ឪត្រូវបំពេញជំនួសម៉ែ ។
ឪធ្វើកិច្ចការតែម្នាក់ឯង ក្រោមក្ដៅសូរ្យសែងឥតស្រាកល្ហែ
ញើសជោកកាយារាល់ថ្ងៃខែ ឪប្រឹងឥតប្រែចិត្តនឿយណាយ ។
ពេលម៉ែប្រសូតឪតក់ស្លុត ភិតភ័យស្រយុតចិត្តខ្វល់ខ្វាយ
រត់រកចាស់ទុំទីឋិតឆ្ងាយ ខ្លាចកូននិងម្ដាយឆ្លងមិនផុត ។
ពេលកូនកើតមកឪអរក្រៃ ទន់ទោរហឫទ័យចិត្តមុះមុត
អោបថើបថ្នមកូនស្ងួនវិសុទ្ធិ ឪដូចបានម្កុដពាក់លើក្បាល ។
រួចឪត្រូវធ្វើកិច្ចការងារ ដើម្បីគ្រួសារទាំងធ្ងន់ស្រាល
ចិញ្ចឹមម៉ែកូនស្ងួនគ្រប់កាល អាណាព្យាបាលគឺរូបឪ ។
ឪជាព្រះព្រហ្មទ្រនំកូន រូបឪជាក្បូនដែលកូនត្រូវ
ជិះឆ្លងខាលទុក្ខចេញទៅ កាន់ទីគោលដៅគឺសុខា ។
នោះត្រូវភ្លៀងផ្គរខ្ញ័រគំរាម ឪផ្គងព្យាយាមឥតរួញរា
ជីកគាស់កកាយផែនពសុធា ធ្វើស្រែចំការចិញ្ចឹមកូន ។
ថ្នាមរឹតរណ្ដំញ័រចំប្រប់ ឪស្ទើរសន្លប់ស្លាប់សោះសូន្យ
តែឪនៅនឹកដល់រូបកូន មាសស្ងួនស្ម័គ្រស្មោះស្មើជីវិត ។

ឱ្យធ្វើកិច្ចការតាំងពីព្រឹក ឯចិត្តរលឹកនឹកកូនពិត
រសៀលថ្ងៃរេរសាយខិត កាយឱ្យល្ហិតមកគេហា ។
ឱ្យអស់កម្លាំងស្លាំងជើងដៃ តែក្នុងហឫទ័យក្តីមេត្តា
ចូលវែ្របកបក្នុងលង់ចិន្តា ឱ្យត្រូវយាត្រាឲ្យដល់ផ្ទះ ។
នោះហោចនោះហត់អស់កម្លាំង ចិត្តតាំងកាយប្រឹងយ៉ាងរូតរះ
ដំណើរឆ្ពោះត្រង់តម្រង់ផ្ទះ អន្ទះសាចង់ឃើញមុខកូន ។
ឱ្យរួតដល់ផ្ទះវែងវីកកាយ ហោចហត់ចាំងឡាយរសាយសូន្យ
ពេលឱ្យឃើញមុខម្តាយនិងកូន ឱ្យលែងស្រែពានឱ្យត្រេកអរ ។
ឱ្យលេងឱ្យសើចនឹងកូនតូច ឱ្យច្រៀងឱ្យហួចដោយអំណរ
ឱ្យថើបឱ្យថ្នមបមបីព ពិស័យកេសដ៏ល្អស្អាត ។
ឱ្យខំបន្ទាបបន្ទន់ខ្លួន ដើម្បីកូនស្ងួនឆ្លួនសុទ្ធសាធ
ឱ្យដូចទាសីបំរើបាទ សន្ទាតប្រឹងប្រែងបំរើកូន ។
ចូលវ័យសិក្សាកុមារភាព ឱ្យលោមឱ្យស្ទាបកូនមាសស្ងួន
ដឹកដៃនាំទៅដោយលំទោន ពឹងគ្រូជួយកូនឲ្យចេះដឹង ។
កូនរៀនឱ្យរកទ្រព្យបំរុង ផ្គត់ផ្គង់គ្រួសារដោយប្រែប្រឹង
ខំហើយខំទៀតឆ្លៀតរំពឹង ថ្ងៃក្រោយកូននឹងជាមនុស្សល្អ ។
ឱ្យសញ្ជឹងគិតក្នុងចិត្តជប់ ត្បិតកូនមានភ័ព្វឱ្យត្រេកអរ
កូនរៀនចេះដឹងឱ្យសាធរ មិនចង់ឲ្យមោហ៍ចូលបិទបាំង ។

ឥឡូវកូនអើយឪចាស់ហើយ　　កូនកុំកន្តើយបែរគេគាំង
កុំអាងចំណេះហ៊ានប្រឆាំង　　មាត់ខ្លាំងតតាំងនឹងឪពុក ។
កូនត្រូវតាំងខ្លួនជាមនុស្សល្អ　　សង្គមឲ្យពរធើបបានសុខ
កុំចងបញ្ហាការស្មុគស្មាញស្រុក　　នាំមានក្តីទុក្ខជាប់កាយា ។
បើកូនសាងខ្លួនបានល្អហើយ　　កូនអើយនេះឯងក្តីប្រាថ្នា
ចង់ឃើញកូនល្បីល្បាញកិត្យា　　រស់ដោយសុខាក្នុងសង្គម ។
ហេតុនេះកូនៗស្ងួនវិសុទ្ធិ　　ឆ្លងផុតកុំភ្លេចចោលទ្រនំ
ត្រូវខាកមើលក្រោយឲ្យសមរម្យ　　រៀបចំទ្រនំឲ្យសុខសាន្ត ។
កូនត្រូវត្រងត្រាប់ស្តាប់ព្រះព្រហ្ម　　ហើយត្រូវរៀបចំនូវអង្គប្រាណ
ផ្តត់ផ្តង់ព្រហ្មវិញ្ញាណាកល្យាណ　　កុំព្រើលភ្លេចប្រាណណាពិសី ។
ឪចាស់ឪចង់ចំណីឆ្ងាញ់　　សូមកូនសំឡាញ់ឲ្យឪផឹ
មុងភួយខ្នល់ខ្នើយណាថ្មោងថ្មី　　សូមកូនលក់លៃធិញជូនគាត់ ។
បើកូនធ្វើបានមានសេរី　　មង្គលសួស្តីឥតប្រាសព្រាត់
សោយសុខចំរើនឥតភ្លាំងភ្លាត់　　លោកនេះប្រាកដដល់សួគ៌នាយ ។៚

(ភិក្ខុ ចន្ទធម្មោ សេន សែក)

ព្រះគុណម៉ែ

--+++000+++--

គុណម៉ែតាំងតែគភ៌ចាប់ផ្ដើម ទ្រាំពរពោះផើមទ្រាំលំបាក
ដេកដើរដូចរោគតាមឥតស្រាក ទម្រាំកូនចាកចេញពីផ្ទៃ ។
ពេលឆ្លងទន្លេម៉ែឈឺខ្លាំង ចិត្តតាំងកាយប្រឹងព្រមដោយភ័យ
មិនដឹងយ៉ាងណាចិត្តមមែ នឹកភ័យក្រែងកូនសូន្យសង្ខារ ។
លុះកូនបានកើតជាទារក ម៉ែថើបថញ្ជក់សព្វកាយា
បីបមថ្នាក់ថ្នមពេញហត្ថា បីផ្ទប់ឱរាដោយចិត្តស្មោះ ។
នៅពេលកូនឈឺម៉ែរក្សា មេត្តាប្រែឈាមជាទឹកដោះ
កូនឈឺម៉ែភ័យមុខស្លាំងអស់ មិនសម្រាន្តសោះខាល់ៗព្រឹក ។
នៅពេលកូនជាម៉ែសប្បាយ ចិត្តម៉ែមិនណាយមានតែនឹក
ឃ្លាតឆ្ងាយបន្តិចចិត្តខឹក រលឹករកកូនមិលមិញភ្លាម ។
អង្គុយកកិលក្រោកឈរដើរ ទៅតាមដំណើរម៉ែព្យាយាម
ខំបង្ហាត់កូនមិនធនាម ក្នុងនាមជាគ្រូឧត្តមក្រៃ ។
ជុះនោមហូបចុកស្លៀកដណ្ដប់ ចំណេះចេះសព្វប្រចាំថ្ងៃ
សំដីភាសាមារយាទថ្លៃ កូនកុំសង្ស័យក្រែងឥតគ្រូ ។

កូនចេះមួយមុខម៉ែអរម្តង　　អួតប្រាប់អ្នកផងមិនចាំយូរ
ម៉ែនឿយយ៉ាងណាមិនគិតគូរ　　បន្ធូរកង្វល់ដោយថ្នាល់កូន ។
កូនធំបន្តិចបែបបាងវែង　　កូនខ្លះទទឹងអាងជីដូន
ម៉ែខឹងអន់ចិត្តមុខស្រពោន　　វាយកូនរួចគិតអាណិតក្រោយ ។
កូនល្អម៉ែសុខក្រៃកន្លង　　បានដូចម៉ែផ្សងសូមអំណោយ
ដូចបានកែវទិព្វទេវតាឲ្យ　　ចុះដូចបានសោយសុខសួគ៌ា ។
ពេលកូនបានសុខម៉ែសុខផង　　ពេលកូនមានហ្មងម៉ែពុំថា
កូនក្រលំបាកម៉ែវេទា　　គ្រប់គ្រាម៉ែគិតកូនស្រីប្រុស ។
កូនខូចអាក្រក់ពេញភូមិឃុំ　　គេគុំគេស្អប់សព្វសាយសុស
ម៉ែដឹងប្រាកដថាកូនខុស　　តែម៉ែសន្តោសប្រោសប្រណី ។
ម៉ែគឺជាព្រះរបស់កូន　　ជាក្បួនជីវិតមនុស្សប្រុសស្រី
ម៉ែមានគុណធ្ងន់ហួសពោលស្ដី　　គ្មានអ្វីជំនួសម៉ែបានឡើយ ៕

(អគ្គបណ្ឌិត ប៊ុត សាវង្ស)

ការសូមខមាទោសចំពោះសព្វសត្វ

--+++OOO+++--

យេ កេចិ ខុទ្ទកា បាណា មហន្តាបិ មយា ហតា

យេ បាណោកេ បមាទេន កាយវាចាមនេហិ វា

បុញ្ញំ មេ អនុមោទន្តុ គណ្ហន្តុ ផលមុត្តមំ វេរិនោ ចេ

បមុញ្ចន្តុ សព្វទោសំ ខមន្តុ មេ ៕

សត្វទាំងឡាយណាមួយ ទោះបីតូចក្តី ធំក្តី ដែលខ្ញុំបានបៀតបៀនហើយ មួយទៀតសត្វទាំងឡាយពួកខ្លះ ដែលខ្ញុំបានធ្វើទុក្ខបុកម្នេញហើយ ព្រោះសេចក្តីប្រមាទ ភ្លាត់ភ្លាំងដោយកាយវាចាចិត្ត សត្វទាំងឡាយនោះ ចូរអនុមោទនានូវបុណ្យរបស់ខ្ញុំចុះ ចូរទទួលយកនូវផលបុណ្យដ៏ឧត្តមចុះ សូមអត់ទោសទាំងពួងដល់ខ្ញុំផង ៕ +++ (ចប់) +++

+សត្វណាក៏ដោយទោះខ្សោយឬខ្លាំង ឆាត់ឬស្គមស្គាំងរាប់ទាំងតូចធំ

ដែលយើងសម្លាប់ខុសច្បាប់សន្តម ប្រមាទវានាំកាយវាចាចិត្ត ។

+សូមសត្វទាំងឡាយរីករាយគំនិត យកផលប្រណីតបុណ្យយើងទៅចុះ

បើសត្វចងពៀរពេរាមិនរួះ ចូររួចគ្នាចុះទាំងអស់កុំខាន

សូមសត្វទាំងឡាយមេត្តាប្រោសប្រាណ អត់ទោសឲ្យបានដល់យើងខ្ញុំហោង

៕៚

សុភមង្គលគាថា

---+++000+++---

ហោតុ សព្វំ សុមង្គលំ	សុមង្គលគឺសេចក្តីចំរើនដ៏ល្អគ្រប់យ៉ាង ចូរមានដល់ខ្ញុំ
រក្ខន្តុ សព្វទេវតា	ទេវតាទាំងពួងទាំងឡាយចូររក្សានូវខ្ញុំ
សព្វពុទ្ធា នុភាវេន	ដោយអានុភាពនៃព្រះពុទ្ធគ្រប់ព្រះអង្គ
សព្វធម្មា នុភាវេន	ដោយអានុភាពនៃព្រះធម៌ទាំងពួង
សព្វសង្ឃា នុភាវេន	ដោយអានុភាពនៃព្រះសង្ឃទាំងពួង
សោត្ថិ ហោតុ និរន្តរំ	សូមសេរីសួស្តី ចូរមានដល់ខ្ញុំ ឲ្យបាន គ្រប់ពេលកុំបីមានចន្លោះឡើយ ។

បរាភវសូត្រ

បទបឋ្យាវត្ត

បរាភវន្តំ បុរិសំ មយំ បុច្ឆាម គោតមំ
ភវន្តំ បុដ្ឋុមាគម្ម កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយ មកសូមទូលសួរ នូវហេតុដែលគួរ ចម្រើនវិនាស
ប្រុសស្រីក្នុងលោ-កសន្និវាស ដែលនឹងវិនាស សាបសូន្យចាកគុណ ។
ឆ្លោះព្រះគោតម ព្រះអង្គមានបុណ្យ មេត្តានិមន្ត សំដែងឲ្យទាន
ធម្មជាតដូចម្តេច ដែលជាប្រធាន នាំសត្វឲ្យមាន សេចក្តីវិនាស ។

(ព្រះសាស្តាឆ្លើយតបនឹងទេវតាថា)

សុវិជានោ ភវំ ហោតិ សុវិជានោ បរាភវោ
ធម្មកាមោ ភវំ ហោតិ ធម្មទេស្សី បរាភវោ ។

អ្នកដែលចម្រើន តថាគតស្គាល់ងាយ អ្នកដែលអន្តរាយ តថាគតស្គាល់ពិត
អ្នកប្រាថ្នាធម៌ ល្អិតល្អក្នុងចិត្ត ហើយខំប្រព្រឹត្ត នឹងបានចម្រើន ។
អ្នកដែលទ្រុស្តធម៌ ស្អប់ធម៌ឥតកើន ឥតកើតចម្រើន វិនាសទៅមុខ ។

ឥតិ ហេតំ វិជានាម បឋមោ សោ បរាភវោ
ទុតិយំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង ព្រោះហេតុដូច្នោះ
ក្តីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី១ទាន់ហន់ ។
បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សំដែងឲ្យទាន
វិនាសទី២ អ្វីជាប្រធាន នាំសត្វឲ្យមាន សេចក្តីវិនាស ។

អសន្តស្ស បិយា ហោន្តិ សន្តេន កុរុតេ បិយំ
អសតំ ធម្មរោចេតិ តំ បរាភវតោ មុខំ ។

អ្នកដែលស្រឡាញ់ ពេញចិត្តស្នេហា តែនឹងមនុស្សណា អសប្បុរស
តែងមិនស្រឡាញ់ ពេញចិត្តទាំងអស់ នឹងអ្នកសប្បុរស មកធ្វើជាមិត្ត ។
សេចក្តីស្រឡាញ់ ពេញចិត្តគំនិត ហើយទៅគប់មិត្ត អសប្បុរស
គាប់ចិត្តក្នុងធម៌ ឬមួយរបស់ ហេតុនោះទាំងអស់ នាំឲ្យវិនាស ។

ឥតិ ហេតំ វិជានាម ទុតិយោ សោ បរាភវោ
តតិយំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង ព្រោះហេតុដូច្នោះ
ក្តីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី២ទាន់ហន់ ។
បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សំដែងឲ្យទាន
វិនាសទី៣ អ្វីជាប្រធាន នាំសត្វឲ្យមាន សេចក្តីវិនាស ។

និទ្ទាសីលី សភាសីលី អនុដ្ឋាតា ច យោ នរោ
អលសោ កោធបញ្ញាណោ តំ បរាភវតោ មុខំ ។

អ្នកដេកច្រើនមួយ និយាយច្រើនមួយ និងអ្នកឥតព្យួយ ឥតគិតប្រឹងប្រែង
អ្នកខ្ជិលច្រអូស មិនមានខ្នះខ្នែង ខឹងច្រើនសំដែង ឲ្យគេឃើញបាន ។
ហេតុធម៌ទាំងនោះ មិនជាកល្យាណ នាំឲ្យខកខាន ខាតខូចប្រយោជន៍
មានជាប្រធាន តិចច្រើនដោយហោច នាំបង់ប្រយោជន៍ ហើយឲ្យវិនាស ។

ឥតិ ហេតំ វិជានាម តតិយោ សោ បរាភវោ
ចតុត្ថំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង ព្រោះហេតុដូច្នោះ
ក្តីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទីពទាន់ហាន់ ។
បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សំដែងឲ្យទាន
វិនាសទី៤ អ្វីជាប្រធាន នាំសត្វឲ្យមាន សេចក្តីវិនាស ។

យោ មាតរំ វា បិតរំ វា ជិណ្ណកំ គតយោព្វនំ
បហុសន្តោ ន ភរតិ តំ បរាភវតោ មុខំ ។

នរជនណា មានទ្រព្យធនធាន ហើយខ្លួនមិនបាន ចិញ្ចឹមរក្សា
មាតាបិតា ដែលចាស់ជរា ហេតុនោះទៅជា នាំឲ្យវិនាស ។

ឥតិ ហេតំ វិជានាម ចតុត្ថោ សោ បរាភវោ
បញ្ចមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយ បាននឹងជាក់ស្តែង វិនាសនេះឯង ព្រោះហេតុដូច្នោះ
ក្តីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី៤ទាន់ហន់ ។
បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សំដែងឲ្យទាន
វិនាសទី៥ អ្វីជាប្រធាន នាំសត្វឲ្យមាន សេចក្តីវិនាស ។

យោ ព្រាហ្មណំ សមណំ វា អញ្ញំ វាបិ វនិព្វកំ
មុសាវាទេន វញ្ចេតិ តំ បរាភវតោ មុខំ ។

ជនបញ្ឆោតព្រាហ្មណ៍ ឬពួកសមណៈ ពួកស្មូមឬអ្នក ដទៃៗ
ដោយមុសាវាទ ឃ្លាតពាក្យប្រពៃ នោះប្រធាននៃ សេចក្តីវិនាស ។

ឥតិ ហេតំ វិជានាម បញ្ចមោ សោ បរាភវោ
ឆដ្ឋមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយ បាននឹងជាក់ស្តែង វិនាសនេះឯង ព្រោះហេតុដូច្នោះ
ក្តីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី៥ទាន់ហន់ ។
បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សំដែងឲ្យទាន
វិនាសទី៦ អ្វីជាប្រធាន នាំសត្វឲ្យមាន សេចក្តីវិនាស ។

បហុតវិត្តោ បុរិសោ សហិរញ្ញោ សភោជនោ
ឯកោ ភុញ្ជតិ សាទូនិ តំ បរាភវតោ មុខំ ។

បុរសអ្នកមាន ទ្រព្យធនធានច្រើន មាសប្រាក់ចម្រើន និងគ្រឿងអាហារ
លបលាក់របស់ ដែលឆ្ងាញ់ពិសា ស៊ីម្នាក់ឯងជា ប្រធានវិនាស ។

ឥតិ ហេតំ វិជានាម ឆដ្ឋមោ សោ បរាភវោ
សត្តមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង ព្រោះហេតុដូច្នោះ
ក្តីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី៦ទាន់ហន់ ។
បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សំដែងឲ្យទាន
វិនាសទី៧ អ្វីជាប្រធាន នាំសត្វឲ្យមាន សេចក្តីវិនាស ។

ជាតិត្ថទ្ធោ ធនត្ថទ្ធោ គោត្តត្ថទ្ធោ ច យោ នរោ
សញ្ញាតឹ អតិមញ្ញេតិ តំ បរាភវតោ មុខំ ។

អ្នកដែលប្រកាន់ ជាតិទ្រព្យត្រកូល ហើយមិនប្រមូល សាច់ញាតិសន្តាន
មើលងាយញាតិខ្លួន ដោយអាងខ្លួនមាន នោះជាប្រធាន សេចក្តីវិនាស ។

ឥតិ ហេតំ វិជានាម សត្តមោ សោ បរាភវោ
អដ្ឋមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង ព្រោះហេតុដូច្នោះ
ក្តីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី៧ទាន់ហន់ ។
បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សំដែងឲ្យទាន
វិនាសទី៨ អ្វីជាប្រធាន នាំសត្វឲ្យមាន សេចក្តីវិនាស ។

ឥត្ថីធុត្តោ សុរាធុត្តោ អក្ខធុត្តោ ច យោ នរោ
លទ្ធំ លទ្ធំ វិនាសេតិ តំ បរាភវតោ មុខំ ។

ជនអ្នកប្រព្រឹត្ត ល្បែងបីប្រការ ល្បែងស្រីល្បែងស្រា ល្បែងភ្នាល់ទាំងឡាយ
ធ្វើទ្រព្យខ្លួនមាន ឲ្យអន្តរាយ ការល្បែងទាំងឡាយ នោះនាំវិនាស ។

ឥតិ ហេតំ វិជានាមអដ្ឋមោ សោ បរាភវោ
នវមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង ព្រោះហេតុដូច្នោះ
ក្តីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី៨ទាន់ហន់ ។
បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សំដែងឲ្យទាន
វិនាសទី៩ អ្វីជាប្រធាន នាំសត្វឲ្យមាន សេចក្តីវិនាស ។

សេហិ ទារេហិ អសន្តុដ្ឋោ វេសិយាសុ បទុស្សតិ
ទុស្សតិ បរទារេសុ តំ បរាភវតោ មុខំ ។

ប្រុសមិនត្រេកអរ នឹងប្រពន្ធខ្លួន ហើយទៅជាប់ជួន នឹងស្រីពេស្យា
ទ្រុស្តនឹងប្រពន្ធ កូនជននានា ហេតុនោះទៅជា នាំឲ្យវិនាស ។

ឥតិ ហេតំ វិជានាម នវមោ សោ បរាភវោ
ទសមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង ព្រោះហេតុដូច្នោះ
ក្តីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី៩ទាន់ហាន់ ។
បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សំដែងឲ្យទាន
វិនាសទី១០ អ្វីជាប្រធាន នាំសត្វឲ្យមាន សេចក្តីវិនាស ។

អតីតយោព្វនោ បោសោ អានេតិ តិម្ពរុត្ថនឹ
តស្សា ឥស្សា ន សុបតិ តំ បរាភវតោ មុខំ ។

បុរសមានវ័យ ដែលចាស់ហួសពេក ហើយមានតម្រេក ដោយក្តីតណ្ហា
នាំយកស្រីក្មេង មកធ្វើភរិយា ហេតុនោះទៅជា នាំឲ្យវិនាស ។

ឥតិ ហេតំ វិជានាម ទសមោ សោ បរាភវោ
ឯកាទសមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង ព្រោះហេតុដូច្នោះ
ក្តីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី១០ទាន់ហាន់ ។
បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សំដែងឲ្យទាន
វិនាសទី១១ អ្វីជាប្រធាន នាំសត្វឲ្យមាន សេចក្តីវិនាស ។

ឥត្ថី សោណ្ឌី វិកិរណី បុរិសំ វាបិ តាទិសំ
ឥស្សរិយស្មឹ ឋបេតិ តំ បរាភវតោ មុខំ ។

បុរសតាំងស្រី អ្នកលេងខ្ជះខ្ជាយ ឬស្រីទាំងឡាយ តាំងបុរសនោះ
ដែលជាអ្នកលេង ខ្ជះខ្ជាយដូច្នោះ អំពើទាំងនោះ នាំឲ្យវិនាស ។

ឥតិ ហេតំ វិជានាម ឯកាទសមោ សោ បរាភវោ
ទ្វាទសមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង ព្រោះហេតុដូច្នោះ
ក្តីវិនាសនេះ បើរាប់សង្គ្រោះ វិនាសនោះឈ្មោះ ទី១១ទាន់ហាន់ ។
បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សំដែងឲ្យទាន
វិនាសទី១២ អ្វីជាប្រធាន នាំសត្វឲ្យមាន សេចក្តីវិនាស ។

អប្បភោគោ មហាតណ្ហោ ខត្តិយេ ជាយតេ កុលេ
សោ ច រជ្ជំ បត្ថយតិ តំ បរាភវតោ មុខំ ។

ជនណាកើតក្នុង ត្រកូលជាក្សត្រ អ្នកខ្សត់សម្បត្តិ ហើយប្រាថ្នាធំ
ចង់បានជាស្តេច សោយរាជ្យស្តុកស្តម្ភ ហេតុនោះនឹងនាំ ឲ្យដល់វិនាស ។

ឯតេ បរាភវេ លោកេ បណ្ឌិតោ សមវេក្ខិយ
អរិយទស្សនសម្បន្នោ ស លោកំ ភជតេ សិវំ ។

ជនជាបណ្ឌិត គំនិត្យប្រសើរ បានឃើញដំណើរ នៃហេតុវិនាស
ដល់សត្វក្នុងលោ-កសន្និវាស គេចពីវិនាស គប់រកចម្រើន ។

(**បរាភវសុត្តំ និដ្ឋិតំ**)

(បរាភវសូត្រ ចប់)

អាយុរបស់សត្វទាំងឡាយក្នុងត្រៃភព

+++សត្វទាំងឡាយដែលកើតក្នុងអបាយភូមិ៤ក្តី កើតក្នុងជម្ពូទ្វីបក្តី ពុំមានកំណត់អាយុឡើយ រមែងប្រព្រឹត្តទៅតាមកម្មផលរបស់ខ្លួន ។

+++មនុស្សកើតក្នុង ឧត្តរកុរុទ្វីប មានអាយុកំណត់ ១.០០០ឆ្នាំមនុស្ស

+++មនុស្សកើតក្នុង អមរគោយានទ្វីប-បុព្វវិទេហទ្វីប មានអាយុកំណត់ ៥០០ឆ្នាំមនុស្ស

ចំណែកមនុស្សកើតក្នុងស្ថានសួគ៌មានអាយុដូចតទៅ :

	ស្ថានសួគ៌ ៦ជាន់	១ថ្ងៃនៃទេវតានៅស្ថាន	ចំនួនឆ្នាំទិព្វ	ចំនួនឆ្នាំមនុស្ស
១	ចាតុម្មហារាជិកា	ស្មើ៥០ឆ្នាំរបស់មនុស្ស	៥០០ឆ្នាំទិព្វ	៩. ០០០.០០០
២	តាវតឹង្ស	- ១០០ - -	១.០០០ -	៣៦. ០០០.០០០
៣	យាមា	- ២០០ - -	២.០០០ -	១៤៤. ០០០.០០០
៤	តុសិត	- ៤០០ - -	៤.០០០ -	៥៧៦. ០០០.០០០
៥	និម្មានរតី	- ៨០០ - -	៨.០០០ -	២ .៣០៤. ០០០.០០០
៦	បរនិម្មិតវសវត្តី	-១.៦០០ - -	១៦.០០០ -	៩ .២១៦. ០០០.០០០

អាយុរបស់ព្រហ្មមានរូប

	ឈ្មោះឈានតាមលំដាប់ថ្នាក់	ឈ្មោះស្ថានព្រហ្ម	អាយុរបស់ព្រហ្ម
១	បឋមជ្ឈាន ជាបរិត្តយ៉ាងទន់	ព្រហ្មបរិសជ្ជា	១/៣ នៃកប្ប
២	បឋមជ្ឈាន ជាមជ្ឈិមយ៉ាងកណ្តាល	ព្រហ្មបុរោហិតា	១/២ កប្ប
៣	បឋមជ្ឈាន ជាប្រណីតយ៉ាងឧក្រិដ្ឋ	មហាព្រហ្ម	១ កប្ប
១	ទុតិយជ្ឈាន ជាបរិត្ត	បរិត្តាភា	២ កប្ប
២	ទុតិយជ្ឈាន ជាមជ្ឈិម	អប្បមាណាភា	៤ កប្ប
៣	ទុតិយជ្ឈាន ជាប្រណីតយ៉ាងឧក្រិដ្ឋ	អាភស្សរា	៨ កប្ប

អាយុរបស់ព្រហ្មមានរូប

:	: ឈ្មោះឈានតាមលំដាប់	: ឈ្មោះស្ថានរបស់ព្រហ្ម	: អាយុរបស់ព្រហ្ម
: ១ :	តតិយជ្ឈាន ជាបរិត្ត	: បរិត្តសុភា	: ១៦ កប្ប
: ២ :	តតិយជ្ឈាន ជាមជ្ឈិម	: អប្បមាណសុភា	: ៣២ កប្ប
: ៣ :	តតិយជ្ឈាន ជាប្រណីត	: សុភកិណ្ហា	: ៦៤ កប្ប
: ១ :	ចតុត្ថជ្ឈាន ជាបរិត្ត	: វេហប្ផលា	: ៥០០ កប្ប
: ២ :	ចតុត្ថជ្ឈាន មជ្ឈិម	: អសញ្ញីសត្តា	: ៥០០ កប្ប
: ៣ :	ចតុត្ថជ្ឈាន ជាប្រណីត	: អវិហា	: ១.០០០ កប្ប
	ជាព្រះអនាគាមីបុគ្គល	: អតប្បា	: ២.០០០ កប្ប
	ក្នុងជាន់សុទ្ធាវាសទាំង ៥	: សុទស្សា	: ៤.០០០ កប្ប
		: សុទស្សី	: ៨.០០០ កប្ប
		: អកនិដ្ឋា	: ១៦.០០០ កប្ប

អាយុរបស់ព្រហ្មគ្មានរូប

:	: ឈ្មោះឈានតាមលំដាប់	: ឈ្មោះស្ថានរបស់ព្រហ្ម	: អាយុរបស់ព្រហ្ម
: ១ :	អរូបព្រហ្មទី ១	: អាកាសានញ្ចាយតនសមាបត្តិ	: ២ ម៉ឺនមហាកប្ប
: ២ :	អរូបព្រហ្មទី ២	: វិញ្ញាណញ្ចាយតនសមាបត្តិ	: ៤ --
: ៣ :	អរូបព្រហ្មទី ៣	: អាកិញ្ចញ្ញាយតនសមាបត្តិ	: ៦ --
: ៤ :	អរូបព្រហ្មទី ៤	: នេវសញ្ញានាសញ្ញាយតនសមា	: ៨៤.០០០ មហាកប្ប

មង្គលសូត្រ

ឯវម្មេ សុតំ *សូត្រនេះឈ្មោះមង្គលសូត្រ គឺខ្ញុំឈ្មោះអានន្ទបានស្តាប់មកហើយយ៉ាងនេះថា*

ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ

សម័យមួយព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន
ជាអារាមរបស់ អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី

អថខោ អញ្ញតរា ទេវតា អភិក្កន្តាយ រត្តិយា អភិក្កន្ត វណ្ណា
កេវលកប្បំ ជេតវនំ ឱភាសេត្វា យេន ភគវា តេនុបសង្កមិ
ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ

លំដាប់នោះឯងទេវតាអង្គមួយ កាលដែលវេលារាត្រីបឋមយាមកន្លងទៅហើយ មានរស្មីដ៏ល្អញ៉ាំងវត្តជេតពនជុំវិញទាំងអស់ឲ្យភ្លឺស្វាងហើយ ព្រះដ៏មានព្រះភាគទ្រង់គង់ក្នុងទីណា ក៏ចូលទៅក្នុងទីនោះ លុះចូលទៅដល់ហើយ ទើបថ្វាយបង្គំចំពោះអង្គព្រះដ៏មានព្រះភាគ ហើយឈរនៅក្នុងទីដ៏សមគួរ ។

ឯកមន្តំ ឋិតា ខោ សា ទេវតា ភគវន្តំ គាថាយ អជ្ឈភាសិ

កាលទេវតានោះឈរក្នុងទីដ៏សមគួរហើយ ទើបក្រាបទូល
ព្រះដ៏មានព្រះភាគ ដោយពាក្យជាគាថាយ៉ាងនេះថា :

ពហូ ទេវា មនុស្សា ច មង្គលានិ អចិន្តយុំ
អាកង្ខមានា សោត្ថានំ ព្រូហិ មង្គលមុត្តមំ

ទេវតានិងមនុស្សទាំងឡាយជាច្រើន ប្រាថ្នានូវសេចក្តីសួស្តី បានគិតរកនូវមង្គលទាំងឡាយ សូមព្រះអង្គទ្រង់ព្រះមេត្តាសំដែងប្រាប់នូវមង្គលដ៏ឧត្តម ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សំដែងតបពាក្យទេវតានោះ ដោយពុទ្ធភាសិតជាគាថាយ៉ាងនេះថា

អសេវនា ច ពាលានំ បណ្ឌិតានញ្ច សេវនា
បូជា ច បូជនីយានំ ឯតម្មង្គលមុត្តមំ

កិរិយាមិនសេពគប់នូវបុគ្គលពាលទាំងឡាយ១ កិរិយាសេពគប់នូវបុគ្គលជាបណ្ឌិតទាំងឡាយ១ កិរិយាបូជាដល់បុគ្គលដែលគួរបូជាទាំងឡាយ១ ទាំង៣នេះជាមង្គលដ៏ឧត្តម។

បដិរូបទេសវាសោ ច បុព្វេ ច កតបុញ្ញតា
អត្តសម្មាបណិធិ ច ឯតម្មង្គលមុត្តមំ

កិរិយានៅក្នុងប្រទេសដ៏សមគួរ១ ភាវនៃបុគ្គលបានធ្វើបុណ្យទុកហើយក្នុងកាលមុន១ កិរិយាដំកល់ខ្លួនដោយប្រពៃ១ ទាំង៣នេះជាមង្គលដ៏ឧត្តម។

ពាហុសច្ចញ្ច សិប្បញ្ច វិនយោ ច សុសិក្ខិតោ
សុភាសិតា ច យា វាចា ឯតម្មង្គលមុត្តមំ

ភាវៈនៃបុគ្គលបានស្តាប់បានរៀនហើយដោយច្រើន១ សិល្បសាស្ត្រគឺសេចក្តីឆ្លៀវឆ្លាសក្នុងហត្ថកម្មរបស់អ្នកបួសនិងគ្រហស្ថ១ វិន័យដែលបុគ្គលសិក្សាដោយប្រពៃ១ វាចាដែលបុគ្គលពោលត្រឹមត្រូវ១ ទាំង៤នេះជាមង្គលដ៏ឧត្តម។

មាតាបិតុឧបដ្ឋានំ បុត្តទារស្ស សង្គហោ
អនាកុលា ច កម្មន្តា ឯតម្មង្គលមុត្តមំ

កិរិយាបំរើនូវមាតា១ កិរិយាបំរើនូវបិតា១ សេចក្តីសង្គ្រោះដល់បុត្រនិងភរិយា១ ការងារទាំងឡាយដែលមិនច្របូកច្របល់១ ទាំង៤នេះជាមង្គលដ៏ឧត្តម ។

ទានញ្ច ធម្មចរិយា ច ញាតកានញ្ច សង្គហោ
អនវជ្ជានិ កម្មានិ ឯតម្មង្គលមុត្តមំ

កិរិយាបរិច្ចាគទាន១ កិរិយាប្រព្រឹត្តនូវធម៌១ សេចក្ដីសង្គ្រោះដល់ញាតិទាំងឡាយ១ ការងារទាំងឡាយដែលមិនមានទោស១ ទាំង៤នេះជាមង្គលដ៏ឧត្ដម

អារតី វិរតី បាបា មជ្ជបានា ច សញ្ញមោ
អប្បមាទោ ច ធម្មេសុ ឯតម្មង្គលមុត្តមំ

កិរិយាមិនត្រេកអរក្នុងបាបនិងកិរិយាវៀរចាកបាប១ សេចក្ដីសង្រួមចាកកិរិយាផឹកនូវទឹកស្រវឹង១ សេចក្ដីមិនប្រមាទក្នុងធម៌ទាំងឡាយ១ ទាំង៣នេះជាមង្គលដ៏ឧត្ដម ។

គារវោ ច និវាតោ ច សន្តុដ្ឋី ច កតញ្ញុតា
កាលេន ធម្មស្សវនំ ឯតម្មង្គលមុត្តមំ

សេចក្ដីគោរពចំពោះបុគ្គលដែលគួរគោរព១ កិរិយាប្រព្រឹត្តបន្ទាបនូវខ្លួន១ សេចក្ដីត្រេកអរចំពោះរបស់ដែលមាន១ ភាវៈនៃបុគ្គលអ្នកដឹងនូវឧបការៈដែលអ្នកដទៃធ្វើហើយដល់ខ្លួន១ កិរិយាស្ដាប់នូវធម៌តាមកាល១ ទាំង៥នេះជាមង្គលដ៏ឧត្ដម ។

ខន្តិ ច សោវចស្សតា សមណានញ្ច ទស្សនំ
កាលេន ធម្មសាកច្ឆា ឯតម្មង្គលមុត្តមំ

សេចក្តីអត់ធន់១ ភាវៈនៃបុគ្គលដែលគេប្រដៅបានដោយងាយ១ កិរិយាបានឃើញបានជួបនឹងសមណៈទាំងឡាយ១ ធម្មសាកច្ឆាគឺកិរិយាសន្ទនាទៅវិញទៅមកនូវធម៌តាមកាល១ ទាំង៨នេះជាមង្គលដ៏ឧត្តម ។

តបោ ច ព្រហ្មចរិយញ្ច អរិយសច្ចាន ទស្សនំ

និព្វាន សច្ឆិកិរិយា ច ឯតម្មង្គលមុត្តមំ

